ព្រះពុទ្ធវង្ស សេខ នាង អគ្គាធិការរងនៃពុទ្ធិកសិក្សា
កែសម្រួលដោយពិនិត្យពិច័យ

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

# សម្រង់អត្ថបទ

ប្រធានសព្ទ

សម្រាប់ថ្នាក់ឆ្នាំទី ១ និង ថ្នាក់ឆ្នាំទី ២

នៃសាលាពុទ្ធិកបឋមសិក្សា

INSTITUT BOUDDHIQUE

៣២៥.
១៩៩

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៥៣៩

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្ស កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage.  This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

៧២៥.១៩៩

**ព្រះពុទ្ធវង្ស សេង នាង** អគ្គាធិការរងនៃពុទ្ធិកសិក្សា
កែសម្រួលដោយពិនិត្យពិច័យ

BUDDHIST INSTITUTE
LIBRARY
១៣៩០/៩៥
06.12

# សម្រង់អត្ថបទ

ប្រធានសព្ទ

**សម្រាប់ថ្នាក់ឆ្នាំទី ១ និងឆ្នាំទី ២**

នៃសាលាពុទ្ធិកបឋមសិក្សា

បោះពុម្ពឡើងវិញ ចំនួន ៣.៥០០ ច្បាប់
តាមច្បាប់បោះពុម្ពលើកទី ២

**ភ្នំពេញ**
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៥៣៩ គ.ស ១៩៩៥

www.budinst.gov.kh www.elibraryofcambodia.org

# សេចក្តីបញ្ជាក់
# ចំពោះការបោះពុម្ពឡើងវិញ

សៀវភៅនេះ ត្រូវបានបោះពុម្ពជាថ្មីឡើងវិញ ដោយមានការឧបត្ថម្ភពីអង្គការជំនួយសូតូស៊ូជប៉ុន (JSRC) និងពីអង្គការ រិស្សូ កូសី-កៃ (RKK) ។

ការបោះពុម្ពឡើងវិញលើកនេះ ធ្វើឡើងដោយថតចម្លងពីសៀវភៅច្បាប់ដើមទាំងស្រុង ។ ហេតុនេះ ប្រសិនបើមានកំហុសអក្ខរាវិរុទ្ធក្តី កំហុសក្នុងការរៀបរៀងឃ្លាក្តី នោះគឺជាលក្ខណៈដែលមានក្នុងច្បាប់ដើមពីមុនមក ។

ពុទ្ធសាសនបណ្ឌិត្យ សូមអភ័យទោសជាមុន ចំពោះកង្វះខាតផ្សេងៗ ដែលអាចនឹងកើតមានដោយអចេតនា ក្នុងការបោះពុម្ពឡើងវិញនេះ ។

ពុទ្ធសាសនបណ្ឌិត្យ នឹងខិតខំចាត់ការបោះពុម្ពសៀវភៅសិក្សា និងសៀវភៅអានគ្រប់បែបយ៉ាងផ្សេងទៀត ដើម្បីតម្រូវទៅតាមការចាំបាច់ប្រើប្រាស់របស់សាធារណជនផង ដើម្បីរក្សាមរតកវប្បធម៌ អក្សរសាស្ត្រ អោយគង់វង្ស និងរីកចំរើនផង ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះអង្គការជំនួយសូតូស៊ូជប៉ុន (JSRC) និងអង្គការ រិស្សូ កូសី-កៃ (RKK) ដែលបានផ្តល់ការឧបត្ថម្ភដ៏ឧត្តុង្គឧត្តមដល់ការបោះពុម្ពសៀវភៅនេះ ។

ភ្នំពេញ, ខែ កញ្ញា ឆ្នាំ ១៩៩៥

ពុទ្ធសាសនបណ្ឌិត្យ

www.budinst.gov.kh www.elibraryofcambodia.org

## ごあいさつ

この本は、立正佼成会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の仏教徒とカンボジアの人々との友情のきずなとなり、カンボジアの文化発展に貢献できれば幸いです。

## និវេទនកថា

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយអង្គការជំនួយសូតូស៊ូជប៉ុន ( JSRC ) និងដោយមានការឧបត្ថម្ភពី

អង្គការ រិស្សូ កូសី-កៃ (RKK)

យើងអធិដ្ឋាន សូមអោយសៀវភៅនេះបានជាវិភាគទានរក្សាមិត្តភាពជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនា និងសម្បត្តិវប្បធម៌របស់ប្រជាជនកម្ពុជា ។

## ACKNOWLEDGEMENT

This book has been printed by Japan Sotoshu Relief Committee (JSRC) with the contribution from

Rissho Kosei-Kai (RKK)

We pray that this book would contribute to the friendship with Cambodian people and their religious and cultural preservation.


www.budinst.gov.kh www.elibraryofcambodia.org

ព្រះពុទ្ធវង្ស

សេខ - នាខ
អគ្គាធិការរងនៃពុទ្ធិកសិក្សា

កែសម្រួលដោយពិនិត្យពិច័យ

# សម្រង់អត្ថបទ

## ប្រធានសព្ទ

## សម្រាប់ថ្នាក់ឆ្នាំទី ១

នៃសាលាពុទ្ធិកបឋមសិក្សា

ក្នុង

កម្ពុជរដ្ឋ

តម្កល់ទុកតាមច្បាប់លេខ ៣៩៦
ចុះថ្ងៃទី ៣១-១០-៦៩-បោះពុម្ពលើកទី ២
ចំនួន ២.០០០ ក្បាល

រក្សាសិទ្ធិគ្រប់យ៉ាង

ព.ស. ២៥១៤ គ.ស. ១៩៧០

www.budinst.gov.kh www.elibraryofcambodia.org

## អារម្ភកថា

● នៅសាលាពុទ្ធិកបឋមសិក្សាសព្វថ្ងៃ អត្ថបទជាភាសាជាតិ សម្រាប់ការអាននិងសរសេរតាមសូត្យ ដែលស្របតាមប្រធានសព្ទនេះ នៅខ្វះច្រើនណាស់ ជាហេតុនាំឲ្យលោកគ្រូបង្រៀនលំបាកពន់ពេក ក្នុងការអនុវត្តន៍តាមកម្មវិធីសិក្សា ផ្នែកភាសាជាតិ ។

● អាស្រ័យហេតុនេះ ខ្ញុំបានប្រគលភារៈ ឲ្យលោក ចន្ទ សយ ជួយរៀបរៀងអត្ថបទទាំងអស់នេះ ហើយខ្ញុំយកមកកែសម្រួលដោយពិនិត្យពិច័យ រួបរួមជាសៀវភៅមួយឈ្មោះថា **សៀវភៅសម្រង់អត្ថបទ** ខ្ញុំយល់ថាសៀវភៅនេះ ទុកជាឧបករណ៍មួយ មានសារៈដ៏សំខាន់ដល់លោកគ្រូនិងសិស្ស ប្រចាំថ្នាក់ទី ១ និងទី ២ នៃសាលាពុទ្ធិកបឋមសិក្សា ស្របទៅតាមគោលបំណង នៃការបង្កើតពុទ្ធិកបឋមភូមិ ។

វត្តឧណ្ណាលោម, ថ្ងៃ ទី ២៥ វិច្ឆិកា ឆ្នាំ ១៩៦៩

ព្រះពុទ្ធវង្ស សេង - នាង

អគ្គាធិការរងនៃពុទ្ធិកសិក្សា

www.budinst.gov.kh www.elibraryofcambodia.org

# មាតិកាអត្ថបទថ្នាក់ទី ១


អំពីវត្ត ទំព័រ ១
វត្តឧណ្ណាលោម –២
សិទ្ធត្ថកុមារ –៣
ព្រះពុទ្ធវិន័យ –៤
អាគារិយវិន័យ –៥
អនាគារិយវិន័យ –៦
សាមណេរសន –៧
បព្វជិត –៨
ចៅអធិការ –៩
នាទីចៅអធិការ –១០
អនុគណ ១១
នាទីអនុគណ –១២
មេគណ –១៣
នាទីមេគណ –១៤
ថេរសភា –១៥
ឧបាសក - សិកា –១៦
សមណសក្តិ –១៧
សមណបរិក្ខារ –២០

រឿងសុទត្ត ទំព័រ ២១
នាងវិសាខា –២២
អំពីភូមិ –២៣
អ្នកស្រុក –២៤
របរអ្នកស្រុក –២៥
ជីវភាពអ្នកស្រែ –២៦
ជីវភាពឧស្សាហករ- ២៧
នាយស្ទូនធ្នាំង –២៨
ជាងកំបោរ –២៩
ជាងឈើ –៣០
រឿងអណ្តើកនិងស្វា –៣១
អស្សុតរអស់ឫទ្ធិ –៣២
ជីវភាពអ្នកចំការ –៣៣
ជាងតម្បាញ –៣៤
បុណ្យចូលឆ្នាំ –៣៥
បុណ្យភ្ជុំបិណ្ឌ –៣៦
ទង់ជាតិ –៣៧
ទង់សាសនា –៣៨

ទង់មហារាជ ទំព័រ ៣៩
ទង់ជ័យ –៣៩
ថ្ងៃទី ៩ វិច្ឆិកា –៤០
អគ្គពុទ្ធសាសនូ
បត្ថម្ភក៍ –៤១
ជីវភាពមនុស្ស
ជាន់ដើម –៤២
គេហដ្ឋាន –៤៣
អំពីញាតិ –៤៤
អំពីគ្រួសារ –៤៥
សេចក្តីស្នេហា
របស់បុត្រធីតា –៤៦
សាមណេរសន
និងមាតា –៤៧
សេចក្តីស្នេហា
របស់មាតាបិតា –៤៨


www.budinst.gov.kh www.elibraryofcambodia.org

# មាតិកាអត្ថបទថ្នាក់ទី ២


មុខវិជ្ជានៅពុទ្ធិក
សិក្សា ទំព័រ ៥១
ពុទ្ធិកសិក្សា
សម័យដើម —៥២
អំពីសិស្សល្អ – ៥៣
អតីតសាលា
បឋមសិក្សា —៥៤
ការគ្រប់គ្រងផ្ទះ —៥៦
ពុទ្ធិកសិក្សា
សម័យឯករាជ្យ —៥៧
ព្រះពុទ្ធ – ៥៨
ចិត្តមាតាបិតា —៥៩
ការប្រព្រឹត្តទៅ
នៃជីវិត –៦១
អំពីមុខការ –៦២
សេចក្ដីព្យាយាម –៦៣
សត្វរុយនិងមូស –៦៥
វិជ្ជាពេទ្យ –៦៦
កសិកម្ម —៦៧
វិធីសាបស្រូវ –៦៩
រដូវស្ទូង —៧០

វិធីបញ្ចូលទឹក
ក្នុងស្រែ ទំព័រ ៧១
រដូវច្រូតស្រូវ –៧២
ចម្រូតស្រូវ –៧៤
ពាណិជ្ជកម្ម ៧៥
អាទិលនិងអាខ្វច –៧៦
ក្អែក ១ ផា
ក្អែក ១០ ៧៨
ផ្សារនៅជនបទ ៨០
ម៉ាស៊ីនកិនស្រូវ —៨១
វិធីកិនស្រូវ –៨៣
មាតុភូមិខ្មែរ –៨៤
សន្ដានចិត្តខ្មែរ –៨៥
ព្រះពុទ្ធសាសនា – ៨៧
ពុទ្ធចក្រ និង
អាណាចក្រ —៨៨
រដ្ឋាភិបាល និង
ព្រះពុទ្ធសាសនា —៨៩
ពុទ្ធសាសនុប្បត្តិ –៩០
ពិធីសម្ពោធព្រះ
ត្រៃបិដក –៩១

បុព្វហេតុនៃបុណ្យសម្ពោធ
ព្រះត្រៃបិដក ទំព័រ ៩២
ក្រុមជំនុំព្រះ
ត្រៃបិដក –៩៤
ផលប្រយោជន៍
ព្រះត្រៃបិដក –៩៥
ន័យនៃព្រះត្រៃបិដក –៩៦
បច្ឆិមពុទ្ធវចនៈ –៩៧
បច្ឆិមពុទ្ធវចនៈ(ត) –៩៩
ឃុំវជននិងព្រះ
ត្រៃបិដក –១០០
គ្រូបាអាចារ្យ និង
សិស្ស –១០១
សង្គហធម៌ –១០២
សួស្ដីនិងអព
មង្គល –១០៣
អច្ឆរិយាភិ
និក្ខមណ៍ –១០៥
ទុក្ករកិរិយា –១០៦
ពុទ្ធបូជា –១០៧
ចិត្តភក្ដី –១០៨


www.budinst.gov.kh www.elibraryofcambodia.org

# អំពីវត្ត

● វត្ត ជាលំនៅនៃបព្វជិត អ្នកប្រព្រឹត្តកុសលធម៌ ដើម្បីចេញចាកកាម និងដើម្បីសិក្សាអប់រំបន្ទុំកាយ ឲ្យឆ្ងាយចាកអវិជ្ជា ។

វត្ត សំដៅយកទីអារាមទាំងមូល ដែលមានព្រះវិហារកុដិ ឧបដ្ឋានសាលា សាលាពុទ្ធិកបឋមសិក្សា សាលាបឋមសិក្សា ហោត្រៃយ ចេតិយ ឈាបនដ្ឋាន វច្ចកុដិ តាំងនៅច្រងច្រាង តម្រៀបគ្នាជាជួរ គួរជាទីជ្រះថ្លា ។ ក្រៅពីនោះមានសួនច្បារលាយចម្រុះដោយបុប្ផជាតិផ្សេង ។ មានដើមរុក្ខជាតិធំ ។ បែកមែកសាខាប្រកបដោយម្លប់ត្រឈឹងត្រឈៃស៊ុមទ្រុម គួរជារមណីយដ្ឋាន ដល់ឧបាសកឧបាសិកា ដែលមានប្រាថ្នាសាងសីលទាន ដើម្បីជាសម្បត្តិទៅកាន់បរលោក ។

## សំណួរ

១– ចូរពន្យល់ពាក្យ : វត្ត បព្វជិត កុសលធម៌ អវិជ្ជា សាលាពុទ្ធិកបឋមសិក្សា ត្រឈឹងត្រឈៃ ។

២– ចូរតែងឃ្លាជាមួយនឹងពាក្យ : ព្រះវិហារ កុដិ ផ្សេង ។ ប្រាថ្នា បរលោក ។

៣— វត្តលោកនៅក្នុងសង្កាត់- ស្រុក - ខេត្តណា ? មានកុដិប៉ុន្មានខ្នង ? លោកគ្រូចៅអធិការព្រះនាមអ្វី ? គ្រូបង្រៀនលោកព្រះនាមអ្វី ?

៤— សាលាពុទ្ធិកបឋមសិក្សា ដែលលោកស្នាក់សិក្សា នៅក្នុងសង្កាត់ ស្រុក ខេត្តណា ?



www.budinst.gov.kh www.elibraryofcambodia.org

# វត្តឧណ្ណាលោម

● វត្តឧណ្ណាលោម ជាវត្តមួយធំជាងគេក្នុងកម្ពុជរដ្ឋ នាបច្ចុប្បន្ន-សម័យ ។ នៅទិសខាងកើត មានទន្លេចតុមុខ ដែលមានផារទឹកធំល្វឹងល្វើយ, ទិសខាងត្បូង មានវាលព្រះមេរុនិងនិវេសន៍វាំង គួរជាទីស្ងប់ស្ងែង នៃទស្សនិកជនទាំងឡាយ, ទិសខាងលិច មានពន្ធនាគារជាទីស្ងប់ស្ងៀម, ទិសខាងជើង មានផ្សារមួយ ហៅថា ផ្សារកណ្តាល ។

នៅក្នុងអារាសនោះ មានព្រះវិហារមួយធំ កំពូលដូចប្រាសាទបុរាណខ្ពស់ស្កឹមស្កៃ, មហាកុដិជិតនោះ មានកំពូលប្រដាប់ដោយផហ្វាផងក្តារ, មានឈាបនដ្ឋានមួយធំ ស្ថិតនៅទិសពាយព្យនៃមហាកុដិ, នៅទិសឧត្តរនៃមហាកុដិមានចេតិយមួយធំ ដែលរដ្ឋាភិបាលនិងពុទ្ធបរិស័ទសាងឡើង សម្រាប់តម្កល់ព្រះអដ្ឋិធាតុ ព្រះសង្ឃរាជ ឬ ព្រះសង្ឃនាយក ។ ក្រៅពីនោះ មានកុដិជាច្រើនស្ថាបនាដោយឥដ្ឋនិងស៊ីម៉ង់ត៍ស្ទើរតែទាំងអស់ ។ ក្នុងកុដិនីមួយ ៗ មានវត្ថុកុដិបរិបូណ៌ដោយអនាម័យដ៏ល្អ ។ គួរជាទីជ្រះថ្លា ។

## សំណួរ

១– ចូរពន្យល់ពាក្យ: កម្ពុជរដ្ឋ បច្ចុប្បន្នសម័យ ពន្ធនាគារ ផ្សារ ខ្ពស់ស្កឹមស្កៃ។

២– ចូរតែងឃ្លាជាមួយនឹងពាក្យ : ទិស ទស្សនិកជន ឈាបនដ្ឋាន ទន្លេចតុមុខ សាង អនាម័យ ។

៣– ចូររកវេវចនសព្ទនឹងពាក្យ : អារាម អាគារ ។

៤-វត្តឧណ្ណាលោមតាំងនៅឯណា? ក្នុងវត្តនោះមានអ្វីខ្លះ? វត្ថុកុដិ ស្ថិតនៅត្រង់ណា?



www.budinst.gov.kh www.elibraryofcambodia.org

# សិទ្ធត្ថកុមារ

● សិទ្ធត្ថកុមារ ជារាជបុត្រនៃព្រះបាទសុទ្ធោទន៍និងព្រះនាងសិរីមហាមាយា សោយរាជ្យនៅក្រុងកបិលពស្ដុ ។ ព្រះរាជកុមារអង្គនេះ ទ្រង់ប្រសូតនៅថ្ងៃពេញបូណ៌មី ខែពិសាខ ឆ្នាំច មុនពុទ្ធសករាជ ៨០ ឆ្នាំ ក្រោមដើមសាលព្រឹក្សក្នុងលុម្ពិនីវ័នឧទ្យាន ត្រង់ចន្លោះនគរកបិលពស្ដុនិងនគរទេវទហៈ ។ ព្រះរាជកុមារ បានទទួលមង្គលាភិសេក ជាមួយនឹងនាងពិម្ពាយសោធរា ក្នុងព្រះជន្ម ១៦ វស្សា ។ ព្រះវរបិតា បានឲ្យសោយរាជ្យសួងព្រះអង្គយ៉ាងសុខសាន្ត តែព្រះអង្គពុំត្រេកអរក្នុងសិរីរាជសម្បត្តិទេ ទ្រង់បែរជាចេញទៅសាងបព្វជ្ជា តាមពុទ្ធប្បវេណីវិញ ។ ក្រោយពីបានបំពេញទុក្ករកិច្ច អស់ប្រាំមួយព្រះវស្សាគត់ ទ្រង់កម្ចាត់បង់រាគាទិក្កិលេស បានត្រាស់ដឹង នូវអនុត្តរសម្មាសម្ពោធិញ្ញាណ មានព្រះនាមប្រាកដថាព្រះពុទ្ធ ។

## សំណួរ

១— **ចូរពន្យល់ពាក្យៈ** សោយរាជ្យ ប្រសូត ឧទ្យាន ព្រះជន្ម ទុក្ករកិច្ច ។

២— **ចូរតែងឃ្លានឹងពាក្យៈ** សិទ្ធត្ថកុមារ ក្រុងកបិលពស្ដុ ព្រះវរបិតា បព្វជ្ជា រាគាទិក្កិលេស ។

៣— ព្រះពុទ្ធយើងនេះ ប្រសូត្រនៅថ្ងៃ ខែ ឆ្នាំអ្វី? កាលនៅជាកុមារមានព្រះនាមដូចម្ដេច ? មាតាបិតាព្រះនាមអ្វី ? ទ្រង់ចេញទៅសាងផ្នួសក្នុងព្រះជន្មប៉ុន្មាន ? បានត្រាស់នៅឆ្នាំណា ? កន្លែងណា ? ព្រះជន្មប៉ុន្មាន ? បរិនិព្វាន នៅថ្ងៃខែឆ្នាំអ្វី ? កន្លែងណា ?

៤— ចូររៀបរាប់ដោយមាត់ទទេ នូវប្រវត្តិព្រះពុទ្ធ តាមអត្ថបទនេះ ។



www.budinst.gov.kh www.elibraryofcambodia.org

# ព្រះពុទ្ធវិន័យ

● ព្រះសម្មាសម្ពុទ្ធ ទ្រង់បានត្រាស់ដឹង នៅប្រទេសឥណ្ឌា ក្នុងជន្មាយុសាមសិបប្រាំព្រះវស្សា ។ ព្រះភគវន្តមុនីអង្គនេះ បានប្រកាសសាសនា អស់រយៈកាល សែសិបប្រាំឆ្នាំគត់ ។ ទ្រង់បានអប់រំសត្វលោក ឲ្យស្គាល់លក្ខណៈច្បាប់របស់ខ្លួន ដោយមាត្រាក្រឹត្យក្រម ដែលហៅថាវិន័យ ។ វិន័យជាខ្សែបន្ទាត់សម្រាប់តម្រង់មនុស្ស ដែលរស់នៅក្នុងសង្គម ឲ្យបានប្រកបដោយសុខសាន្តត្រាណ មានសាមគ្គីរាប់រកគ្នី ។ វិន័យនោះ ចែកចេញជាពីរយ៉ាង គឺអាគារិយវិន័យ វិន័យសម្រាប់គ្រហស្ថ ; អនាគារិយវិន័យ វិន័យសម្រាប់បព្វជិត ក្នុងព្រះពុទ្ធសាសនា ។

## សំណួរ

១– ចូរពន្យល់ពាក្យៈ ត្រាស់ដឹង សាសនា អប់រំ វិន័យ សុខសាន្ត ។

២– ចូរតែងឃ្លានឹងពាក្យៈ ព្រះជន្មាយុ សត្វលោកវិន័យ សាមគ្គី គ្រហស្ថ ។

៣– វិន័យ ជាអ្វី ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ? បើពុំមានវិន័យទេ តើលោកនឹងទៅជាអ្វី ? ចូរពន្យល់ឲ្យច្បាស់លាស់ ។

៤– ចូរតែងអត្ថបទថ្មីមួយទៀត ឲ្យបានប្រាំបន្ទាត់ និយាយអំពីព្រះពុទ្ធវិន័យ ។



www.budinst.gov.kh www.elibraryofcambodia.org

# អាគារិយវិន័យ

● វិន័យ ឬ ច្បាប់ ដែលសម្រាប់អប់រំគ្រហស្ថ អ្នកគ្រប់គ្រងផ្ទះ ហៅថា អាគារិយវិន័យ ។ អាគារិយវិន័យនេះ សំដៅយក ការលះបង់អកុសលកម្មបថ ១០ គឺកាយកម្ម ៣: បាណាតិបាត បំបាត់ជីវិតអ្នកដទៃ, អទិន្នាទាន ការលួចទ្រព្យអ្នកដទៃ, កាមេសុមិច្ឆាចារ ការប្រព្រឹត្តខុសក្នុងកាម; វចីកម្ម ៤ : មុសា ការកុហក, បិសុណាវាចា ការនិយាយញុះញង់គេ, ផរុសវាចា ការនិយាយចាក់ដោតគេ, សម្ផប្បលាប: ការនិយាយពិកិច្ចការឥតប្រយោជន៍, មនោកម្ម ៣: អភិជ្ឈា ការរំពៃទ្រព្យអ្នកដទៃ ព្យាបាទ, ការចងគំនុំគុំគួនអ្នកដទៃ, មិច្ឆាទិដ្ឋិ ការយល់ខុស ។

## សំណួរ

១– ចូរពន្យល់ពាក្យ: អាគារិយវិន័យ អកុសលកម្មបថ ញុះញង់ ប្រយោជន៍ ការរំពៃ ។

២– វិន័យ និងអាគារិយវិន័យ ប្លែកគ្នាយ៉ាងណា ? ចូរពន្យល់ ។

៣– អកុសលកម្មបថ ១០ តើអ្វីខ្លះ ? ចូររាប់ឬសរសេរឡើងឲ្យគ្រប់ ។

៤– ចូរពន្យល់អំពីអាគារិយវិន័យ ។



www.budinst.gov.kh www.elibraryofcambodia.org

# អនាគារិយវិន័យ

● អនាគារិយវិន័យ ជាវិន័យសម្រាប់អ្នកបួសក្នុងព្រះពុទ្ធសាសនា ។ តាមពុទ្ធវិន័យ អ្នកបួសចែកចេញជាពីរប្រភេទ គឺសាមណេរនិងភិក្ខុ ។ បព្វជិតទាំងពីរនេះ មានវិន័យផ្សេង ៗ គ្នា ។ វិន័យសម្រាប់សាមណេរមាន៣០ គឺ សិល ១០ ទណ្ឌកម្ម ១០ និងនាសនង្គ : ១០ រួមជាមួយនឹងសេក្ខិយវត្ត ៧៥ ព្រមទាំងអាទិលោកវជ្ជសិក្ខាបទ និងវត្តខន្ធកទៀតផង ។ វិន័យសម្រាប់ភិក្ខុមាន ៤ ដែលហៅថាសីល ៤ គឺ : បាតិមោក្ខសំវរសីល សីលគឺការសង្រួមក្នុងបាតិមោក្ខ, ឥន្ទ្រិយសំវរសីល សីលគឺការសង្រួមឥន្ទ្រិយទាំងប្រាំមួយ , បច្ចយសន្និស្សិតសីល សីលគឺការពិចារណាប្រើប្រាស់នូវបច្ច័យ ៤, អាជីវបារិសុទ្ធិសីល សីលគឺសេចក្តីបរិសុទ្ធិនៃអាជីវៈ ។

## សំណួរ

១— ចូរពន្យល់ពាក្យ: អនាគារិយវិន័យ ពុទ្ធវិន័យ ទណ្ឌកម្ម សំវរសីល បច្ច័យ ។

២— ចូរតែងឃ្លាជាមួយនឹងពាក្យ: សាមណេរ ភិក្ខុ សីល ប្រើប្រាស់ អាជីវៈ ។

៣— អាគារិយវិន័យ និងអនាគារិយវិន័យ ប្លែកគ្នាយ៉ាងណា ? ចូរពន្យល់ ។

៤— វិន័យរបស់សាមណេរ មានប៉ុន្មានយ៉ាង ? ភិក្ខុមានសីលប៉ុន្មាន ? អ្វីខ្លះ ? ចូររាប់ ។ ឥន្ទ្រិយ ៦ អ្វីខ្លះ ?



www.budinst.gov.kh www.elibraryofcambodia.org

## សាមណេរ សន

●រៀងរាល់ព្រឹក សាមណេរ សន ក្រោកពីព្រលឹមស្រាង ៗ លុបមុខស្អាតស្អំ ចូលក្នុងសំណិង ពិចារណាអតីតប្បច្ចវេក្ខណៈ ជាក់ច្បាស់ក្នុងខ្លួន តពីនោះនេន សន ចាប់យកសៀវភៅមេរៀនទាំងឡាយ ដែលត្រូវសិក្សាព្រឹកនោះមកទន្ទេញ ។ ព្រះសុរិយាបញ្ចេញរស្មីច្បាស់, នេន សន ក៏បោសច្រាសលើកុដិក្រោមកុដិ ព្រមទាំងទីវាលក្នុងអារាសវត្ត ដែលស្ថិតនៅជិត ៗ កុដិរបស់លោក ជរាបដល់ស្អាតអស់ ។ ក្រោយពីឆាន់ចង្ហាន់ព្រឹករួចហើយ, ស្គរជួង ប៊ុង ! ប៊ុង ! សាមណេរ សន រៀបដំណើរឥតរួញរា ប្រញាប់ប្រញាល់ដើរតម្រង់ទៅកាន់ថ្នាក់សិក្សាជាបន្ទាន់ ។

លោកគ្រូបង្រៀន. និងលោកគ្រូចៅអធិការ ពេញចិត្តណាស់ ព្រោះនេន សន ជាសិស្សពូកែ ហើយឧស្សាហ៍ខ្មីឃ្មាត យកចិត្តទុកដាក់ក្នុងឧបជ្ឈាយវត្ត , អាចរិយវត្ត និងសម្អាតលំនៅផង ។

### សំណួរ

១— ចូរពន្យល់ពាក្យ : ក្រោក ស្អាតស្អំ អតីតបច្ចវេក្ខណៈ ការសិក្សា ។

២- ចូរតែងឃ្លាជាមួយនឹងពាក្យ : ពិចារណា សៀវភៅ ប្រញាប់ប្រញាល ចិត្ត ឧស្សាហ៍ ។

៣- ចូររកវេវចនសព្ទនឹងពាក្យ : ព្រះសុរិយា រស្មី ។

៤- ចូររៀបរាប់ពីការប្រព្រឹត្ត របស់សាមណេរ សន ចំពោះលោកគ្រូចៅអធិការ និងគ្រូបង្រៀនរបស់ខ្លួន ។



www.budinst.gov.kh www.elibraryofcambodia.org

## បព្វជិត

● ពាក្យថាបព្វជិត មានន័យថា លោកអ្នកដែលនៀយណាយក្នុងកាមគុណ ឬលោកអ្នកដែលចេញចាកគិហិភាព ចូលទៅកាន់បព្វជិតភាព ។ បព្វជិតនេះ បើប្រែឲ្យងាយយល់ គឺបានដល់ពាក្យសាមញ្ញថាអ្នកបួស ។ អ្នកបួសក្នុងពុទ្ធសាសនា នាបច្ចុប្បន្ននេះ សំដៅយកសាមណេរនិងភិក្ខុប៉ុណ្ណោះ, ក៏ប៉ុន្តែក្នុងពុទ្ធសម័យ សំដៅយកទាំងភិក្ខុ, ភិក្ខុនី, សិក្ខមានា, សាមណេរ និងសាមណេរីផង ។

● អ្នកបួសទាំងអស់នេះ ហៅថាបព្វជិតក្នុងពុទ្ធសាសនា ។

### សំណួរ

១— **ចូរពន្យល់ពាក្យ** : បព្វជិត កាមគុណ គិហិភាព សាមញ្ញ សិក្ខាមានា ។

២— **ចូរតែងឃ្លានឹងពាក្យ** : ន័យ ចូលទៅ បព្វជិតភាព សាមណេរី ពុទ្ធសម័យ ។

៣— **ចូររកសទិសសព្ទនឹងពាក្យ** : អ្នក ក៏ ។

៤— សមណៈ និង បព្វជិត មានន័យដៀងគ្នាយ៉ាងណា? ចូរពន្យល់ ។



www.budinst.gov.kh www.elibraryofcambodia.org

# ចៅអធិការ

● ចៅអធិការ កើតឡើងដោយការបោះឆ្នោត ពីសំណាក់ភិក្ខុសាមណេរគ្រប់រូប ដែលនៅក្នុងវត្ត, ភិក្ខុដែលត្រូវចាត់តាំងឲ្យឈរឈ្មោះបោះឆ្នោតនោះ ត្រូវមានចំណាស់ផ្នួសយ៉ាងតិចត្រឹមប្រាំវស្សា ព្រមទាំងមានគុណសម្បត្តិ និងសមត្ថភាពគ្រប់គ្រាន់ផង ។ ក្នុងពេលបោះឆ្នោត ត្រូវមានមន្ត្រីសង្ឃពីសាលាអនុគណ និងមន្ត្រីអាណាចក្រ មានមន្ត្រីសាលាសង្កាត់ សាលាស្រុក ឬសាលាក្រុង មកសង្កេតពិនិត្យពិធីបោះឆ្នោតនោះ ។ ភិក្ខុសាមណេរក្នុងវត្ត ត្រូវជ្រើសយកភិក្ខុបីអង្គ គឺភិក្ខុដែលបានទទួលឆ្នោតច្រើនជាងគេ ត្រូវបានតំណែងជាចៅអធិការ, ភិក្ខុដែលបានឆ្នោតជាបន្ទាប់ ត្រូវបានតំណែងជាគ្រូសូត្រស្តាំ ហៅថា ចៅអធិការរងទីមួយ, ភិក្ខុក្រោយនេះ ត្រូវបានតំណែងជាគ្រូសូត្រឆ្វេង គឺចៅអធិការរងទីពីរ ។

## សំណួរ

១– ចូរពន្យល់ពាក្យ : ចៅអធិការ ភិក្ខុ វស្សា មន្ត្រីសង្ឃ គ្រូសូត្រ ។

២– ចូរតែងឃ្លាជាមួយនឹងពាក្យ : គុណសម្បត្តិ សាលាគណ ពិនិត្យ ទទួល ។

៣– ភិក្ខុដែលមានលក្ខណសម្បត្តិយ៉ាងណាខ្លះទើបអាចធ្វើជាចៅអធិការបាន? ចៅអធិការនិងឧបជ្ឈាយ៍មានលក្ខណៈប្លែកគ្នាដូចម្តេចខ្លះ?ចូរពន្យល់ឲ្យច្បាស់លាស់។

៤– ចូរពន្យល់អត្ថបទខាងលើនេះ ដោយគំនិតផ្ទាល់ ។



www.budinst.gov.kh www.elibraryofcambodia.org

## នាទីចៅអធិការ

● ចៅអធិការ មាននាទីគ្រប់គ្រងភិក្ខុសាមណេរទាំងអស់ ក្នុងអាវាសវត្ត ។ ចៅអធិការ ត្រូវមានមន្ត្រីសង្ឃពីររូបទៀត ជួយគ្រប់គ្រងវត្តអារាម គឺគ្រូសូត្រស្តាំ និងគ្រូសូត្រឆ្វេង ។ ទាំងបីអង្គនេះ ត្រូវបានទទួលតែងតាំងដោយប្រកាសនីយបត្រ ពីសម្តេចព្រះសង្ឃរាជ ឬ ព្រះសង្ឃនាយក ដែលមានរដ្ឋមន្ត្រីក្រសួងធម្មការ ទទួលស្គាល់តាមផ្លូវការ ខាងអាណាចក្រផង ។ ក្រោយដែលបានតែងតាំងតាមផ្លូវការរួចហើយ មន្ត្រីសង្ឃទាំងបីអង្គនេះ មានភារៈដឹកនាំកិច្ចការសង្ឃ ឲ្យមានប្រព្រឹត្តទៅស្រួលល្អ, រំងាប់អធិករណ៍ផ្សេង ៗ ដែលកើតឡើងក្នុងវត្ត ដោយមានទំនាក់ទំនង ជាមួយគណៈសង្ឃសាលាអនុគណ ។

### សំណួរ

១– ចូរពន្យល់ពាក្យ : នាទី ប្រកាសនីយបត្រ សម្តេចព្រះសង្ឃរាជ សង្ឃនាយក ក្រសួងធម្មការ កិច្ចការព្រះសង្ឃ ។

២– ចូរតែងឃ្លាជាមួយនឹងពាក្យ : ផ្លូវការ ដឹកនាំ ប្រព្រឹត្ត អធិករណ៍ គណៈសង្ឃ ។

៣– អំណាចនិងនាទី ប្លែកគ្នាយ៉ាងណា ? ចូរពន្យល់ ។

៤– ចៅអធិការមាននាទីដូចម្តេចខ្លះ ? ចូររៀបរាប់ដោយគំនិតផ្ទាល់ ។



www.budinst.gov.kh www.elibraryofcambodia.org

## អនុគណ

ចៅអធិការគ្រប់វត្ត ក្នុងស្រុកនីមួយៗ ត្រូវប្រជុំគ្នាជ្រើសរើសនូវចៅអធិការមួយរូប ដែលមានសមត្ថភាពគ្រប់គ្រាន់ ហើយដែលមានអាវាសមិនឆ្ងាយពីសាលាស្រុក ឲ្យទទួលនាទីជាអនុគណ ។

● អនុគណ ត្រូវជ្រើសដោយវិធីបោះឆ្នោត ពីចៅអធិការ គ្រប់វត្តក្នុងស្រុក ហើយមានភិក្ខុបីរូបទៀត ជួយធ្វើការផងគឺ :

វិន័យធរអនុគណ លោកអ្នកស្ទាត់ជំនាញខាងវិន័យ

សមុហ៍អនុគណ លោកអ្នកកាន់បញ្ជីនិងឯកសារ

និងអនុលេខាធិការអនុគណ លេខាធិការរង ។

មន្ត្រីសង្ឃប្រចាំសាលាអនុគណទាំងបួនរូបខាងលើនេះ ត្រូវបានតែងតាំងឡើង ដោយប្រកាសនីយបត្រ ដូចចៅអធិការដែរ ។ ចំណែកអនុគណ មានសមណសក្តិ ឋានានុក្រម ទីជាព្រះគ្រូផង ។

## សំណួរ

១— ចូរពន្យល់ពាក្យ : អនុគណ សមត្ថភាព សាលាស្រុក វិន័យធរ សមុហ៍ លេខាធិការ ។

២— ចូរតែងឃ្លាជាមួយនឹងពាក្យ : ប្រជុំ ធ្វើការ អនុលេខាធិការ សមណសក្តិ ។

៣— ចូររកសទិសសព្ទនឹងពាក្យ : ការ សង្ឃ ។

៤— ចូរពន្យល់ន័យនៃអត្ថបទ និងប្រយោជន៍នៃការសិក្សាអត្ថបទនេះ ។



www.budinst.gov.kh www.elibraryofcambodia.org

## នាទីអនុគណ

● អនុគណ មាននាទីគ្រប់គ្រងត្រួតត្រាលើចៅអធិការគ្រប់វត្ត ក្នុងស្រុករបស់ខ្លួន ។ បើមានអធិករណ៍កើតឡើងក្នុងវត្តណាមួយ គណៈសង្ឃមានចៅអធិការជាដើម រំងាប់មិនបាត់ស្ងាត់ទេ ត្រូវបញ្ជូនសំណុំរឿងអធិករណ៍នោះ ទៅគណៈសង្ឃទី ២ គឺសាលាអនុគណ ។ បើគណៈសង្ឃសាលាអនុគណ សម្រុះសម្រួល ឬវិនិច្ឆ័យរំងាប់ ហើយអធិករណ៍នោះស្ងប់រំងាប់បានជាការល្អ បើមិនស្ងប់ទេ ត្រូវបញ្ជូនសំណុំរឿងនោះ ទៅគណៈសង្ឃទី ៣ គឺសាលាគណ ដែលមានមេគណ ជាប្រធាន ។

● ព្រះគ្រូអនុគណគ្រប់ស្រុក មាននាទីប្រជុំចៅអធិការគ្រប់វត្តក្នុងស្រុកកំណត់ប្រាំមួយខែម្តង ដើម្បីរំលឹកចៅអធិការគ្រប់រូប តាមបញ្ញត្តិ ឬសង្ឃប្រកាសនៃសម្តេចព្រះសង្ឃរាជ , ព្រះសង្ឃនាយក , ក្រសួងធម្មការ ឬ សេចក្តីសម្រេចរបស់អនុសំវច្ឆរមហាសន្និបាត ដែលមានរៀងរាល់ឆ្នាំ នៅក្រុងភ្នំពេញ ឬ ក៏ពិគ្រោះផ្ទាល់នឹងចៅអធិការគ្រប់វត្ត ដើម្បីរាវរកសេចក្តីចម្រើនខាងព្រះពុទ្ធសាសនា ។

### សំណួរ

១- ចូរពន្យល់ពាក្យ៖ ត្រួតត្រា អធិករណ៍ គណៈសង្ឃ វិនិច្ឆ័យ បញ្ញត្តិ ។

២-ចូរតែងឃ្លាជាមួយនឹងពាក្យ:រំងាប់ សំណុំរឿង កំណត់ ព្រះសង្ឃនាយក,

៣— ចូរធ្វើនិងប្រែកិរិយាសព្ទទាំងនេះ ឱ្យទៅជានាមៈ

ប្រព្រឹត្ត, បញ្ចូត, ប្រសូត, ចង្រៃ, សន្មត, អនុម័ត ។

៤- ចូរពន្យល់អំពីនាទី អនុគណ ក្រោយពេលដែលបានអានអត្ថបទនេះរួច ។



www.budinst.gov.kh www.elibraryofcambodia.org

## មេគណ

●ក្នុងខេត្តនីមួយ ៗ កាលបើមានអនុគណគ្រប់ស្រុកហើយ ។ អនុគណទាំងអស់ ត្រូវប្រជុំគ្នាបោះឆ្នោតជាផ្លូវការ ដើម្បីជ្រើសតាំងអនុគណមួយរូប ដែលមានសមត្ថភាពជាងគេ ហើយដែលមានអាវាស ស្ថិតនៅក្នុងក្រុងជិតសាលាខេត្ត ឲ្យធ្វើជាមេគណ ។

មេគណ ត្រូវជ្រើសរើសភិក្ខុបួនរូបទៀតឲ្យជួយធ្វើការ គឺបាឡាត់គណ ( មេគណរង ) វិន័យធរគណ គឺអ្នកស្ទាត់ជំនាញខាងវិន័យ, សមុហ៍គណ គឺអ្នកកាន់បញ្ជីនិងឯកសារ, លេខាធិការគណ គឺស្មៀនគណ ។

មន្ត្រីសង្ឃសាលាគណទាំងប្រាំរូបនេះ ត្រូវតែងតាំងឡើងដោយប្រកាសនីយបត្រ ដូចមន្ត្រីសង្ឃសាលាអនុគណដែរ ហើយមានសមណសក្តិឋានានុក្រមដំបូងទីជាព្រះគ្រូ ។ តខាងក្រោយមក មេគណ កាលបើមានការស្នើសុំអំពីលោកអ្នកឧកញ៉ា អភិបាលខេត្ត ក៏អាចឡើងឋានន្តរ ទីជាសមណសក្តិបាន ។

### សំណួរ

១– ចូរពន្យល់ពាក្យ: មេគណ សាលាខេត្ត បញ្ជី ឯកសារ ឋានានុក្រម។

២– ចូរតែងឃ្លាជាមួយនឹងពាក្យ: មេគណ ជ្រើសតាំង ស្ថិតនៅ បាឡាត់គណ សមុហ៍គណ ។

៣– ចូរពន្យល់របៀបប្រើ យុគលពិន្ទុ និងវិសជ្ជនី ( ះមុខ ) ។

៤– ចូរពន្យល់ន័យនៃអត្ថបទខាងលើនេះ ។



www.budinst.gov.kh www.elibraryofcambodia.org

## នាទីមេគណ

● មេគណ មានទាទីស្នើសូមតាមផ្លូវការ ចំពោះសម្តេចព្រះសង្ឃរាជ ឬព្រះសង្ឃនាយកនូវតំណែងតាំងព្រះថេរៈមួយរូប ពីររូប ឬច្រើនរូប ឲ្យមានសមណៈ-សក្តិជាទីព្រះគ្រូ ដើម្បីជួយបំពេញកិច្ចការរបស់លោក នៅសាលាគណ ។ សាលាគណ ជាគណៈសង្ឃទី ៣ មាននាទីជំនុំជម្រះ និងសម្រេចសេចក្តីនៃអធិករណ៍ដែលគណៈសង្ឃទី ២ គឺសាលាអនុគណពុំអាចរំងាប់បាន ។ បើអធិករណ៍នោះ មិនព្រមស្ងប់ទេ សាលាគណត្រូវបញ្ជូនសំណុំរឿង ទៅគណៈសង្ឃទី ៤ គឺក្រសួងព្រះសង្ឃរាជ ឬព្រះសង្ឃនាយក, បើសម្តេចព្រះសង្ឃរាជ ឬព្រះសង្ឃនាយក ជំនុំជម្រះអធិករណ៍នោះស្ងប់បានជាការល្អ បើមិនស្ងប់ទេ ត្រូវបញ្ជូនសំណុំរឿងនោះ ទៅគណៈសង្ឃទី៥ គឺថេរសភាជាន់ខ្ពស់ ។

### សំណួរ

១– **ចូរពន្យល់ពាក្យ** : ស្នើសូម តំណែងតាំង ព្រះថេរៈ ទីព្រះគ្រូ ។

២– **ចូរពន្យល់ន័យ**: សម្តេចព្រះសង្ឃរាជ និង ព្រះសង្ឃនាយក ប្លែកគ្នាយ៉ាងណា ?

៣ – **ចូរពន្យល់ឧត្តមគតិអត្ថបទ** : នាទីមេគណ ។

៤– ចូររាប់ព្រះនាម នៃសម្តេចព្រះសង្ឃរាជ និងព្រះសង្ឃនាយក តាំងពីអតីតកាលទល់នឹងបច្ចុប្បន្នកាលនេះ ។



www.budinst.gov.kh www.elibraryofcambodia.org

## ថេរសភា

សំណុំរឿងអធិករណ៍ ដែលសាលាគណបញ្ជូនតាមរយៈ ទៅក្រសួងព្រះសង្ឃរាជ ឬព្រះសង្ឃនាយក ។ កាលបើសម្ដេចព្រះសង្ឃរាជ ឬព្រះសង្ឃនាយកទ្រង់វិនិច្ឆ័យហើយ អធិករណ៍នោះអាចរំងាប់បាន នេះជាការល្អ បើមិនស្ងប់ទេត្រូវបញ្ជូនទៅគណៈសង្ឃ ទី ៥ គឺថេរសភា ។ បើគណៈសង្ឃថេរសភា ជំនុំជម្រះត្រឹមត្រូវតាមធម៌ ហើយដោយមានសម្ដេចព្រះសង្ឃរាជ ឬសម្ដេចព្រះសង្ឃនាយកយល់ព្រមផងនោះ ទុកជាចប់ស្រេចត្រឹមប៉ុណ្ណេះ នឹងឧទ្ធរណ៍ឬតវ៉ាយ៉ាងណាពុំបានឡើយ ។ គណៈសង្ឃទី៥ នេះមានសមាជិកជាគណៈសង្ឃមន្ត្រីថ្នាក់ផេ្សងៗ ចំនួនប្រាំបួនរូប មានលេខាធិការ និងអនុលេខាធិការ ទីជាមន្ត្រីសង្ឃឬបានានុក្រមរួមទាំងប្រធានមួយរូបផង ត្រូវជាដប់ពីររូប ។ សមាជិក ថេរសភាទាំងអស់ រួមទាំងអធិបតីផង ត្រូវតែងតាំងឡើងដោយក្រឹត្យ មាននាទីកាត់សេចក្ដីផាច់ណាត់ស្មើនឹងសាលាវិនិច្ឆ័យជាន់ខ្ពស់ ខាងអាណាចក្រដែរ ។

### សំណួរ

១– **ចូរពន្យល់ពាក្យ** : ថេរសភា ក្រសួង ជំនុំជម្រះ តាមធម៌ ឧទ្ធរណ៍ អធិការ ។

២– **ចូរតែងឃ្លាជាមួយនឹងពាក្យ** : តាមរយៈ ប្រធាន សមាជិក ក្រឹត្យ។

៣– **ថេរសភា** តាំងនៅឯណា ? លោកអ្នកដែលធំជាងគេ មាននាមជាអ្វី ? មានសមាជិកប៉ុន្មានរូប ?

៤– ចូររៀបរាប់សកម្មភាព និងអំណាចថេរសភា ។



www.budinst.gov.kh www.elibraryofcambodia.org

# ឧបាសក-ឧបាសិកា

ឧបាសក សំដៅយកអ្នកដែលចូលទៅអង្គុយជិតព្រះរតនត្រ័យ គឺអ្នកដែលប្រណិតប្រណី បម្រើបម្រាស់ គោរពរាប់អាន បូជាព្រះរតនត្រ័យ ។ តាមន័យក្នុងព្រះពុទ្ធសាសនា សំដៅយកអ្នកដល់នូវព្រះរតនត្រ័យជាទីពឹងទីរលឹក គឺគ្រហស្ថដែលចូលកាន់ព្រះពុទ្ធសាសនាសិប់សួន កាន់សីលធម៌ខ្ជាប់ខ្ជួន តាមក្រមច្បាប់នៃពុទ្ធសាសនិកជនជាគ្រហស្ថ ។ បើជាស្ត្រីវិញ គេហៅថាឧបាសិកា ។ ឧបាសកនិងឧបាសិកាទាំងពីរប្រភេទនេះ សុទ្ធតែពួកជនជាសប្បុរស មានសទ្ធាជ្រះថ្លាចិត្តចេះសន្តោសន្តោះទៅរកព្រះពុទ្ធសាសនា ជាអ្នកកាន់សីលឲ្យទានពុំមានក្តីរុញរា មានសាមគ្គីសមគ្គាបង្កើតសេចក្តីសុខ នៅក្នុងលោកនេះ និងលោកខាងមុខ ។

## សំណួរ

១– **ចូរពន្យល់ពាក្យ** : ឧបាសក ឧបាសិកា ព្រះរតនត្រ័យ សប្បុរស សាមគ្គី ។

២– **ចូរតែងឃ្លាជាមួយនឹងពាក្យ** : ឧបាសក គោរព សីលធម៌ សទ្ធាចិត្ត រួបរួម ។

៣– ចូរប្រាប់ពាក្យ ដែលជានាមនាម នៅក្នុងអត្ថបទនេះ , ហើយពាក្យណាខ្លះមាននាទីជាសមាសនាម ? ចូរឲ្យឧទាហរណ៍ ។

៤– **ចូរតែងអត្ថបទថ្មីមួយទៀត** ដោយស្តីពីរឿងឧបាសក ឧបាសិកា តែកុំយកឃ្លាទាំងស្រុងក្នុងអត្ថបទនេះ មកធ្វើជាអត្ថបទថ្មី ។



www.budinst.gov.kh www.elibraryofcambodia.org

# សមណសក្តិមន្ត្រីសឡថ្នាក់ចត្វា

## គណៈមហានិកាយ

១– ព្រះធម្មវិបស្សនា

២– ព្រះសម្មាធិធម្ម

៣– ព្រះញាណកោសល

៤– ព្រះសិរីសង្គ្រាមមុនី

៥– ព្រះសិរីវិសុទ្ធិ

៦– ព្រះធម្មវង្សា

៧– ព្រះញាណសំវរ

៨– ព្រះវិន័យសំវរ

៩– ព្រះឥន្ទមុនី

១០– ព្រះទេពមុនី

១១– ព្រះវិន័យមុនី

១២– ព្រះទេពសត្ថា

១៣– ព្រះសីលសំវរ

១៤– ព្រះគម្ពីរត្ថេរ

១៥– ព្រះអរិយមគ្គញាណ

១៦– ព្រះវិភទ្ធញាណ

១៧– ព្រះបវរសត្ថា

១៨– ព្រះញាណវិសុទ្ធិវង្ស

១៩– ព្រះធម្មវិសុទ្ធិវង្ស

២០– ព្រះបិដកធម្ម

## គណៈធម្មយុត្តិកនិកាយ

១– ព្រះបទុមវង្សា

២– ព្រះធម្មមុនី

៣– ព្រះវជិរមេធា

៤– ព្រះអរិយមុនី

៥– ព្រះទេពមាលី

៦– ព្រះធម្មត្ថេរ

៧- ព្រះអមរាភិរក្ខិត

៨- ព្រះមហារាជធម្ម

៩- ព្រះរតនមុនី

១០- ព្រះធម្មត្រ័យលោកាចារ្យ

១១- ព្រះធម្មវរោត្តម

១២- ព្រះញាណវីរិយះ



www.budinst.gov.kh www.elibraryofcambodia.org

# សមណសក្តិមន្ត្រីសង្ឃថ្នាក់ត្រី

## គុណៈមហានីកាយ

១- ព្រះសិរីសម្មតិវង្ស
២- ព្រះពុទ្ធវង្ស
៣- ព្រះសាក្យវង្ស
៤- ព្រះឧបាលិវង្ស
៥- ព្រះញាណវង្ស
៦- ព្រះសុមេធវង្ស

## គណៈធម្មយុត្តិកនិកាយ

១- ព្រះអរិយវង្ស
២- ព្រះធម្មកវីវង្សា
៣- ព្រះញាណវង្សី
៤- ព្រះមហាវីរវង្សាចារ្យ

# សមណសក្តិមន្ត្រីសង្ឃថ្នាក់ទោ

## គណៈមហានិកាយ

១- ព្រះមហាវិមលធម្ម
២- ព្រះពុទ្ធឃោសាចារ្យ
៣- ព្រះធម្មឃោសាចារ្យ
៤- ព្រះឃោសធម្ម
៥- ព្រះសាសនមុនី
៦- ព្រះមុនីកោសល

## គណៈធម្មយុត្តិកនិកាយ

១- ព្រះមហាព្រហ្មមុនី
២- ព្រះធម្មឧត្តម
៣- ព្រះអរិយកស្សប



www.budinst.gov.kh www.elibraryofcambodia.org

# សមណសក្តិមន្ត្រីសង្ឃថ្នាក់ឯក

## គណៈមហានិកាយ

១ – ព្រះធម្មលិខិត

២ – ព្រះពោធិវង្ស

៣ – ព្រះវនរ័ត

## គណៈធម្មយុត្តិកនិកាយ

១– ព្រះមង្គលទេពាចារ្យ

២ – ព្រះពុទ្ធាចារ្យ

# សមណសក្តិខ្ពស់ផុតលេខ

## គណៈមហានិកាយ

ព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ ឬព្រះសង្ឃនាយក

## គណៈធម្មយុត្តិកនិកាយ

ព្រះមហាសុធម្មាធិបតី ព្រះសង្ឃរាជ ឬព្រះសង្ឃនាយក



www.budinst.gov.kh www.elibraryofcambodia.org

# សមណបរិក្ខារ

● គ្រឿងប្រើប្រាស់ របស់បព្វជិត ក្នុងព្រះពុទ្ធសាសនាមានៈ ត្រៃចីវរ បរិក្ខាររាយរង និង បរិក្ខារពិសេស ។

ត្រៃចីវរ មានបី គឺ : ឧត្តរាសង្គៈ សំពត់សម្រាប់គ្រង ឬឃ្លុំបិទបាំងសរីរាង្គកាយ គេទម្លាប់ហៅថា ចីពរ, អន្តរវាសកៈ សំពត់សម្រាប់ស្លៀក គេទម្លាប់ហៅថាស្បង់, សង្ឃាដិ សំពត់សម្រាប់ក្រាលសិង ឬសម្រាប់ដណ្ដប់ ។

● បរិក្ខាររាយរង មាន អង្សក, បាត្រ, និសីទនៈ ធម្មក្រក, វត្តពន្ធទ្រូង វត្តពន្ធចង្កេះ កន្សែងជូតព្រះភក្ត្រ សំពត់ងូតទឹកភ្លៀង សំពត់ងូតទឹកធម្មតា, និងសំពត់ចំណាំវស្សា អច្ឆេកចីវរ ។ បរិក្ខារទាំងនេះ ពេលប្រើប្រាស់ ត្រូវធ្វើពិន្ទុកប្បនិងអធិដ្ឋាន ។

● បរិក្ខារពិសេស មាន សុពណ៌បាទ, ឆត្រ, ស្នោកបាត្រ, យោកបាត្រ, គម្របបាត្រ, កាំបិតកោរ, បំពង់ម្ជុល, និងថ្មសំលៀងកាំបិតកោរ ។

## សំណួរ

១- ចូរពន្យល់ពាក្យ : ពុទ្ធសាសនា ត្រៃចីវរ បរិក្ខារ វស្សា អធិដ្ឋាន ។

២- ចូរតែងឃ្លាជាមួយនឹងពាក្យ: ប្រើប្រាស់ ចីពរ ព្រះភក្ត្រ ធម្មតា ស្នោកបាត្រ ។

៣- ចូររកសទិសសព្ទនឹងពាក្យ: ប្រាស ។

៤— សមណបរិក្ខារ មានន័យដូចម្ដេច ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ? តើបរិក្ខាររាយរងមានអ្វីខ្លះ ? ចូររាប់តាមការនឹកឃើញ ។



www.budinst.gov.kh www.elibraryofcambodia.org

# រឿងសុទត្ត

● កាលពីព្រេងនាយ មានបុរសម្នាក់នាមជាក់ជាសុទត្ត ទីលំនៅ នៅនគរពារាណសី ។

● លោកនេះ មានសទ្ធាជ្រះថ្លា ចំណាយធនធាន ជួយសង្គ្រោះមនុស្សក្រីក្រទុគ៌តតោកយ៉ាកអនាថា ដោយឥតរើសមុខ មិនយូរប៉ុន្មាន សុទត្តបុរសត្រូវបានទទួលនាមថ្មីមួយទៀតថា អនាថបិណ្ឌិកសេដ្ឋី ។ ចំណេរក្រោយមក សេដ្ឋីនេះមានបសាទសទ្ធាជ្រះថ្លា ចំណាយទ្រព្យអស់ច្រើនកោដិ ដើម្បីកសាងវត្តជេតពនថ្វាយចំពោះព្រះពុទ្ធគោតមបរមគ្រូ ។ មិនតែប៉ុណ្ណោះ សេដ្ឋីបានផ្គត់ផ្គង់ព្រះភិក្ខុសង្ឃអង្គញាណ ដោយបច្ច័យទាំងបួនឥតខ្ចោះ រហូតដល់បាននាមថា ជាមហាឧបាសកដ៏ឆ្នើម ក្នុងសម័យពុទ្ធកាល ។

## សំណួរ

១- ចូរពន្យល់ពាក្យ : បុរស សទ្ធា ទុគ៌ត សេដ្ឋី ពុទ្ធកាល ។

២– ចូរតែងឃ្លាជាមួយនឹងពាក្យ : កសាង នាម ថ្វាយ សេដ្ឋី មហាឧបាសក ។

៣- ចូរស្រង់ពាក្យជាកិរិយាសព្ទ ដែលមាននៅក្នុងអត្ថបទនេះឲ្យអស់ ព្រមទាំងបង្ហាញនូវមុខងារកិរិយាសព្ទនោះផង ។

៤– ចូរដាក់ចំណងជើងថ្មីនៃអត្ថបទនេះ តើអាចដាក់ថារឿងអ្វីបានខ្លះ ។ ចូរអធិប្បាយដោយមាត់ទទេ ឬតែងរឿងអនាថបិណ្ឌិកសេដ្ឋី ឲ្យមានកម្រិតប្រាំបន្ទាត់យ៉ាងវែង ។



www.budinst.gov.kh www.elibraryofcambodia.org

# នាងវិសាខា

● នាងវិសាខា ជាធីតាសំណព្វចិត្តរបស់ធនញ្ជយសេដ្ឋី នៅក្នុងនគរសាកេត ។ នាងនេះ បានដល់នូវសោតៈ តាំងពីអាយុ ៧ ឆ្នាំម៉្លេះ ក្នុងពេលដែលចូលទៅស្តាប់ធម៌ព្រះពុទ្ធ ជាមួយនឹងជីតា ។ នាងបានកសាងវត្តបុព្វារាមអស់ប្រាក់ចំនួនម្ភៃប្រាំពីរកោដិ ដើម្បីឧទ្ទិសចំពោះព្រះពុទ្ធបរមគ្រូ ក្រោយពីនោះ នាងបានទំនុកបម្រុងព្រះសាស្តា មួយអន្លើដោយភិក្ខុសង្ឃ ឥតបីធ្វេសប្រហែស ។ សេចក្តីតំណាលថា ក្នុងពេលធ្វើដំណើរទៅកាន់អារាមរាល់ពេល នាងពុំដែលមានដៃទទេឡើយ គឺពេលព្រឹកមានចង្ហាន់ភោជ្យភត្តសព្វយ៉ាង ពេលល្ងាចមានភេសជ្ជៈសម្រាប់ថ្នាំកែរោគ ។ អំពើជាសប្បុរស ចំពោះពុទ្ធសាសនានោះ បណ្តាលឲ្យនាងមាននាមថា ជាមហាឧបាសិកាមួយរូប ប្រកបដោយសទ្ធាជ្រះថ្លា ល្បីខ្ចរខ្ចាយរហូតដល់សព្វថ្ងៃ ។

## សំណួរ

១ ចូរពន្យល់ពាក្យ : កសាង ព្រះសាស្តា ភោជ្យភត្ត ភេសជ្ជៈ រោគ ។

២- ចូរតែងឃ្លាជាមួយនឹងពាក្យ : នាងវិសាខា នគរសាកេតធម៌ តំណាល ល្បីខ្ចរខ្ចាយ ។

៣— តើនាងវិសាខាបានសាងអ្វីខ្លះ សម្រាប់ពុទ្ធសាសនា? នាងបាននាមថ្មីថាជាអ្វី ? ក្នុងពុទ្ធកាលនាងបានសម្រេចធម៌អ្វី ? ធម៌នោះមានប្រយោជន៍ដល់នាងដូចម្តេចខ្លះ ?

៤— ចូរតែងរៀងនាងវិសាខា ដោយស្រង់គំនិត តាមអត្ថបទនេះ ។



www.budinst.gov.kh www.elibraryofcambodia.org

## អំពីភូមិ

● ផ្ទះច្រើនរួមគ្នា កើតបានជាភូមិ ។ ឈ្មោះភូមិគេច្រើនកំណត់យកតាមលំនាំទីកន្លែង ដែលមានគោលចារឹក ដូចជាឈ្មោះព្រៃក បឹង, ស្ទឹង, ទួល, វត្ត, ឈើផ្សេង ៗ និងឈ្មោះមនុស្សដែលបង្កភូមិដំបូងបំផុត ។ ឧទាហរណ៍ ភូមិព្រែកក្របៅ, ភូមិបឹងដោល, ភូមិស្ទឹងសែន, ភូមិទួលអ្នកតា, ភូមិវត្តប្រាសាទ, ភូមិឈើទាល, ភូមិតាសុខ ជាដើម ។

ភូមិនីមួយ ៗ មានមេភូមិម្នាក់ ជាអ្នកមើលការខុសត្រូវ ចំពោះអ្នកភូមិ ។ ភូមិមានទំហំមិនដូចគ្នាទេ គឺភូមិខ្លះធំ ខ្លះតូច តាមតែចំនួនផ្ទះ និងប្រជាជន បើចំនួនផ្ទះតិចពេក ភូមិនោះក៏ពុំពេញលក្ខណៈដែរ ។ ឯភូមិដែលមានលក្ខណៈពេញលេញ គឺភូមិដែលមានផ្លូវចរាចរស្រួលបួល និងដីមានជីជាតិច្រើន មនុស្សចូលចិត្តរស់នៅ ។

## សំណួរ

១- ចូរពន្យល់ពាក្យ : ភូមិ គោលចារឹក ប្រជាជន លក្ខណៈ ចរាចរ ។

២- ចូរតែងឃ្លាជាមួយនឹងពាក្យ : ភូមិ ផ្ទះ ពេញលេញ ផ្លូវ ជីជាតិ ។

៣- ចូររកវេវចនសព្ទនឹងពាក្យ : ផ្ទះ ប្រជាជន ។

៤- ចូរពិពណ៌នា អំពីភូមិមួយ ដែលលោកបានស្គាល់ច្បាស់ ។



www.budinst.gov.kh www.elibraryofcambodia.org

## អ្នកស្រុក

● ភូមិច្រើនរួមបានជាសង្កាត់ ហើយសង្កាត់ច្រើនរួមបានជាស្រុក ។ ប្រជាជនដែលរស់នៅក្នុងស្រុក ហៅថាអ្នកស្រុក តែខ្លះទម្លាប់ហៅមនុស្ស ដែលនៅក្នុងភូមិនីមួយៗ ថាជាអ្នកស្រុកដែរ ដោយសំដៅន័យថា អ្នកភូមិទាំងនោះស្ថិតនៅក្នុងស្រុក ។ អ្នកស្រុកក្នុងភូមិនីមួយ ៗ ត្រូវស្ថិតនៅក្រោមគម្រប់គម្រង នៃលោកចៅសង្កាត់ និងលោកអភិបាលស្រុក ។ អ្នកស្រុកត្រូវមានភារៈជួយរក្សាសន្តិសុខរវាងគ្នានិងគ្នា ដូចជាគ្រួសារតែមួយ; ត្រូវបង់ពន្ធអាករទៅសាលាស្រុកតាមរយៈសាលាសង្កាត់របស់ខ្លួន ។ កាលបើអ្នកស្រុកណាម្នាក់ ដែលនៅក្នុងភូមិជាមួយ ទទួលគ្រោះថ្នាក់ ដោយមាតាបិតា មាមីង ឬបងប្អូនទទួលអនិច្ចធម្ម ឬក៏រវល់ធ្វើបុណ្យឋានអ្វីមួយ អ្នកដែលនៅជិតខាង គប្បីចំណាយប្រាក់កាស ឬក៏កម្លាំងជួយជ្រោមជ្រែងអ្នកស្រុកនោះ ដែលមានអាសន្នអន្ទ្រក ឲ្យដូចជាគ្រួសារតែមួយ ។ ជាពិសេស ត្រូវចេះជួយដោះទុក្ខធុរៈអ្នកស្រុកដែលរស់នៅជាមួយ ដោយជួយពន្យល់ឲ្យស្រឡាញ់ចំណេះវិជ្ជានិងការងាររបស់ខ្លួន ។

### សំណួរ

១– **ចូរពន្យល់ពាក្យ** : ស្រុក អ្នកស្រុក សង្កាត់ សន្តិសុខ ពន្ធអាករ អនិច្ចធម្ម ។

២– **ចូរតែងឃ្លាជាមួយនឹងពាក្យ** : ទម្លាប់ នៅ ទៅ ជួយ ទទួល ។

៣– ភូមិ ស្រុក ខេត្ត មានន័យផ្សេងគ្នាយ៉ាងណាខ្លះ? ចូរពន្យល់ ។

៤– ចូរពិពណ៌នា អំពីអ្នកស្រុកដែលនៅជិតវត្តនោះ ។



www.budinst.gov.kh www.elibraryofcambodia.org

# របររស្រុក

● ប្រជាជន ដែលរស់នៅក្នុងស្រុកនីមួយ ៗ មានមុខរបរផ្សេង ៗ គ្នា, ក្រុមខ្លះប្រកបមុខរបរធ្វើស្រែ, ក្រុមខ្លះមានមុខរបរជាអ្នកធ្វើចម្ការ, ខ្លះមានមុខក្រសួងជាអ្នករដ្ឋការ បម្រើកិច្ចការរដ្ឋ តាមផ្នែករបស់ខ្លួន, ខ្លះមានអាជីវកម្មខាងជំនួញផ្សេងៗ, ខ្លះលក់ដូរបន្តិចបន្តួច ។

● បណ្ដាក្រុមនៃប្រជាជនទាំងអស់ ប្រជាជនដែលប្រកបរបរកសិកម្ម ច្រើនជាងក្រុមដទៃទៀត ព្រោះស្រុកខ្មែរយើង សម្បូណ៌ដោយដីស្រែចម្ការ ហើយផលដែលកើតអំពីកសិកម្មទៀតសោត ក៏អាចផ្ដល់ឲ្យអ្នកប្រកបមុខរបរនោះ ល្មមសមគួរដល់គោលបំណងរបស់ខ្លួនបាន ។

## សំណួរ

១– **ចូរពន្យល់ពាក្យ** : មុខរបរ កិច្ចការរដ្ឋ កសិកម្ម អាជីវកម្ម ។

២– **ចូរតែងឃ្លាជាមួយនឹងពាក្យ** : ក្រុមខ្លះ ផ្នែក លក់ដូរ សម្បូណ៌ ផល ។

៣– ពាក្យថា សម្បូណ៌ និងចម្រើន ប្រើបានប៉ុន្មានយ៉ាង ? ក្នុងន័យបែបណាខ្លះ? ចូរពន្យល់ និងតែងជាឃ្លា ។

៤– តើអត្ថបទនេះ គេនិយាយអំពីអ្វីខ្លះ ? ចូរស្រង់មកបន្តិច ។



www.budinst.gov.kh www.elibraryofcambodia.org

# ជីវភាពអ្នកស្រែ

● ខែចែត្រចូលដល់ , អ្នកស្រែគ្រប់ជនបទ បានរៀបចំប្រុងប្រៀបប្រដាប់ប្រដា គឺ នង្គ័ល រនាស់ គោ ក្របី និងពិធិត្យពូជធារសម្រាប់ធ្វើស្រែ ។

● ផ្គរលាន់ក្តុងក្តាំង, ភ្លៀងធ្លាក់ជោគជាំ, គេនាំគ្នាយកស្រូវពូជទៅត្រាំៗ ដើម្បីយកទៅសាប ឬព្រោះលើដីស្រែដែលភ្ជួររាស់រួចហើយ ។ កន្លងមួយខែកន្លះ ឬពីរខែក្រោយមក គេក៏ដកសំណាបយកទៅស្ទូងក្នុងស្រែ ។ រវាងបី ឬបួនខែ សម្ទុងក្លាយទៅជាស្រូវ មានផ្លែក្រហមឆ្អៅ ពេលនោះហើយដែលក្រុមកសិករ មានសេចក្តីសង្ឃឹមញញឹមចំពោះលទ្ធផលស្រូវរបស់ខ្លួន ។ ផុតពីរដូវស្រូវ អ្នកស្រែមានភារៈធូរស្រាលបន្តិច តែខ្លះនៅតែមានការមមាញឹក ចំពោះមុខរបរផ្សេងៗទៀត មានរបរត្នោត និងរបរលក់ដូរជាដើម ។

## សំណួរ

១– ចូរពន្យល់ពាក្យ : ជីវភាព កសិករ លទ្ធផល រដូវ មមាញឹក ។

២– ចូរតែងឃ្លាជាមួយនឹងពាក្យ : រៀបចំ ពិនិត្យ សាបព្រោះ ភ្ជួរ ស្រូវ ។

៣– ចូររៀបរាប់អំពីប្រដាប់ប្រដា របស់កសិករ ឲ្យសព្វគ្រប់មកមើល ?

៤– ចូរពន្យល់ អំពីជីវភាពអ្នកស្រែ តើប្លែកពីអ្នកចម្ការដូចម្តេចខ្លះ ?



www.budinst.gov.kh www.elibraryofcambodia.org

# ជីវភាពឧស្សាហករ

● ប្រវត្តិសាស្ត្រក្នុងសម័យបច្ចុប្បន្ន បានពង្រីកអាត្ម័នវិវដ្ត ជ្រាបចូលក្នុងទឹកចិត្ត នៃប្រជាជនខ្មែរគ្រប់និគមជនបទ ។ រោងចក្រស្ទើរគ្រប់ខេត្ត បានបញ្ចេញសំឡេងគួរឲ្យរំភើប សកម្មភាពឧស្សាហករ ប្រកបដោយចលនារស់រវើកក្នុងការបញ្ចេញកម្លាំងនិងសាច់ដុំ លាយឡំជាមួយនឹងកម្លាំងយន្ត ដែលអូសទាញវិលត្រឡប់ត្រឡិនគ្មានឈប់ឈរ ។ ដោយសារចលនានៃឧស្សាហករនេះហើយ បានជាប្រទេសខ្មែរយើង មានប្រដាប់ប្រដាប្រើប្រាស និងគ្រឿងបរិភោគសព្វយ៉ាង ដូចជាស្ករស, សំពត់, ក្រដាស, ក្តារបន្ទះ, ចាន, កែវ, ស៊ីម៉ង់ត៍, ដែកគោល និងម្ជុលកំប៉ុងគ្រប់ធុន ដែលមានក្នុងបច្ចុប្បន្នកាលនេះស្រាប់ ។

## សំណួរ

១— ចូរពន្យល់ពាក្យ ៖ ឧស្សាហកម្ម ឧស្សាហករ ប្រវត្តិសាស្ត្រ ឯកភាជ្យជាតិ សកម្មភាព ។

២— ចូរតែងឃ្លាជាមួយនឹងពាក្យ ៖ ប្រវត្តិសាស្ត្រ ឧស្សាហករ ចលនា ប្រើប្រាស់ ស្ករស ក្រដាស ។

៣— ចូរពន្យល់និងឱ្យឧទាហរណ៍ចំពោះពាក្យ ៖ ឧស្សាហករ និងឧស្សាហកម្ម ។

៤— ចូរពិគណ៌នា ករណីយកិច្ចរបស់ឧស្សាហករ ដែលលោកបានឃើញក្នុងពេលគេបំពេញភារកិច្ច ។



www.budinst.gov.kh www.elibraryofcambodia.org

# នាយស្មូនឆ្នាំង

● អ្នកមីងទេវី ជាឧបាសិកាម្នាក់ បានប្រកបមុខរបរប្រចាំជីវិតរបស់ខ្លួន ជាស្មូនឆ្នាំង ។ មួយថ្ងៃៗ គេឃើញគាត់អង្គុយលើជើងម៉ា, ជើងឆ្វេងធាក់ឈ្នាន់ឲ្យវិលថាស, ដៃសង្កត់ចំកណ្ដាលដុំដី ដែលនៅលើថាស, ដុំដីនោះក្លាយទៅជាភាជន៍មួយ តែពុំទាន់មានរាងរៅជាឆ្នាំងនៅឡើយ ។ អ្នកស្មូនឆ្នាំងនេះ យកដៃទាំងពីរពង្រីកផ្ទៃភាជន៍ ហើយពន្លូតមាត់ឲ្យស្ដើង បំពោងត្រង់ក្អែងមាត់ លាបលនឲ្យស្មើសាច់ ។ លុះត្រាតែបានរូបរាងជាឆ្នាំង ឬក្អម រួចហើយគេយកទៅហាលថ្ងៃឲ្យស្ងួតសិន មុននឹងយកទៅដុតឲ្យឆ្អិនក្នុងគំនរចំបើង ។

## សំណួរ

១– ចូរពន្យល់ពាក្យ : ជីវិត ស្មូនឆ្នាំង ភាជន៍ ឆ្នាំង ក្អម ។

២– ចូរតែងឃ្លាជាមួយនឹងពាក្យ : អង្គុយ ជើង ថាស រាងរៅ ពង្រីក យកទៅ ឲ្យ ។

៣– គេធ្វើឆ្នាំងនិងក្អម នៅតំបន់ណាខ្លះ ? ឆ្នាំងដែលសម្រាប់ប្រើប្រាស់សព្វថ្ងៃមានឈ្មោះដូចម្ដេចខ្លះ ? ឆ្នាំងស្ពាន់ធ្វើនៅខេត្តណា ?

៤– ចូរពន្យល់អំពីរបៀបធ្វើឆ្នាំងដី ដែលជាសមិទ្ធិការ្យ ប្រតិស្ឋនៅស្រុកខ្មែរ ។



www.budinst.gov.kh www.elibraryofcambodia.org

# ជាងកំបោរ

●ព្យូសួន ជាជាងកំបោរមួយរូប ។ គាត់បានទទួលសាងព្រះវិហារវត្តព្រែកក្របៅ ។ គេឃើញគាត់មានប្រដាប់ប្រដា គឺស្លាបព្រាដែក, ស្លាបព្រាឈើ, ថាំងសម្រាប់ដាក់កំបោរ, ចបកាប់, ចបចូក, កែវស្ទង់, កូនប្រយោល និងម៉ែត្រ ។

ដំបូង គាត់កាប់ជីកដីចាក់គ្រឹះសសរ ប្រើដោយស៊ីម៉ង់ត៍ គ្រួស ខ្សាច់ បង្កប់សរសៃដែកខាងក្នុង ។ ជញ្ជាំងរៀបឥដ្ឋ បូកដោយបាយអរយ៉ាងម៉ត់ចត់ ។

ព្យូសួន គាត់មានកូនជាងជាច្រើនទៀត ជួយធ្វើការគាត់ ខ្លះលាយកំបោរថ្ម ខ្លះលាយទឹកកំបោរ ខ្លះជញ្ជូនខ្សាច់ ខ្លះរៀបឥដ្ឋ ។ កូនជាងទាំងនោះជាអ្នកចុះខសន្យា ក្នុងដំណើរធ្វើការស៊ីប្រាក់ប្រចាំថ្ងៃ ។

## សំណួរ

១– ចូរពន្យល់ពាក្យ : គ្រឹះ មេជាង កូនជាង ខសន្យា ប្រាក់ប្រចាំថ្ងៃ។

២– ចូរតែងឃ្លាជាមួយនឹងពាក្យ : ព្យូសួន កូនប្រយោល ជីក គ្រួស លាយ បញ្ជូន ។

៣– ចូរពិពណ៌នាអំពីជាងកំបោរម្នាក់ ដែលមាននាទីជាមេជាង ។



www.budinst.gov.kh www.elibraryofcambodia.org

# ជាងឈើ

●បណ្ឌិតស្ងួត ជាមេជាងមួយរូប មានសិល្បៈខាងវឌ្ឍកី ។ រៀងរាល់ថ្ងៃគាត់ពុំបានទំនេរឡើយ ព្រោះការងារវឌ្ឍកីនេះ ជារបរប្រចាំជីវិតរបស់គាត់ ។ ម្ល៉ោះហើយប្រសិនបើគ្មាននរណាជាក់ឲ្យគាត់ធ្វើទេ, គាត់តែងតែធ្វើតុ តាំង ទូ គ្រែ កៅអី ដើម្បី ទុកយកទៅលក់ឯផ្សារ ។ នៅជិតខ្លួនគាត់, គេឃើញមានសម្ភារៈជាងជាច្រើន គឺជើងម៉ាឈូសឈើ, ដែកឈូស, ដែកលក ដែកអង្រស, ពន្ទាក, ស្វាន, ដែកកណ្ដារ, ដែកខ្វង, ម៉ែត្រ, កែង, ប្រពាយ, ដែកឈាន ដែកបញ្ចូន, រណារកាត់, រណារវ៉ា, រណាររៀល, ផង្កាប់, ក្ដារ, ដែកកោល និងគ្រឿងតុ តាំង ទូ ដែលគាត់បានធ្វើរួចហើយ ។

## សំណួរ

១– ច្ចូរពន្យល់ពាក្យ : ជាងឈើ បណ្ឌិត វឌ្ឍកី សម្ភារៈ ។

២– ចូរតែងឃ្លាជាមួយនឹងពាក្យ : ពូកែណាស់ ទំនេរ រណារ គ្រែ តុ តាំង ពន្ទាក ប្រពាយ ។

៣– ចូររកបរិវារសព្ទនឹងពាក្យ : ប្រើ ប្រដាប់ ថ្នាំ ចាន, ផ្ទះ, បន្ទេ-, ធំ-, ។

៤– ចូរបង្ហាញប្រដាប់ប្រដា ដែលកើតពីស្នាដៃជាងឈើ និងសម្ភារៈរបស់ជាងឈើ ។



www.budinst.gov.kh www.elibraryofcambodia.org

# រឿងអណ្ដើកនិងស្វា

●អណ្ដើកនិងស្វា បានស្មគ្គាធ្វើជាមិត្រសំឡាញ់ ។ ចំណេរចីរកាលក្រោយមក, ថ្ងៃមួយ ស្វាអញ្ជើញអណ្ដើកទៅជប់លៀងលើចុងឈើ ដោយឲ្យអណ្ដើកខាំវល្លិ ហើយស្រាវខ្សែឡើងទៅលើ ។ លុះជិតទៅដល់ចុងឈើ ភរិយានៃស្វាស្រែកសួរសុខទុក្ខអណ្ដើក ។ អណ្ដើកអត់ទ្រាំពុំបាន ក៏ហាមាត់ឆ្លើយ មិនទាន់ទាំងបាននិយាយតបមួយម៉ាត់ផង ក៏ធ្លាក់ខ្នោកបែកស្នូកខ្ទេចខ្ទី ខានបរិភោគភោជនាហារ ដែលស្វារៀបចំបម្រុងទុកនោះទៅ ។

## សំណួរ

១– ចូរពន្យល់ពាក្យ : មិត្រសំឡាញ់ ចីរកាល ជប់លៀង ភោជនាហារ អត់ទ្រាំ ។

២– ចូរតែងឃ្លាជាមួយនឹងពាក្យ : អណ្ដើក ស្វា អញ្ជើញ ស្រែកសួរ ធ្លាក់ ។

៣– ចូរនិទានរឿង អណ្ដើកនិងស្វា ដោយមាត់ទទេ ។

៤– តើរឿងអណ្ដើកនិងស្វា បានជាដំបូន្មានដល់លោកដូចម្ដេចខ្លះ ?ចូរពន្យល់ ។



www.budinst.gov.kh www.elibraryofcambodia.org

# អស្សុតរអស់ឫទ្ធិ

● សេចក្ដីតំណាលថា សម័យមួយ មានពុទ្ធបរិស័ទមួយក្រុម បានធ្វើសមាធិកម្មដ្ឋាន កំពុងស្ងឹងស្ងាធិក្នុងព្រះវិហារ ។ មានសេះមួយធុំក្លិនក្រអូបមធុបាយាស ស្រក់ទឹកមាត់ ទ្រាំពុំបាន ក៏ចូលទៅកប្បិយបាយាសអស់ ហើយហោះបាត់ទៅ ។ ព្រះសង្ឃមួយអង្គើដោយពុទ្ធបរិស័ទ ចេញពីធ្វើធម៌ វិញក៏ទ្រាំអត់ចង្ហាន់អស់មួយថ្ងៃ ។

លោកគ្រូមេវត្តនឹកសង្ស័យ ក៏ដេញប្រាជ្ញា ចូលមេកច្ចាយ គោះពួកអស្សុតរទាំងអស់មកពិនិត្យ លុះដឹងរឿងពិត លោកក៏យកកាំបិតកោរ កាត់សរសៃជើងសេះ លែងឲ្យហោះរួច ព្រោះខ្លាចមានវិបត្តិ ដល់មនុស្សលោកទៅពេលក្រោយ ពួកសេះក៏លែងហោះរួចតាំងពីពេលនោះមក ។

## សំណួរ

១- ចូរពន្យល់ពាក្យ : អស្សុតរ មធុបាយាស កប្បិយ ពុទ្ធបរិស័ទ វិបត្តិ ។

២- ចូរតែងឃ្លាផ្សំមួយនឹងពាក្យ : ហោះ សង្ស័យ កាត់ ខ្លាច ។

៣- ចូររកវេវចនសព្ទនឹងពាក្យៈ អស្សុតរ និងកប្បិយ ។

៤- ចូរបង្ហាញនូវមូលហេតុ ដែលបណ្ដាលឲ្យសេះអស់ឫទ្ធិ លែងស្ដាប់បាន ។



www.budinst.gov.kh www.elibraryofcambodia.org

# ជីវភាពអ្នកចម្ការ

● ប្រជាជនមួយក្រុមធំ ដែលរស់នៅតាមតំបន់ចម្ការ មានរបរប្រចាំជីវិតខាងដាំដំណាំ ។

ក្នុងមួយឆ្នាំ ៗ អ្នកចម្ការពុំដែលមានពេលទំនេរឡើយ ព្រោះដំណាំដែលគេត្រូវដាំ មានគ្រប់រដូវ គឺអស់ពីរដូវដំណាំមួយ ទោដល់រដូវដំណាំមួយទៀត ពុំដែលមានចោលដីទំនេរទេ ។

ពោត គេចាប់ដាំតាំងពីខែចេត្រ ដល់ខែស្រាពណ៍ហើយក្នុងរដូវនេះ គេអាចដាំត្រាវ, ដំឡូង, ត្រប់ និងដំណាំផ្សេង ៗ ទៀត ។ រដូវសណ្ដែក គេដាំសណ្ដែកតាំងពីខែស្រាពណ៍ ដល់ខែអស្សុជ ។ រដូវផែថារ គេចាប់ដាំថៃថារតាំងពីខែអស្សុជដល់ខែបុស្ស ។ រដូវអំពៅ គេចាប់ដាំអំពៅតាំងពីខែបុស្សដល់ខែចេត្រ ។

ដីចម្ការដែលមានច្រើនជាងគេ គឺស្ថានភាពដី ដែលស្ថិតនៅតាមមាត់ទន្លេមេគង្គ ។ ហើយពួកកសិករទាំងនោះ តែងបានទទួលផលដំណាំជាទីគាប់ចិត្តរបស់ខ្លួន។

## សំណួរ

១– ចូរពន្យល់ពាក្យ : អ្នកចម្ការ តំបន់ ដំបន់ ដំណាំ ស្ថានភាព។

២– ចូររកសន្តាននៃសព្ទនឹងពាក្យ : ប្រជា ។

៣– នាមនាម និងគុណនាម ប្លែកគ្នាយ៉ាងណា ? ចូរពន្យល់ឲ្យច្បាស់លាស់។

៤– ចូររៀបរាប់ អំពីជីវភាពរបស់អ្នកចម្ការ ។



www.budinst.gov.kh www.elibraryofcambodia.org

# ជាងតម្បាញ

● ពលរដ្ឋខ្មែរមួយក្រុម ជាឧស្សាហការីនី បានធ្វើឧស្សាហកម្មក្នុងគេហដ្ឋានផ្ទាល់ខ្លួន ។ រោងចក្រតម្បាញ ដែលផុសចេញពីស្នាដៃប្រជាជនសុទ្ធសាធនេះ មានតាំងពីយូរយារណាស់មកហើយ ។ គេឃើញអ្នកទាំងនោះ មានកីសម្រាប់ត្បាញបួនបែប គឺ កីសណ្ដូក, កីកាច់, កីកន្ត្រាក់ និងកីម៉ាស៊ីន ។

● សម្ភារៈរបស់កីនីមួយ ៗ មាន ក្តារកី, កកី, ត្រដោក (១) សម្រាប់សិតក្តារមួរ, ជើងកី, ឈើសណ្ដូក, ផ្ទឹមកី ។ ក្រោយពីនោះ ជាងតម្បាញត្រូវមានៈ ផ្ចិតសម្រាប់មូរសៃ្ស, ចន្ទល់ សម្រាប់ជ្រែងសាច់សៃ្ស, កន្ទុយដង្កូវ, ដង្កូវ, ឈ្នាន់, រ៉ត, ត្រល់, ខ្នារ, ក្តារមូរ, ឈើពាន, ដាម, ធ្មេញឈើ, គ្រាប់ធ្មេញឈើ, សន្តៈ, រហាត់ខារអំបោះអន្ទង, រហាត់ខារអំបោះចាក់ និងជើងអង្ហឹង ។

សំពត់ដែលកើតពីកីតម្បាញមាន ៖ សៃ្សមុង, ក្រមា, សំពត់ស្ទូត្រ-អំបោះ, សារុងស្ទូត្រ-អំបោះ, សំពត់ព្រៃ, ហូល, ផាមួងជាដើម ។

## សំណួរ

១– **ចូរពន្យល់ពាក្យ** ៖ ជាងតម្បាញ ពលរដ្ឋ រោងចក្រ សុទ្ធសាធ ។

២– **ចូរតែងឃ្លាជាមួយនឹងពាក្យ** ៖ ឧស្សាហការីនី យូរយារ ឃើញ ត្បាញ មូរ ។

៣– សត្វបែបណា ហៅថា កិរិយាសព្ទ? មានប៉ុន្មានយ៉ាង? អ្វីខ្លះ? ចូររាប់ ។

៤– ចូរឆ្លើយដោយមាត់ទទេ នូវសម្ភារៈរបស់ជាងតម្បាញ ។

---

១– សម័យឥឡូវនេះ គេមិនសូវប្រើត្រដោកទេ ច្រើនធ្វើទម្ពក់ទាញរឹតក្តារមូរ ។



www.budinst.gov.kh www.elibraryofcambodia.org

# បុណ្យចូលឆ្នាំខ្មែរ

នៅថ្ងៃទី ១៣ ខែមេសា រៀងរាល់ឆ្នាំ ខ្មែរបានកំណត់បុណ្យមួយ ហៅថា បុណ្យចូលឆ្នាំ ។ មនុស្សក្នុងភូមិនីមួយៗ បានបោសសម្អាតគេហដ្ឋានព្រមទាំងតុបតែងលម្អផ្ទះ ដោយផ្កាឈើនិងផ្កាក្រដាស រំលេចដោយទង់ជាតិ និងទង់សាសនាៗ

នៅខាងមុខផ្ទះ, មានតុមួយ តម្កល់ទៀន ធូប ផ្កា ទឹកអប់ និងផ្លែឈើផ្សេងៗ សម្រាប់ទទួលទេវតាឆ្នាំថ្មី ។

ក្នុងឱកាសចូលឆ្នាំ, ប្រជាជន បាននាំគ្នាទៅវត្ត ដើម្បីប្រគេនចង្ហាន់ព្រះសង្ឃនិងស្តាប់ធម៌ទេសនា ។ ក្រោពីនោះ មានលេងល្បែងប្រជាប្រិយផ្សេងទៀត ដូចលេងគោះក្រឡោក, ចោលឈូង, ទាញព្រ័ត្រ, លោតអន្ទាក់, លាក់កន្សែង, បោះអង្គុញ ហើយនិងស្តេចចង់, វេលាយប់ គេនាំគ្នាច្រៀងប្រលែង និងច្រៀងរាំវង់ ។ លុះថ្ងៃឡើងស័ក គេនាំគ្នាផងទឹកយកទៅស្រង់ព្រះ ឬដាក់ពាងប្រគេនព្រះសង្ឃ និងអូតឲ្យមាតាបិតា ជីដូនជីតា ព្រមទាំងចាស់ព្រឹទ្ធាចារ្យ ដើម្បីជាកិច្ចសូមខមាទោស ។

## សំណួរ

១– **ចូរពន្យល់ពាក្យ ៖** ឱកាស ប្រគេន ចង្ហាន់ ប្រជាប្រិយ ព្រឹទ្ធាចារ្យ ។

២— នាមនាម និងគុណនាមប្លែកគ្នាយ៉ាងណា? ចូរប្រៀបធៀបដោយឧទាហរណ៍ៗ

៣– បុណ្យចូលឆ្នាំខ្មែរមានពីគ្រឹមណាមក? ជាតិណាខ្លះដែលចូលឆ្នាំត្រូវគ្នានឹងចូលឆ្នាំខ្មែរ ? ចូររៀបរាប់ ។

៤– ចូរពិពណ៌នា របៀបចូលឆ្នាំខ្មែរ នៅក្នុងស្រុករបស់លោក ។



www.budinst.gov.kh www.elibraryofcambodia.org

## បុណ្យភ្ជុំបិណ្ឌ

● រៀងរាល់ឆ្នាំ, នៅថ្ងៃ ១៥ រោច ខែភទ្របទ ខ្មែរយើង តែងប្រារព្ធធ្វើនូវបុណ្យមួយ ហៅថា បុណ្យភ្ជុំបិណ្ឌ ។

នៅថ្ងៃភ្ជុំ ក្នុងទីអាវាសវត្តនីមួយ ៗ មានឧបាសក ឧបាសិកា មនុស្សប្រុសស្រី ក្មេង ចាស់ ច្រើនមីរដេរដាស ស្លៀកពាក់ខោអាវថ្មី ៗ មានសភាពយ៉ាងសមរម្យ ឡើងទៅជួបជុំគ្នាកកស្រទាប់ នៅក្នុងសាលាបុណ្យ ដើម្បីប្រគេនចង្ហាន់ព្រះសង្ឃនិងស្ដាប់ព្រះសង្ឃសូត្រធម៌ ។

ក្នុងពេលបុណ្យភ្ជុំបិណ្ឌម្ដង ៗ ប្រជាជនដែលនៅឆ្ងាយ ៗ បានវិលទៅជួបជុំគ្នានៅស្រុកកំណើតវិញ ដើម្បីនិមន្តព្រះសង្ឃបង្សុកូល ឧទ្ទិសផលដល់បុព្វការីជន ដែលបានចែកឋានទៅកាន់បរលោក ។

តាមធម្មតា បុណ្យភ្ជុំបិណ្ឌ គេច្រើនតែធ្វើនៅក្នុងវត្ត គេមិនសូវធ្វើបុណ្យនេះនៅក្នុងផ្ទះ ឬទីដទៃទៀតឡើយ ។

### សំណួរ

១ — **ចូរពន្យល់ពាក្យ**: បុណ្យ ប្រារព្ធ ភ្ជុំ បង្សុកូល បុព្វការី ។

២ — **ចូរតែងឃ្លាជាមួយនឹងពាក្យ**: បុណ្យភ្ជុំបិណ្ឌ មីរដេរដាស សមរម្យ ។

៣ — គុណនាម មានន័យដូចម្ដេច? មានប៉ុន្មានយ៉ាង? អ្វីខ្លះ?

៤ — ចូរប្រាប់នូវពាក្យដែលជាគុណនាម នៅក្នុងអត្ថបទខាងលើនេះ ។



www.budinst.gov.kh www.elibraryofcambodia.org

# ទង់ជាតិ

● ប្រជាជាតិក្នុងរដ្ឋនីមួយ ៗ តែងមានទង់សម្រាប់ជាតិរបស់ខ្លួន ។ ប្រទេសខ្មែរ ជារដ្ឋមួយ ក្នុងចំណោមរដ្ឋទាំងឡាយនៃពិភពលោក ហើយទង់ដែលតំណាងជាតិខ្មែរ ហៅថា « ទង់ជាតិខ្មែរ » ។

ទង់ជាតិនេះ មានពណ៌ប្រកបដោយអង្គបី ហៅថា ត្រៃរង្គ គឺនៅឋានកណ្ដាល មានពណ៌ស ជាគ្រឿងសម្គាល់សាសនា បញ្ជាក់ថាជាតិខ្មែរ ជាជនដែលមានសាសនាសម្រាប់ជាតិ; ពណ៌ក្រហមអមជុំវិញពណ៌ស ជាគ្រឿងសម្គាល់ថាជាតិខ្មែរ ជាអ្នកក្លាហានក្នុងរៀណរង្គ; ពណ៌ខៀវផ្ទៃមេឃ ជាគ្រឿងសម្គាល់ថាជាតិខ្មែរ មានឥស្សរភាពចំពោះខ្លួនឯង និងអារ្យធម៌ដ៏រុងរឿង ។ ក្រៅពីពណ៌ទាំងបីនោះ មានរូបប្រាសាទ ស្ថិតនៅត្រង់កណ្ដាលពណ៌ស ជាគ្រឿងសម្គាល់ថាជាតិខ្មែរ មានប្រាសាទល្អអស្ចារ្យក្នុងពិភពលោក ។

## សំណួរ

១– **ចូរពន្យល់ពាក្យ** : ទង់ជាតិ ពិភពលោក ត្រៃរង្គ រៀណរង្គ ឥស្សរភាព អារ្យធម៌ ។

២– **ចូរតែងឃ្លាជាមួយនឹងពាក្យ** : ទង់ជាតិ សម្គាល់ ផ្ទៃមេឃ អស្ចារ្យ ។

៣– **ចូររកពាក្យផ្ទុយនឹងពាក្យ** : សង្គ្រាម ពុទ្ធសាសនា សុចរិត សុភាសិត អារ្យធម៌ អរិយធម៌ សាមគ្គី ។

៤– ចូរពន្យល់អំពីលក្ខណៈទង់ជាតិ និងប្រយោជន៍របស់ទង់ជាតិខ្មែរ ។



www.budinst.gov.kh www.elibraryofcambodia.org

## ទង់សាសនា

● ប្រទេសខ្មែរ មានព្រះពុទ្ធសាសនា ជាសាសនាសម្រាប់រដ្ឋព្រោះពលរដ្ឋខ្មែរគោរពប្រតិបត្តិ ទាំងអស់គ្នា ។ អាស្រ័យហេតុនេះ ប្រជាជាតិខ្មែរ ត្រូវមានទង់មួយបែប ដែលមានរស្មីមានពណ៌ប្រាំមួយយ៉ាង ហៅថា ឆព្វណ្ណរង្សី គឺពណ៌ ខៀវ លឿង ក្រហម ស ហង្សបាទ និងពណ៌ ផ្លេក១ចម្រុះ នៅខាងចុង ។ ទង់សាសនានេះសម្រាប់ប្រើក្នុងពេលមានពិធីបុណ្យសាសនាម្តង ។ ដូចជា បុណ្យភ្ជុំ, បុណ្យចូលឆ្នាំ, បុណ្យវិសាខបូជា, បុណ្យមាឃបូជា, បុណ្យដង្ហែព្រះសារីរិកធាតុ និងបុណ្យកឋិនជាដើម ។

ជួនកាលគេលើកទង់សាសនា និងទង់ជាតិជាមួយផងក៏មាន ព្រោះគេសម្គាល់ថា សាសនាអាស្រ័យជាមួយនឹងជាតិ បើគ្មានជាតិទេនោះ សាសនាក៏ពុំមានដែរ ។

### សំណួរ

១– ចូរពន្យល់ពាក្យ៖ សាសនា ពលរដ្ឋ រស្មី ឆព្វណ្ណរង្សី ព្រះសារីរិកធាតុ ។

២– ពាក្យជាកិរិយាសព្ទ មានន័យយ៉ាងណា? មានប៉ុន្មានយ៉ាង? អ្វីខ្លះ? ចូររាប់ ។

៣– ចូរស្រង់ពាក្យដែលជាកិរិយាសព្ទទាំងអស់ ក្នុងអត្ថបទនេះមកមើល ?

៤ ទង់សាសនា គេប្រើនៅពេលណា? ហេតុអ្វីបានជាប្រើនៅពេលនោះ ? សម្គាល់ដូចម្តេច ? ចូរពន្យល់ ។



www.budinst.gov.kh www.elibraryofcambodia.org

## ទង់មហារាជ

● ក្នុងអតីតកាល ទង់សម្រាប់តំណាងព្រះមហាក្សត្រហៅថា « ទង់មហារាជ » ។ ទង់នេះ មានលក្ខណៈប្លែកពីទង់ជាតិ ព្រោះមានពណ៌តែពីរបែប គឺៈ ពណ៌ខៀវផ្ទៃមេឃ នៅកណ្ដាលពណ៌ក្រហម នៅជាយជុំវិញហើយនៅកណ្ដាលផ្ទៃទង់ មានប៉ាក់ដោយសូត្រពណ៌មាស នូវសញ្ញារូបព្រះខ័នតម្កល់លើជើងពាន ហើយមានរូបមកុដនៅខាងលើព្រះខ័ន និងមានឆត្រ្រូត ១គូ អមពានព្រះខ័ន ព្រមទាំងរូបរាជសីហ៍ ១ គជសីហ៍ ១ ឈរចំអើតបែរមុខគល់គ្នា ស្ថិតនៅខាងក្រោមឆត្រ្រូត អមសងខាងព្រះខ័ន ។

## ទង់ជ័យ

● ទង់សម្រាប់ប្រចាំកងទ័ព ហៅថា « ទង់ជ័យ » ។ ទង់នេះមានលក្ខណៈភិនភាគ ជាត្រីកោណ « ជ្រុងបី » មានពីរពណ៌គឺពណ៌ខៀវផ្ទៃមេឃនៅឋានកណ្ដាល ពណ៌ក្រហមអមជុំវិញ ជាយខាងផ្ចិតផ្គង់ដោយផាក់ប្ញ រំលេចព្រយពទ្ធជុំវិញ វៀរលែងតែផ្នែកខាងមុខ ដែលភ្ជាប់នឹងដង ។ ចំណែកដងទង់ជ័យវិញ សម័យឥឡូវ គេប្រើដងធម្មតា ពុំមានរូបព្រះនារាយណ៍គង់លើគ្រុឌនិងរូបហនុមាននៅចុងដង ដូចសម័យអង្គរភ្នំឡើយ ។

## សំណួរ

១– ចូរពន្យល់ពាក្យ : តំណាង ទង់មហារាជ ទង់ជ័យ ត្រីកោណ ។

២ ទង់ដែលសម្រាប់ប្រើក្នុងប្រទេសខ្មែរ មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

៣– ចូរពន្យល់អំពីប្រយោជន៍ របស់ទង់មហារាជ និងទង់ជ័យ ។



www.budinst.gov.kh www.elibraryofcambodia.org

# ថ្ងៃទី ៩ វិច្ឆិកា

● ថ្ងៃទី ៩ វិច្ឆិកា ១៩៥៣ គឺជាថ្ងៃប្រកបដោយជោគជ័យសិរីមង្គល ដ៏ប្រសើរ ពលរដ្ឋ ជាមួយនាម៉ឺនមុខមន្ត្រី បានទាមទារឯករាជ្យពេញបរិបូណ៌ពិតប្រាកដសេស សម្រាប់ប្រជាជាតិខ្មែរ ។ ពេលនោះប្រជាជនខ្មែរទូទាំងប្រទេស ផ្នែកព្រះសង្ឃ ក៏ដូចជាគ្រហស្ថ បានដុះតំនិតផុសខាត់ចិត្ត បញ្ចេញទឹកភក្ត្រញញឹមប្រិមប្រិយ មាន សន្តានចិត្តត្រេកអរសាទរ រកវត្ថុសក្តិសិទ្ធិអ្វីមកប្រៀបពុំបាន ។ សម្រែកផ្លូវចិត្ត បានផុះចេញពីហទយវត្ថុនៃពលរដ្ឋខ្មែរគ្រប់ ៗ គ្នា រុញច្រានហត្ថាឲ្យបញ្ចេញអច្ឆោដន សព្ទ លាយឡំជាមួយសម្រែកជ័យឃោស ស្ទើរកក្រើកព្រះធរណីខ្មែរ ។

## សំណួរ

១– ចូរពន្យល់ពាក្យ : ជោគជ័យ ឯករាជ្យ វត្ថុសក្តិសិទ្ធិ ហទយវត្ថុ។

២– ចូរតែងឃ្លាជាមួយនឹងពាក្យ : សិរីមង្គល ប្រធាន ដុសខាត់ ដុះចេញ ត្រេកអរសាទរ ផ្តល់ឲ្យ អច្ឆោដនសព្ទ ជ័យឃោស ។

៣– ពាក្យយ៉ាងណាហៅថាសព្ទនាម ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ? បើគ្មានសព្ទ នាមទេ នឹងមានវិបត្តិចំពោះអត្ថបទយ៉ាងណាខ្លះ ? ចូរពន្យល់ ។

៤– ពាក្យថា ឯករាជ្យនិងអធិបតេយ្យ មានន័យដូចម្តេច ? ចូរពន្យល់ ។



www.budinst.gov.kh www.elibraryofcambodia.org

# អគ្គពុទ្ធសាសនូបត្ថម្ភក៍

● ក្រៅពីកិច្ចការសព្វសារពើ ដែលរដ្ឋាភិបាល បានបំពេញចំពោះជាតិ ។ រដ្ឋាភិបាលបានជួយទំនុកបម្រុងព្រះពុទ្ធសាសនា គ្រប់ពេលវេលាឥតខ្ចោះ ដូចជាកសាងវត្តអារាមសម្រាប់ព្រះសង្ឃស្នាក់អាស្រ័យ, កសាងសាលាពុទ្ធិកបឋមសិក្សា — ពុទ្ធិកវិទ្យាល័យ ។

ក្រៅពីកិច្ចស្ថាបនាគ្រឹះស្ថានសម្រាប់ពុទ្ធសាសនា សមាជិករដ្ឋាភិបាលជាពុទ្ធសាសនិកមួយក្រុមដ៏ពិត៌ត្ន ក្នុងការរក្សាសីលនិងការបរិច្ចាគធនធានផ្ទាល់ខ្លួន ដើម្បីរក្សាទុកក្នុងព្រះពុទ្ធសាសនា មានចំណាយសម្បត្តិកម្មសិទ្ធិ ដង្ហែអង្គកឋិនធ្វើបុណ្យផ្កា បុណ្យវិសាខបូជានិងមាឃបូជា ជាអាទិ ។

ដោយការបំពេញកុសល ប្រកបដោយបសាទសទ្ធាដ៏ប្រសើរនេះហើយ ទើបពលរដ្ឋខ្មែរ បានប្រសិទ្ធនាមថ្មី ចំពោះរដ្ឋាភិបាលថាជា អគ្គពុទ្ធសាសនូបត្ថម្ភក៍ ដែលមានន័យថា ក្រុមអ្នកទំនុកបម្រុងគាំទ្រព្រះពុទ្ធសាសនាដ៏ឆ្នើម ស្របទៅតាមមាត្រា៨ (១) នៃរដ្ឋធម្មនុញ ដែលចែងថា «ពុទ្ធសាសនា ជាសាសនារបស់រដ្ឋ» ។

## សំណួរ

១– **ចូរពន្យល់ពាក្យ** : កិច្ចការ រដ្ឋាភិបាល ស្ថាបនា ពិត៌ត្ន ធនធាន ។

២– **ចូរតែងឃ្លាជាមួយនឹងពាក្យ** ៖ សព្វសារពើ ទំនុកបម្រុង គប់ទុក បរិច្ចាគ ។

---

(១) មាត្រា ៨ – សេរីភាពខាងជំនឿ ត្រូវបើកឲ្យមាន ដោយបរិបូណ៌ សេរីភាព ក្នុងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបើកឲ្យមានដូចខ្លោះដែរ បើបន្ថយខ្វះបាន តែត្រង់ណាដែលវៀរពុំបានដើម្បីកុំឲ្យខូចសេចក្តីស្ងប់រៀបរយដល់មហាជន ។



www.budinst.gov.kh www.elibraryofcambodia.org

# ជីវភាពមនុស្សជាន់ដើម

● ជីវភាពរបស់មនុស្សជាន់ដើម ប្លែកពីមនុស្សឥឡូវនេះច្រើនណាស់ ព្រោះរបររកស៊ីធំបំផុតរបស់ពួកនោះ គ្មានអ្វីក្រៅពីមុខរបរនេសាទនិងបរបាញ់ឡើយ ។

ផ្នែកជំនឿ, ពលរដ្ឋជំនាន់នោះ ប្រកាន់សាសនាមិនប្រាកដ គឺពុទ្ធសាសនាក៏មិនកាន់ ព្រហ្មញ្ញសាសនាក៏មិនកាន់ ។ បើមានជនណាម្នាក់ប្រព្រឹត្តឧក្រិដ្ឋទោស គេនាំគ្នាយកជននោះទៅទម្លាក់ក្នុងទឹកឲ្យក្រពើស៊ី ឬក៏យកទៅដាក់ក្នុងទ្រុងឲ្យខ្លាស៊ី ។ ប៉ុន្តែជនទាំងនោះ ខ្លាចអ្នកតាណាស់ ព្រោះគេជឿថា អ្នកតាអាចផ្តល់នូវទោសទុក្ខ និងសុភមង្គល ដល់មនុស្សគ្រប់ពេលវេលា ។

ផ្នែកសម្ភារៈ គេមិនចេះត្បាញសំពត់ សម្រាប់ស្លៀកដណ្តប់ឡើយ ។ កាំបិតប៉ូវថៅ គេយកថ្មមកដុសខាត់ឲ្យសំប៉ែត មានមុខមុតបង្គួរ សម្រាប់កាប់ឈើព្រៃ ។

## សំណួរ

១– ចូរពន្យល់ពាក្យ : ជីវភាព នេសាទ បរបាញ់ ជំនឿ ឧក្រិដ្ឋទោស ។

២– កិរិយាវិសេសន៍ មានន័យដូចម្តេច? សម្រាប់ប្រើនៅកន្លែងណា? វាអាចក្លាយទៅជាគុណនាមបានឬទេ ? ព្រោះអ្វី? ចូរស្រង់និងពន្យល់ ។

៣– តើក្នុងអត្ថបទនេះ មានកិរិយាវិសេសន៍ប៉ុន្មានពាក្យ? ចូរបង្ហាញ ។

៤– លោកយល់ដូចម្តេច ចំពោះជីវភាពមនុស្សជាន់ដើម? ចូរពន្យល់ ។



www.budinst.gov.kh www.elibraryofcambodia.org

# គេហដ្ឋាន

● គេហដ្ឋាន គឺជាលំនៅនៃមនុស្សលោក ហើយទីដែលអាចស្នាក់នៅបាននោះ គឺជំរំ ខ្ទម បង្ហា តាក ឆ្នៀង របៀង តូប រោង សាលា ព្រះវិហារ កុដិ ផ្ទះ គ្រឹះស្ថាន ប្រាង្គប្រាសាទ គ្រឹហា ថែវ និងលេណដ្ឋាន ។

នៅប្រទេសខ្មែរ គេហដ្ឋានដែលមានច្រើនជាងគេ គឺផ្ទះដែលសង់ដោយឈើ ហើយប្រក់ក្បឿង ព្រោះប្រទេសខ្មែរ បរិបូណ៌ដោយព្រៃឈើធំ ៗ និងដីឥដ្ឋដែលអាចយកទៅធ្វើជាក្បឿងបានយ៉ាងល្អ ។ ម្ល៉ោះហើយ ទោះនៅទីជនបទដាច់ស្រយាលយ៉ាងណាក៏ដោយ គេក៏ឃើញគេហដ្ឋានទាំងឡាយ បញ្ចេញពណ៌ក្រហមឆ្អៅ បង្ហាញឲ្យឃើញថា ប្រជាជនខ្មែរចូលចិត្តផ្ទះក្បឿងជាងផ្ទះដទៃទៀត ។

## សំណួរ

១– តើពាក្យដែលនៅក្នុងអត្ថបទនេះ ពាក្យណាខ្លះដែលលោកមិនយល់ន័យនៃពាក្យ ? ចូរស្រង់មកមើល ?

២– ចំណងជើងអត្ថបទ បើគេផ្លាស់យកពាក្យដទៃដាក់វិញ បានឬទេ? ដាក់ពាក្យដូចម្ដេច? ព្រោះហេតុអ្វីបានជាដាក់ដូចនេះ ?

៣– ចូររៀបរាប់អំពីសម្ភារៈរបស់កុដិ ដែលលោកស្នាក់នៅសព្វថ្ងៃ ។



www.budinst.gov.kh www.elibraryofcambodia.org

## អំពីញាតិ

● ជនដែលរួមខ្សែលោហិតនឹងគ្នា ខាងមាតាឬខាងបិតាហៅថា ញាតិ ។ ញាតិនេះ ចែកចេញជាផ្លូវ មានប្រាំពីរផ្លូវ ដែលហៅថា ញាតិប្រាំពីរសន្តាន ។ តាមន័យក្នុងគម្ពីរព្រះពុទ្ធសាសនា លោកឲ្យរាប់ថ្នាក់ខាងលើបីជាន់ គឺថ្នាក់មាតាបិតា ១, ថ្នាក់ជីដូនជីតា ១, ថ្នាក់យាយទួតតាទួត , ថ្នាក់ខាងក្រោមបីជាន់ទៀត គឺថ្នាក់កូន ១ , ថ្នាក់ចៅ ១ , ថ្នាក់ចៅទួត ១ រួមនឹងថ្នាក់យើងមួយទៀត ត្រូវជាប្រាំពីរថ្នាក់ ។

● ឯជនដែលត្រូវជាសាច់ថ្លៃ ដូចជាបងថ្លៃ ប្អូនថ្លៃ កូនប្រសា មាតាបិតាក្មេកជាដើម លោកចាត់ជាញាតិដោយសារ ឬញាតិពន្ធ ។

## សំណួរ

១– ចូរពន្យល់ពាក្យ : ញាតិ លោហិត គម្ពីរ ញាតិពន្ធ ។

២– ចូរតែងឃ្លាជាមួយនឹងពាក្យ : រួមខ្សែ ផ្លូវ ផ្លូវ សន្តាន ថ្នាក់ ។

៣– ចូរពន្យល់នាទិនិងមុខងាររបស់ពាក្យ : និង នឹង ហ្នឹង ។

៤– ជនបែបណាខ្លះ ដែលហៅថាញាតិ ៧ សន្តាន ? ចូរប្រាប់ឲ្យសព្វគ្រប់ ។



www.budinst.gov.kh www.elibraryofcambodia.org

# អំពីគ្រួសារ

● គ្រួសារ សំដៅយកត្រកូលមនុស្ស ឬ ប្រជុំត្រកូលនៃជននៅក្នុងគ្រួសារនីមួយ ៗ មាន ជីតាទួត ជីដូនទួត ជីតា ជីដូន មាមីង មាតាបិតា កូនក្មួយ ចៅ ចៅទួត ។

● គ្រួសារធំ សំដៅយករដ្ឋមួយ ដែលមានប្រមុខរដ្ឋ ឬ ប្រធានាធិបតីជាអ្នកគ្រប់គ្រងពលរដ្ឋ ដោយមានរដ្ឋមន្ត្រីគ្រប់ក្រសួង ជួយការពារសុខសាន្តរបស់រាស្ត្រ ក្រោមបញ្ជានៃប្រមុខរដ្ឋ ឬ ប្រធានាធិបតី ។

● គ្រួសារមធ្យម សំដៅយកប្រជារាស្ត្រ ដែលរស់នៅក្នុងខេត្តនីមួយ ៗ មានលោកអភិបាលខេត្ត ជាអ្នកគ្រប់គ្រងប្រជារាស្ត្រក្នុងខេត្ត ។ លោកអភិបាលស្រុក និងលោកចៅសង្កាត់ ជាអ្នកទទួលភារៈគ្រប់គ្រងប្រជាជន បន្តពីលោកអភិបាលខេត្ត ។

● គ្រួសារតូច សំដៅយកត្រកូលមនុស្ស ដែលរស់នៅក្នុងផ្ទះជាមួយគ្នា មានមាតាបិតា ជាអ្នកគ្រប់គ្រង មើលការខុសត្រូវលើបុត្រធីតានិងអ្នកដែលនៅស្នាក់អាស្រ័យជាមួយ ។

## សំណួរ

១- ចូរពន្យល់ពាក្យ: គ្រួសារ ត្រកូល ប្រមុខរដ្ឋ បញ្ជា មធ្យម ។

២- ចូររកពាក្យដែលសរសេរ ប៊ិ ហើយអានថា ប៊ី ឲ្យបាន ៣ ពាក្យ ។

៣-គ្រួសារមានប៉ុន្មានបែប? ដែលហៅថាគ្រួសារធំ ខុសពីគ្រួសារមធ្យមយ៉ាងណាខ្លះ?

៤- ចូរពិពណ៌នា អំពីគ្រួសារមួយ ដែលលោកបានស្គាល់ ។



www.budinst.gov.kh www.elibraryofcambodia.org

# សេចក្តីស្នេហារបស់បុត្រធីតា

●កុលបុត្រ កុលធីតាទាំងឡាយត្រូវមានចិត្តស្នេហាចំពោះមាតាបិតារបស់អ្នកជានិច្ច។

ក្នុងពេលដែលអ្នកមានវ័យក្មេង ត្រូវប្រឹងសិក្សាសព្វមុខវិជ្ជា ទាំងផ្លូវលោក ផ្លូវធម៌ ។ លុះចំណេរចរកាលតមក អ្នកមានវ័យធំឡើង អាចប្រកបមុខរបរចិញ្ចឹមជីវិត ដោយខ្លួនឯងបាន គប្បីលៃទ្រព្យធនទំនុកបម្រុងមាតាបិតា ដូចកាលដែលគាត់ចិញ្ចឹមអ្នក , គប្បីជួយធ្វើកិច្ចការសព្វយ៉ាង ជាជំនួសកម្លាំងមាតាបិតា , គប្បីតាំងស្មារតីតម្កល់វង្សត្រកូលរបស់មាតាបិតា ឲ្យតាំងនៅជានិច្ច, ត្រូវថែទាំរក្សាឃុំគ្រងមត៌ក ដែលមាតាបិតាបានទុកឲ្យ ឲ្យគង់វង្សនៅជានិច្ច, ត្រូវប្រារព្ធធ្វើទក្ខិណានុប្បទានជារឿយ ៗ ដើម្បីឧទ្ទិសផលចំពោះមាតា ឬ បិតា ក្នុងពេលដែលគាត់ទទួលអនិច្ចកម្មទៅកាន់បរលោក ។

បុត្រធីតា ដែលបានប្រតិបត្តិចំពោះមាតាបិតាតាមន័យខាងលើ ទើបមាននាមថា អ្នកមានសេចក្តីស្នេហាចំពោះមាតាបិតា ។

## សំណួរ

១– **ចូរពន្យល់ពាក្យ** : ស្នេហា កុលបុត្រ កុលធីតា បុត្រធីតា ស្មារតី ទក្ខិណានុប្បទាន ឧទ្ទិស ។

២– **ចូរតែងឃ្លាជាមួយនឹងពាក្យ** : ជានិច្ច វិជ្ជា ធំ តម្កល់ បរលោក ។

៣– ស្នេហា តណ្ហា និង ស្រឡាញ់ ខុសគ្នាយ៉ាងណា ? ចូរពន្យល់ពីការប្រើពាក្យទាំងនេះឲ្យច្បាស់លាស់ ។

៤– បុត្រធីតា ត្រូវតបគុណមាតាបិតា ដោយស្ថានបែបណាខ្លះ ចូរពន្យល់ ?



www.budinst.gov.kh www.elibraryofcambodia.org

# សាមណេរ សន និង មាតា

ញោមប្រុសរបស់កុមារ សន បានទទួលអនិច្ចកម្ម តាំងពី សន នៅជាកុមារ មានអាយុពីរឆ្នាំម្ល៉េះ ។ កុមារ សន រស់នៅជាមួយញោមស្រី ។ លុះអាយុបានដប់បីឆ្នាំ កុមារ សន បានចូលទៅបួសជាសាមណេរ ក្នុងវត្តអម្ពិល សង្កាត់ប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ហើយបានចូលរៀនទៅថ្នាក់ទី ១ នៃសាលាពុទ្ធិកបឋមសិក្សាវត្តនោះ ។

រៀងរាល់ថ្ងៃ ពេលចេញពីរៀន សាមណេរ សន និមន្តទៅបិណ្ឌបាតក្នុងភូមិឧបាសក-ឧបាសិកា យកទៅចិញ្ចឹមញោមស្រី ។ ក្រៅពីគំនក់ច្របាច់និងប៉ះពាលដល់សព្វាង្គកាយមាតា, សាមណេរ សន បានទំនុកបម្រុងឥតខ្ចោះ ព្រោះញោមស្រីលោក ប្រកបដោយវ័យជរាទុព្វលភាព ពន់ពេកណាស់ទៅហើយ ។

ការគោរពថែរក្សាញោមស្រី ដែលសាមណេរ សន បានប្រព្រឹត្តជារៀងរាល់ថ្ងៃនោះ បណ្តាលឲ្យឧបាសកចំណុះវត្ត មានសេចក្តីជ្រះថ្លា ចំពោះព្រះពុទ្ធសាសនាក្រៃលែង ទាំងបានជាគំរូដ៏ល្អសម្រាប់សាមណេរដទៃទៀតផង ។

## សំណួរ

១– **ចូរពន្យល់ពាក្យ** : សាមណេរ កុមារ សព្វាង្គកាយ ជរាទុព្វលភាព ។

២– **ចូរកសទិសសព្ទនឹងពាក្យ** : កម្ម ឆ្នាំ វត្ត ។

៣– តើលក្ខណៈរបស់សាមណេរ សន ដូចម្តេចខ្លះ ដែលនាំឲ្យឧបាសកឧបាសិកាមានសទ្ធាជ្រះថ្លា ចំពោះព្រះពុទ្ធសាសនា ។

៤–តើសព្វថ្ងៃលោកបានប្រតិបត្តិដូចម្តេចខ្លះ ចំពោះញោមរបស់លោក? ព្រោះហេតុអ្វី?



www.budinst.gov.kh www.elibraryofcambodia.org

# សេចក្តីស្នេហារបស់មាតាបិតា

● មាតាបិតា មានសេចក្តីស្នេហាចំពោះបុត្រធីតាឥតរើសមុខ ។ គាត់តែងមានកិច្ចសង្គ្រោះជាច្រើនប្រការ:

● បញ្ជូនកូន ឲ្យចូលទៅសិក្សាក្នុងសាលា ដើម្បីឲ្យកូនបានចេះដឹងសព្វមុខវិជ្ជា ទុកជាប្រទីបសម្រាប់បំភ្លឺរបរាងទៅអនាគត ។

● ស្តីបន្ទោសប្រៀនប្រដៅ ទូន្មានកូន ឲ្យប្រព្រឹត្តអំពើល្អ វៀរចាកការប្រមាថមើលងាយចាស់ព្រឹទ្ធាចារ្យ និងការខ្ជិលច្រអូស ទម្រន់ក្នុងការងាររបស់ខ្លួន ។

● រកគូស្រករឲ្យកូន តាមឋានៈ និងជាតិកំណើត នៃវង្សត្រកូលរបស់ខ្លួន មិនឲ្យម្ខាងខ្ពស់ជាងម្ខាង ។

● ចែកទ្រព្យមត៌កឲ្យកូនស្មើភាគ តាមកាលសម័យ ដោយឥតមានការទឹកស្តាយផល់តិចតួច ។

ដោយសេចក្តីស្នេហានិងការទំនុកបម្រុងនេះហើយ ទើបលោកអ្នកប្រាជ្ញ មានព្រះពុទ្ធជាដើម បានសន្មតមាតាបិតាថាជា ព្រះព្រហ្ម ជាបុព្វទេវា និងជបុព្វាចារ្យរបស់បុត្រធីតា ។

## សំណួរ

១– ចូរពន្យល់ពាក្យ : សង្គ្រោះ អនាគត ប្រមាថ វង្សត្រកូល ។

២-តើមាតាបិតាមានការកិច្ច សង្គ្រោះបុត្រធីតា ដោយស្ថានយ៉ាងណាខ្លះ? ចូរពន្យល់។

៣— តាមអត្ថបទ ពុំបាននិយាយពីកិច្ចដែលមាតាបិតា នាំកូនឲ្យចូលមកបួសសោះ តើលោកយល់បែបណា ចំពោះមាតាបិតាដែលនាំលោកឲ្យបួសនេះ ។

៤– ចូរលោករៀបរាប់ អំពីសេចក្តីស្នេហា របស់មាតាបិតា ទៅលើបុត្រធីតា ។



www.budinst.gov.kh www.elibraryofcambodia.org

# សម្រង់អត្ថបទ

ប្រធានសព្ទ

សម្រាប់ថ្នាក់ឆ្នាំទី ២

នៃ

សាលាពុទ្ធិកបឋមសិក្សា

ក្នុង

កម្ពុជរដ្ឋ

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

## មុខវិជ្ជានៅពុទ្ធិកសិក្សា

● វិជ្ជាខាងសាសនាគឺ បាលី សំស្ក្រឹត វិន័យ ពុទ្ធប្បវត្តិ ព្រះពុទ្ធសាសនា និងសាសនាក្នុងសកលលោក ។ ចំណែកខាងវិជ្ជាផ្លូវលោកគឺ ភាសាជាតិ ភាសាបារាំង ភាសាអង់គ្លេស ប្រវត្តិវិទ្យា ភូមិវិទ្យា គណិតវិទ្យា ធម្មជាតិវិទ្យា អនាសម័យ រូបវិទ្យា-គីមី និងទស្សនវិជ្ជា ។

វិជ្ជាផ្លូវលោក ដែលបញ្ចូលក្នុងកម្មវិធីសិក្សា រួមជាមួយនឹងផ្លូវសាសនា នៃពុទ្ធិកសិក្សាទាំងបីផ្នែកនោះ ដោយមានគោលបំណងចង់ឲ្យសមណនិស្សិតបានចេះដឹងនូវវិជ្ជាទាំងពីរផ្នែក ដែលជាគ្រឿងបណ្តុះសតិប្បញ្ញានៃសមណនិស្សិតឲ្យបានរីកទូលំទូលាយឡើង ឲ្យសមដល់ឋានៈរបស់ប្រទេសឯករាជ្យ ដែលមានព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ព្រោះសមណនិស្សិតទាំងឡាយ និងទៅជាអនាគតនៃសង្ឃក្នុងពុទ្ធសាសនមណ្ឌលនៅប្រទេសខ្មែរ ។ ប្រសិនបើសមណនិស្សិតទាំងឡាយបានសិក្សាចេះដឹងគ្រប់គ្រាន់ ហើយបានឋិតនៅក្នុងភេទជាបព្វជិតតទៅ ក៏ជាការប្រសើរក្រៃលែង ព្រោះសមតាមគោលបំណង ។ បើមិនអាចឋិតក្នុងភេទបព្វជិតទេ ហើយសិក្ខទៅជាគ្រហស្ថ ក៏នឹងបានទៅជាពលរដ្ឋជាតិខ្មែរអ្នកចេះដឹងវិជ្ជាផ្លូវព្រះពុទ្ធសាសនានិងផ្លូវលោកគ្រាន់បើជាងពលរដ្ឋ ដែលមិនចេះដឹងនោះទៅដែរ ។

សម្តេចព្រះពោធិវង្ស ហួត—តាត

ទស្សនាវដ្តី ពុ. សិ. លេខ ១៥ ខែ មេសា ៦៦

### សំណួរ

១— ចូរពន្យល់ពាក្យ: ពុទ្ធប្បវត្តិ ភាសាជាតិ សមណនិស្សិតសតិប្បញ្ញា។



www.budinst.gov.kh www.elibraryofcambodia.org

២- ភាសានិងវេយ្យាករណ៍ មានន័យប្លែកគ្នាយ៉ាងណាខ្លះ ? ចូរពន្យល់ ។

៣- នៅពុទ្ធិកសិក្សា មានមុខវិជ្ជាអ្វីខ្លះសម្រាប់សិក្សា ? ចូររាប់ ។

---

# ពុទ្ធិកសិក្សាសម័យដើម

● ការសិក្សានៃបព្វជិតពុទ្ធសាសនិក ហៅថា ពុទ្ធិកសិក្សា ។ ពុទ្ធិកសិក្សានេះ កើតមាននៅប្រទេសកម្ពុជា តាំងពីយូរអង្វែងណាស់ហើយ ប៉ុន្តែ ពុទ្ធិកសិក្សានេះ បានប្រព្រឹត្តទៅតាមកាលៈទេសៈ ។ បើគិតពីត្រឹម ឆ្នាំ ១៩១៤ មក ពុទ្ធិកសិក្សា អាចឲ្យកត់សម្គាល់បានដោយមានកម្រិតយ៉ាងជាក់ច្បាស់ ព្រោះកាលនៅគ្រិស្តសរាជ ១៩១៤ រដ្ឋការបានបង្កើតការសិក្សា ខាងព្រះពុទ្ធសាសនាជាដំបូង នៅក្រុងភ្នំពេញ ហៅថា សាលាបាលី ។ តមកនៅគ្រិស្តសករាជ ១៩២២ សាលាបាលី បានប្រែឈ្មោះទៅជា សាលាបាលីជាន់ខ្ពស់ ដោយមានកំណែប្រែរបៀបរបបខ្លះ ។ តាំងពីនោះរៀងមក ពុទ្ធិកសិក្សានេះតែមានការកែប្រែផ្លាស់ប្ដូរបន្តិចម្ដងៗ ដើម្បីឲ្យមានវឌ្ឍនភាព គឺសេចក្ដីចម្រុងចម្រើនឡើងដោយលំដាប់ ប៉ុន្តែទោះបីមានកំណែប្រែយ៉ាងណាក៏ដោយ ពុទ្ធិសិក្សាក៏ស្ថិតនៅក្នុងការចង្អៀតចង្អល់ដដែល ព្រោះក្នុងសម័យនោះ ប្រទេសកម្ពុជា ឋិតនៅក្រោមអំណាចនៃរដ្ឋការអាណាព្យាបាលបារាំងសែស ។

សម្ដេចព្រះពោធិវង្ស **ហួត-តាត**

ទស្សនាវដ្ដី ព. ស. លេខ ១៥ ខែ មេសា ១៩៦៦



www.budinst.gov.kh www.elibraryofcambodia.org

## សំណួរ

១– ចូរពន្យល់ពាក្យ : ពុទ្ធិកសិក្សា គ្រិស្តសករាជវិឡូនភាព អាណាព្យាបាល ។

២– ចូរតែងឃ្លាជាមួយនឹងពាក្យ : ជាក់ច្បាស់ កំណែប្រែរបៀប ។

៣– ចូរស្រង់ពីអត្ថបទនេះ នូវពាក្យដែលជានាមនាម ឲ្យបាន ១០ ពាក្យ ។

៤– ចូររាប់រៀបពីលក្ខណៈ សាលាពុទ្ធិកបឋមសិក្សាសម័យដើម ។

## អំពីសិស្សល្អ

សារុន ជាសិស្សម្នាក់ បានចូលទៅស្នាក់នៅក្នុងវត្ត ក្នុងសំណាក់លោកគ្រូចៅអធិការ តាំងពីតូចមក, សារុន ជាកូនកំព្រា មាតាបិតាទទួលអនិច្ចកម្មចោលទៅ។ តាំងពីអាយុប្រាំមួយឆ្នាំម្ល៉េះ បានចូលទៅសិក្សានៅសាលាបឋមសិក្សាវត្តប្រាសាទ ។ វាមានចរិយាសណ្ដាប់ធ្នាប់រមទម ពុំច្រឡោងខាមនិងពុំមានទោសបានដល់ជនណាម្នាក់ឡើយ ទោះបីនៅក្នុងវត្ត ក៏ដូចជានៅក្នុងសាលារៀនដែរ ។ ដូច្នេះ សារុន មិនដែលមានរឿងរ៉ាវ អធិករណ៍ ជម្លោះទាស់ទែងដល់ម្ដងណាសោះ ។ ឥឡូវនេះ សារុន បានចូលកាន់បព្វជ្ជាជាសាមណេរ ហើយបានចូលទៅសិក្សានៅសាលាពុទ្ធិកបឋមសិក្សាវត្តប្រាសាទ ដែលលោកគ្រូតែងហៅថានេន រុន ។

● សិស្សកំព្រានេះ ឥតញោមពិតមែន, ប៉ុន្តែចេះសម្អាតស្បង់ចីពរឲ្យស្អាតបាត

ជានិច្ច ។ ឯសៀវភៅសិក្សាទៀតសោត ក៏នេន រុន ចេះសម្អាតមិនឲ្យប្រឡាក់ប្រឡូសដែរ ។ នៅក្នុងបន្ទប់សិក្សា នេន រុន ស្តាប់លោកគ្រូដោយយកចិត្តទុកដាក់ជាទីបំផុត ។ គ្រប់បញ្ហាដែលលោកគ្រូចោទសួរ នេន រុន សប្បាយចិត្តនឹងលើកដៃឆ្លើយជានិច្ច ទោះចម្លើយនោះខុស ឬ ត្រូវក៏ដោយ ។

មេរៀនទាំងអម្បាលម៉ាន ដែលលោកគ្រូដាក់ឲ្យសិក្សា ពុំដែលមានផងណាដែលនេន រុន មិនចាំឡើយ ។ លទ្ធផលជាទីគាប់ចិត្ត គឺនេន រុន ត្រូវបានទទួលរង្វាន់លេខ ១ ប្រចាំឆ្នាំ និងការសរសើរអំពីព្រះឧបជ្ឈាយ៍ ដែលជាអាណាព្យាបាលជានិច្ច ។

## សំណួរ

១— ចូរពន្យល់ន័យនៃពាក្យ: ចរិយារ ឧស្សាហ៍ សប្បាយ ព្រះឧបជ្ឈាយ៍។

២— សិស្សបែបណា ហៅថា គុណនាម ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

៣— ចូរបង្ហាញសេចក្តីសំខាន់ ៗ របស់អត្ថបទនេះ ។

៤— ចូរពិពណ៌នា អំពីសិស្សខ្ជិលម្នាក់ដែលលោកធ្លាប់ឃើញ ។

---

## អតីតសាលាបឋមសិក្សា

● ក្នុងអតីតកាល, សាលាបឋមសិក្សា ស្ថិតនៅតែក្នុងវត្តអារាម ដោយយកកុដិឬឧបដ្ឋានសាលាជាគ្រឹះស្ថានសិក្សា មានព្រះសង្ឃជាគ្រូបង្រៀន ។ លក្ខណៈនៃកម្មវិធី មានព្រំសីមាល្មមប្រើការបាន តាមសមគួរដល់សម័យនោះ ។ ផ្នែកគ្រឿង



www.budinst.gov.kh www.elibraryofcambodia.org

សិក្ខូបករណ៍ មានដីស ទឹកល្បប់ ( ១ ) និងក្ដារឆ្នួនមួយបន្ទះយ៉ាងវែងជាដើម ។

● សម័យនោះគេឃើញមានច្រើនតែយុវកុមារា ដែលបានចូលទៅសិក្សា ឯយុវកុមារី មិនសូវមានទេ ព្រោះគេមានការបមាញើក ចំពោះកាតព្វកិច្ចក្នុងគេហដ្ឋាន ជាកម្មសិទ្ធិ ។ ចំណាត់ថ្នាក់នៃការសិក្សា កុមារាកុមារី ចាប់ផ្ដើមបទនមស្ការថានមោពុទ្ធាយ សិទ្ធំ រួចរៀនស្រះ, ព្យញ្ជនៈ និងអក្សរផ្ទើផើងហើយរៀនអានទន្ទេញសស្ត្រាច្បាប់ក្រម, ក្រមច្បាប់, កេរកាល, ច្បាប់ប្រុស, ច្បាប់ស្រី, ពាក្យចាស់ និងសាស្ត្រាសុបិន ល្មមចេះអានបានលៀនបង្ហូរ គេសន្មតថាសិក្សាចប់ថ្នាក់បឋមសិក្សា ។ យុវសិស្សដែលចង់បន្តវិជ្ជាទៅមុខទៀត ចាំបាច់ត្រូវប្រែភេទពីគ្រហស្ថ ចូលទៅកាន់ផ្នួសរបស់សាមណេរ ។ សាមណេរនោះត្រូវសិក្សាសស្ត្រាផ្សេង ៗ មានសស្ត្រារឿងសុភមិត្រ, ទុំទាវ, មហោសថ, ព្រះជិនវង្ស, នាងកង្រី, វិធុរបណ្ឌិត ជាដើម។ កាលបើសិក្សាចាំមាត់ស្ទាត់ជំនាញហើយ សន្មត់ថាចប់ថ្នាក់មធ្យមសិក្សា ។ យុវសាមណេរនោះ បើចង់បន្តវិជ្ជាទៅមុខទៀត ត្រូវបំពេញឧបសម្បទាជាភិក្ខុភាព ដើម្បីសិក្សាគម្ពីរដីកាផ្សេង ៗ គឺសាស្ត្រាទេសន៏នានា មានទសជាតក៍ ព្រះវេស្សន្តរនិងបញ្ញាសជាតកជាដើម ។ ការសិក្សានេះ គេសន្មតថាជាថ្នាក់បរិញ្ញា ។

## សំណួរ

១– ចូរពន្យល់ន័យនៃពាក្យៈ ឧបដ្ឋានសាលា សិក្ខូបករណ៍ យុវកុមារ កម្មសិទ្ធិ សាស្ត្រា មន្តវិជ្ជា ទសជាតក៍ ។

២– នាម នាមសព្ទ នាមនាម ពាក្យបីម៉ាត់នេះ មានន័យប្លែកគ្នាយ៉ាងណា ។

៣– ចូរតែងអត្ថបទមួយ ស្ដីពីសាលាបឋមសិក្សាជំនាន់ដើម ។

---

១– ស្រុកខ្លះថា ទឹកល្បប ព្រោះមកពីពាក្យថា ការលុប ។



www.budinst.gov.kh www.elibraryofcambodia.org

## ការគ្រប់គ្រងផ្ទះ

● យុវកុមារា យុវកុមារី ក្នុងបុព្វសម័យ ក្រោយដែលបានចូលទៅសិក្សាក្នុងអារាមវត្តហើយ ខ្លះដែលមិនបានបួសជាសាមណេរ ក៏បានចេញចាកវត្ត ចូលមកជួយរកស៊ីប្រកបការងារមាតាបិតា មានរបរកសិកម្ម ពាណិជ្ជកម្មផ្សេងៗ តាមតែករណីយកិច្ចដែលគ្រួសារផ្តល់ឲ្យ តែភាគច្រើន មិនសូវមានមុខរបរណា ក្រៅពីកសិកម្មឡើយ ព្រោះគ្រួសារនីមួយៗ សុទ្ធតែមានរបរនោះជាត្រីមុខ ។

● យុវកុមារមួយពួក ដែលបានបួសជាសាមណេរ បានរៀនសូត្រចេះដឹងនូវក្បួនច្បាប់ខ្លះៗ ហើយទ្រាំនៅក្នុងសមណេរភេទពុំបាន ក៏សិក្ខាពីបព្វជិតភេទទៅកាន់គហដ្ឋភេទវិញ បានទាមថាបណ្ឌិត ដែលទម្លាប់ហៅខុសថាអន្ទិត ។ ក្រុមសាមណេរ ដែលមានអំណត់ធ្មត់ចំពោះការសិក្សា គម្រប់ ២១ ឆ្នាំ ក៏បានសូមឧបសម្បទាជាភិក្ខុ មាននាទីសិក្សាក្បួនច្បាប់ជ្រៅជ្រះ ចេះទេសន៍ស្ទាត់ជំនាញ ពន្យល់ដឹកនាំប្រជាជន ឲ្យតាំងខ្លួនក្នុងអំពើល្អ លះបង់ទុច្ចរិតធម៌ កាន់យកនូវសុចរិតធម៌ ។

● វដ្តសង្សារចេះតែវិលវល់អន្ទោលទោមកមិនឈប់ឈរ ភិក្ខុសង្ឃអង្គខ្លះទ្រាំនៅក្នុងភេទភិក្ខុមិនបាន ក៏សិក្ខាទៅកាន់ភេទនៃគ្រហស្ថ ៗ ខ្លះបានទៅធ្វើជាឧកញ៉ាមន្ត្រីសេនាបតីរក្សាការពាររដ្ឋ ខ្លះជាអ្នកប្រាជ្ញវង្សករ ខ្លះខំប្រឹងប្រកបរបរអាជីវកម្មជាកសិករឬពាណិជ្ជករ រស់នៅជាមួយអ្នកស្រុកអ្នកភូមិធម្មតា ដោយមានកាតព្វកិច្ចរៀបចំគ្រួសារ តាមទំនៀមទម្លាប់សង្គមជន នៃប្រពៃណីពីដូនតារៀងរាបដរាបមក ។

### សំណួរ

១— ចូរពន្យល់ន័យនៃពាក្យ : បុព្វសម័យ សមណភេទ គហដ្ឋភេទ ។



www.budinst.gov.kh www.elibraryofcambodia.org

២– ចូរតែងឃ្លាជាមួយនឹងពាក្យ : កុមារាកុមារី ករណីយកិច្ច អត់ធ្មត់ ។

៣– ចូរស្រង់យកសង្កាត់សេចក្ដីណាមួយ នៃអត្ថបទនេះ មកពន្យល់ ។

៤– ចូរអធិប្បាយ អំពីជីវភាពរបស់គ្រហស្ថ ។

---

## ពុទ្ធិកសិក្សាសម័យឯករាជ្យ

● លុះតមក ក្រោយពេលដែលប្រទេសខ្មែរ បានតាំងខ្លួនក្នុងឋានៈ ជាប្រទេសឯករាជ្យ រហូតមកដល់បច្ចុប្បន្ននេះ ពុទ្ធិកសិក្សា បានត្រូវរើរៀបចំជាថ្មី ក្រោមកិច្ចមគ្គុទ្ទេស នៃរដ្ឋាភិបាល និង មន្ត្រីសង្ឃគ្រប់ជាន់ថ្នាក់ ដែលមានរដ្ឋមន្ត្រីក្រសួងធម្មការ ជាប្រធានអ្នកគ្រប់គ្រងពុទ្ធិកសិក្សា ក៏បានក្លាយទៅជាពុទ្ធិកសិក្សាមានរបៀបរបបល្អត្រឹមត្រូវ សមតាមសម័យនិយម ។ សម័យបច្ចុប្បន្ននេះ ពុទ្ធិកសិក្សាចែកជា ៣ ផ្នែកគឺ ផ្នែកពុទ្ធិកបឋមសិក្សា សិក្សានូវវិជ្ជាថ្នាក់ដំបូង បានខាងសាលាពុទ្ធិកបឋមសិក្សា នៅក្នុងក្រុងភ្នំពេញ និងនៅគ្រប់ខេត្តក្នុងអាណាចក្រកម្ពុជា ។ ផ្នែកពុទ្ធិកមធ្យមសិក្សា គឺសិក្សានូវវិជ្ជាថ្នាក់មធ្យមបានខាងពុទ្ធិកវិទ្យាល័យ នៅក្រុងភ្នំពេញ និងពុទ្ធិកវិទ្យាល័យ អ៊ឹង ធួង នៅបាត់ដំបង ។

ផ្នែកពុទ្ធិកឧត្ដមសិក្សា គឺសិក្សាវិជ្ជាថ្នាក់ខ្ពស់ ខាងពុទ្ធិកមហាវិទ្យាល័យនៅក្រុងភ្នំពេញ ។ ឯកម្មវិធីសិក្សាក្នុងពុទ្ធិកសិក្សាទាំង ៣ ផ្នែកខាងលើនេះ រដ្ឋាភិបាលបានរើរៀបចំតម្រូវឲ្យមានវិជ្ជាខាងព្រះពុទ្ធសាសនាផង វិជ្ជាខាងផ្លូវលោកផង តាមលំនាំនៃលក្ខណៈ បឋមសិក្សា មធ្យមសិក្សា ឧត្ដមសិក្សាខាងអាណាចក្រ ។

សម្ដេចព្រះពោធិវង្ស ហួត-តាត



www.budinst.gov.kh www.elibraryofcambodia.org

## សំណួរ

១– ចូរពន្យល់ន័យនៃពាក្យ ៖ ប្រទេសឯករាជ្យ ពុទ្ធិកសិក្សា សម័យ និយមរដ្ឋាភិបាល មន្ត្រីសង្ឃ ។

២– ចូររកសទិសសូរសព្ទនឹងពាក្យ ៖ នៅ ឯករាជ្យ ពុទ្ធ ។

៣– ចូររកសទិសន័យសព្ទនឹងពាក្យ ៖ សិក្សា សម័យ ។

៤– ចូរបង្ហាញអត្ថន័យ នៃអត្ថបទនេះ ។

---

## ព្រះពុទ្ធ

● ព្រះពុទ្ធ ជាអង្គអ្នកប្រាជ្ញ មកុដត្រៃភព បានត្រាស់ដឹងនៅថ្ងៃ ១៥ កើត ខែពិសាខ មុនពុទ្ធសករាជ ៤៥ ឆ្នាំ ហើយបរិនិព្វានទៅវិញ នៅថ្ងៃ ១៥ កើតខែពិសាខ មុនពុទ្ធសករាជ ១ ថ្ងៃ ។

ក្នុងកំលុងកាលត្រាស់ដឹង ៤៥ វស្សានេះ ព្រះអង្គពុំបានព្រងើយកន្តើយប្រមាទ ធ្វេសដល់តិចតួចឡើយ ដោយបានគោរពជាប់ នៅពុទ្ធកិច្ចទាំងប្រាំយ៉ាងគឺ ៖ ពេលព្រឹកទ្រង់ចេញបិណ្ឌបាតប្រោសសត្វ ថ្ងៃរសៀលទ្រង់សម្ដែងធម៌ទេសនាពន្យល់ដល់ពុទ្ធបរិសទ័ ព្រលប់ឲ្យឱវាទដល់ពួកភិក្ខុ អធ្រាត្រដោះអាថ៌ប្រស្នាឲ្យពពួកទេព្តា ; ទៀបភ្លឺប្រមើលមើលឧបនិស្ស័យសត្វ ។

ឧត្ដមគតិ ប្រកបដោយព្យាយាមដ៏មុឺងម៉ាត់នេះហើយ ដែលបណ្ដាលឲ្យមានកេរ្តិ៍ឈ្មោះល្បីសុះសាយពាសពេញពិភពលោក រកឧត្តមជនណាមួយមកប្រៀប



www.budinst.gov.kh www.elibraryofcambodia.org

ផ្ដឹម សូម្បីតែមួយចម្រៀកសក់ទី ១៦ ក៏ពុំបាន ។ ភស្តុតាងជាក់ស្ដែង ជនក្នុងលោកទាំងមូលទោះបីពួកបញ្ញវន្ត មានគំនិតប្រកាន់បក្សធ្លាក់ទៅក្នុងលទ្ធិដទៃ មានលទ្ធិគ្រិស្ដ និងមហាម៉ាត់ជាដើម គេក៏ទទួលស្គាល់ថាព្រះពុទ្ធជាអ្នកប្រាជ្ញសាកលលោករហូតដល់ថ្ងៃនេះជាប្រត្យក្ស ។

## សំណួរ

១- **ចូរពន្យល់ន័យនៃពាក្យ៖** អ្នកប្រាជ្ញ មកុដត្រៃភព បរិនិព្វានពុទ្ធសករាជ ប្រមាទធ្វេស ប្រត្យក្ស ។

២- **ចូរតែងឃ្លាជាមួយនឹងពាក្យ** ៖ ព្រះពុទ្ធ ពុទ្ធបរិស័ទ អាថ៌ប្រស្នា បញ្ញវន្ត ។

៣- សំអាងលើហេតុអ្វីខ្លះ បានជាពុទ្ធបរិស័ទនាំគ្នាធ្វើបុណ្យវិសាខបូជា និងមាឃបូជា ។

---

## ចិត្តមាតាបិតា

មាតាបិតា មានភារៈកិច្ចជាទម្ងន់ក្នុងការថែរក្សា ចិញ្ចឹមបីបាច់បុត្រធីតាតាំងពីកូនចូលទៅចាប់បដិសន្ធិក្នុងគភ៌ រហូតដល់បត្រប្រសូត្រចាកឧទរ តពីនេះទៅគាត់បានទំនុកបម្រុងបុត្រធីតាដោយសម្លៀកបំពាក់ និងដោយការឲ្យកូនចូលទៅរៀនសូត្រសព្វសាស្ត្រវិទ្យា ដើម្បីនឹងឲ្យកូនមានអនាគតដ៏ល្អក្នុងការចិញ្ចឹមជីពជន្ម ។

លោកអ្នកប្រាជ្ញ បានឲ្យនាមមាតាបិតាថាជាបុព្វាចារ្យ និងបុព្វទេវា របស់



www.budinst.gov.kh www.elibraryofcambodia.org

បុត្រាបុត្រី ដោយពោលភ្ជាប់ទៅជាមួយនឹងគុណដ៏ធំធេង ប្រៀបដូចជាទឹកនពមហាសមុទ្រ ឬ ភ្នំព្រះសុមេរុ ។ មាតាបិតាស្នេហាកូន ដោយមិនសំឡឹងទ្រព្យសម្បត្តិឡើយ គឺស្រឡាញ់តែកូនដែលស្គាល់គុណបំណាច់ តាមវិថិចិត្តប៉ុណ្ណោះ ។ ទោះបីកូនមានទ្រព្យធនស្តុកស្តម្ភ មានផ្ទះថ្មសសរឥដ្ឋដូចប្រាសាទឥន្ទនិម្មិតក៏ដោយ បើទឹកចិត្តអបលក្ខណ៍ខ្នាំងមឹលស៊ុម៉ឹង សម្តីគំរោះគំរើយសោះកក្រោះផ្លូជាតិ ឃ្លាតពីច្បាប់មនុស្សធម៌ ឬកពាច្រឡោងខាម ប្រមាថមើលងាយចាស់ព្រឹទ្ធាចារ្យ , អ្នកទាំងទ្វេហារ ពិតជាមិនសុខចិត្តទៅទ្រាំទ្រស្ថិ នៅលើផ្ទះកូនបែបនោះឡើយ ។ ទ្រព្យសម្បត្តិដែលគាត់ខំប្រឹងប្រែងរកស៊ី កកាយដី ញីភក់ សន្សំបានមកហើយ ពុំហ៊ានបរិភោគឆ្ងាញ់ ព្រោះហេតុតែចង់ទុកឲ្យកូនប៉ុណ្ណោះ ។ ដូចនេះ បានជាក្រោយពេលរៀបចំអាពាហ៍ពិពាហ៍ ឲ្យកូនមានគូស្រករហើយ បាតាបិតាតែងតែចែកទ្រព្យធនជាកេរមតិកឲ្យទៅកូន ដោយឥតគិតជីវិតអនាគតរបស់ខ្លួន ។

## សំណួរ

១– ចូរពន្យល់ន័យនៃពាក្យ : បដិសន្ធិ ឧទរ គភ៌ ជីពជន្ម បុព្វាចារ្យ បុព្វទេវា អបលក្ខណ៍ ។

២– ចូរតែងឃ្លាជាមួយនឹងពាក្យ : ភ្នំព្រះសុមេរុ វិថីចិត្ត សម្តី ប្រមាថ ។

៣– ចូររកសទិសសព្ទនឹងពាក្យ : គេរ គូ ប្រមាថ ។

៤– ចូរអធិប្បាយ អំពីចិត្តព្រោមស្រីរបស់លោក ដែលលោកបានកត់សម្គាល់ទុក ។



www.budinst.gov.kh www.elibraryofcambodia.org

# ការប្រព្រឹត្តទៅនៃជីវិត

● ព្រះទិនករចរតាមសុរិយវិថី គ្មានពេលសម្រាក ទ្រទិចនាឡិកាដើរគ្រៀន ៗ វាយោបក់រសៀក ៗ ទឹកជ្រោ ផ្រលងបឹងបួហូរសស្រាក់ ឥតស្រាកស្រាន្ត, ជីវិតរស់រវើក, សកម្មភាពមនុស្សមានការមមាញឹកជានិច្ច ។

សិស្សានុសិស្ស ទាំងបព្វជិត ទាំងគ្រហស្ថ នៃសាលាពុទ្ធិកបឋមសិក្សា និងសាលាបឋមសិក្សា ក្នុងអាណាចក្រខ្មែរ បានខំខ្មីឃ្មាតស្រវាស្រទេញយកចិត្តទុកដាក់គោរពមារ៉ាទាំមហស្ចារ្យ ប្រវេប្រវាចម្លងមេរៀន ដែលគ្រូគត់លើក្តារខៀនបញ្ឈរ ។ ក្រុមកសិករ និងពាណិជ្ជករ ស្ទុះស្ទាប្រកបការងារជាចាំបាច់ដែលខ្លួនត្រូវបំពេញ សូម្បីមួយនាទីក៏ពុំមានទំនេរ ។ បក្សាបក្សី ទ្វេបាទចតុប្បាទ និងពហុប្បាទ ជារាត្រីចរ ក៏ដូចជាទិវាចរ តែងតែហោះហើរត្រេចរង្គាត់ចាកចេញពីសំបុក គឺលំនៅស្ថាន ទៅរកភោជ្យភស្តុលៀងជីពជន្ម រៀងរាល់ថ្ងៃ ។

បើយើងបែរភក្ត្រ ចោលចក្ខុទៅមើលពួកព្រានព្រៃ ចរលីលាយាត្រាសព្វច្រកល្ហក តាមផងព្រឹក្សា បរបាញម្រឹគម្រឹគា គ្មានពេលល្ហែ ចាប់យកមកទុកបំប៉នជីវភាព ក្នុងគ្រាដែលខ្លួនមិនទៅប្រម៉ង់ឬប្រមាញ់ ។ សិក្ខាកាមជនគ្រប់រូបខំប្រឹងសិក្សាដោយយកចិត្តទុកដាក់ សព្វទិនទិវារាត្រី ដូចរូបទេពប្រណម្យលើគករប្រណម្យ ឥតសម្រាកមួយវិនាទី ដោយសារតែហេតុនៃជីវិត ព្រោះគេដឹងច្បាស់ថា ក្នុងកាលៈទេសៈណាក៏ដោយ ដើម្បីធ្វើជីវិតឲ្យថ្លៃថ្នូរបាន លុះត្រាជីវិតមានការសិក្សាច្រើន ។



www.budinst.gov.kh www.elibraryofcambodia.org

## សំណួរ

១– ចូរពន្យល់ន័យនៃពាក្យៈ ព្រះទិនករ សុរិយវិថី សិស្សានុសិស្ស។

២– ចូររកសទិសន័យសព្ទនឹងពាក្យ ព្រះទិនករ វារយោ ។

៣– វណ្ណយុត្តិមានន័យដូចម្តេច ? មានប៉ុន្មានយ៉ាង? សម្រាប់ប្រើខុសគ្នាដូចម្តេច?

៤– ចូរពន្យល់ពីអត្ថន័យនៃអត្ថបទនេះ ។

---

## អំពីមុខការ

● មនុស្សម្នាដែលកើតមកហើយ តែងមានជីវិតរស់នៅជាប្រក្រតី ។ កាលបើមានជីវិតហើយ មនុស្សម្នាក់ៗ ត្រូវតែមានមុខងារសម្រាប់ជីវិត ដើម្បីស្ទួយអត្តភាព ឲ្យមានដំណើរឆ្ពោះទៅកាន់វឌ្ឍនភាព នាអនាគតកាល ។

● មនុស្ស មានមុខងារច្រើនប្រភេទ ហើយផ្សេងៗគ្នាទៀតផង គឺខ្លះជាសិក្សាករ កសិករ ពាណិជ្ជករ ឧស្សាហករ កម្មករ ស្ថាបត្យករ វិស្វករ គ្រូបង្ហាត់ គ្រូបង្រៀន សាស្ត្រាចារ្យ អធិការសាលាឧទ្ធរណ៍ អ្នកនិពន្ធនិងខ្លះមានភារកិច្ចខាងសម្អាតគេហដ្ឋាន មិនឲ្យមានមន្ទិលសៅហ្មង ។ លក្ខណកិច្ចនេះ បើនរណាមួយ ឥតការងារ គេសន្មតថាជាជនអាវាសែ រស់នៅលើផែនដី ឥតសារប្រយោជន៍អ្វីសម្រាប់តបស្នងសងគុណមាតុប្រទេស ។ នរជនជំពូកនោះបណ្ឌិតធម្មកោវិទ ឲ្យឈ្មោះថា រស់ដោយគ្រាន់តែដកដង្ហើម ដេកថ្ងូរហ៊ុមចាំតែថ្ងៃអន្សាន់នឹងអាលស្លាប់ បាតបង់រូបកាយក្លាយជាកេរ្តិ៍អសោចិ ។



www.budinst.gov.kh www.elibraryofcambodia.org

● មនុស្សឥតការងារ តាមវោហារអ្នកប្រាជ្ញ លោកអនុម័តចាត់ថាជាជនអន់ថោកថយ មនុស្សកម្ជិលជាមេរោគកាចសាហាវបំផុត ហើយឈមមុខទៅរកសេចក្តីវិនាសជានិច្ចផង ។ ឯមនុស្សបរិសុទ្ធ ពិតជាមានពង្សល្អ ត្រូវតែមានការងារជាចាំបាច់ ព្រោះថា មនុស្សមានជីវិតតិចតួចស្តួចស្តើងមែន តែបើយើងខំរៀន ខំរកខំរិះគិត ខំប្រព្រឹត្តកាតព្វកិច្ច អាចចាត់បានថាជាមនុស្ស រស់នៅរាប់សតវត្ស ។

### សំណួរ

១- ចូរពន្យល់ន័យនៃពាក្យៈ ប្រត្យក្ស អត្តភាព ស្ថាបត្យករ ធម្មគោរវិត អសោចិ សតវត្ស ។

២- ចូរធ្វើកិរិយាទាំងនេះឱ្យទៅជានាមៈ បរិសុទ្ធ សន្មត មគ្គុទ្ទេស ឧបត្ថម្ភ ប្រព្រឹត្ត បរិបូរ ប្រវញ្ច សម្ដោធ ពិសោធ ។

៣- ខណ្ឌសញ្ញាមានប៉ុន្មានយ៉ាង ? ចូររាប់និងពន្យល់ឲ្យសព្វគ្រប់ ។

៤- ចូររៀបរាប់អំពីមុខងាររបស់លោក ដែលត្រូវប្រព្រឹត្តសព្វថ្ងៃ ។

---

## សេចក្តីព្យាយាម

● សេចក្តីព្យាយាម ជានិមិត្តរូបមួយ ឧប្បត្តិកចេញពីជីវិត ដែលប្រែថាការរស់នៅ ។ ទន្ទឹមនឹងរូបន័យខាងលើនេះ អាចចង្អុលឲ្យយើងយល់យ៉ាងជាក់ស្បាន់ នូវសម្ពហភាពបុព្វកាល ដែលពេលនោះប្រជាជនពុំមានសេចក្តីព្យាយាម គេចូលចិត្តរស់នៅក្រោមបញ្ជាការធម្មជាតិ, បណ្តោយអាត្មា ឲ្យទៅតាមបង្គាប់



www.budinst.gov.kh www.elibraryofcambodia.org

ធម្មជាតិពុំមានមធ្យោបាយរៀបចំខ្លួន ឲ្យផុតពីធម្មជាតឡើយ ។

បុព្វសម័យ មនុស្សរស់នៅក្នុងព្រៃភ្នំក្រមថ្ម យកស្លឹកឈើធ្វើជាគ្រឿងអលង្ការតុបតែងសព៌ាង្គកាយ យកញកបពិតមានលេណដ្ឋានជាអាទិ ធ្វើជាលំនៅស្ថាន ។ វស្សានរដូវ គេស្ថាបនាគេហដ្ឋានលើទីទួល ដែលផុតពីទឹកលេច លុះដល់គិម្ហរដូវខែចេត្រ មេឃារាំងថែស ផុតពីព្យុះព្យោមា នាំគ្នាពកូនជញ្ជូនចៅ ដឹកនាំទញសម្ភារៈទៅតាំងលំនៅ នៅតាមមាត់គ្រពាំងបឹងបួ ទីថ្លុកដែលមានទឹកដើម្បីជីវភាព។ ការប្រព្រឹត្តិបែបនេះ ស្ថិតនៅអស់រយៈពេលច្រើនសតវត្ស តែបន្ទាប់មកការសិក្សាក៏បានលូតលាស់ផុះផាល មនុស្សភាគច្រើនបានផុះខាត់ចិត្តយ៉ាងប្រណិត បញ្ចេញសមត្ថភាពតាំងចិត្តប្រឆាំងដោយម៉ឺងម៉ាត់ដាច់អហំការ តវ៉ាជាមួយធម្មជាតិ រិះរកគ្រប់កលោបាយ បង្កបង្កើតកសាងផ្ទះសម្បែង ឲ្យស្ថិតស្ថេរចិរកាល ជីកស្រះ អណ្ដូងទប់ទំនប់យកទឹកសម្រាប់ប្រើប្រាស់ ក្នុងគ្រួសារ ។ គេដាំរុក្ខជាតិផ្សេង ៗ ហើយកាប់យកទៅធ្វើជាឧបករណ៍ជីវិត ទាញជីវិតឲ្យតាំងនៅលើវឌ្ឍនភាព ធ្វើធម្មជាតិឲ្យវិលមកជារណបមនុស្សលោកវិញ ។

## សំណួរ

១- ចូរពន្យល់ន័យនៃពាក្យៈ និមិត្តរូប ឧប្បត្តិក សម្ហូភាពបុព្វកាល លេណដ្ឋាន កលោបាយ ឧបករណ៍ ។

២- ចូរធ្វើឃ្លាជាមួយនឹងពាក្យ : រូបន័យ រៀបចំ គ្រឿងអលង្ការ មេឃា មែកឈើ ។



www.budinst.gov.kh www.elibraryofcambodia.org

៣– វដ្ដរមានន័យដូចម្ដេច? មានប៉ុន្មានយ៉ាង? ចូរប្រាប់និងពន្យល់ឲ្យច្បាស់លាស់ ។
៤– ចូរស្រង់យកឃ្លាណាមួយ មកពន្យល់អំពីមុខងារ នៃពាក្យទាំងនោះ ។

---

## សត្វរុយនិងមូស

● អ្នកវិទ្យាសាស្ត្រ ប៉ែកខាងអនាម័យ បានត្រិះរិះពិនិត្យពិច័យ ពិសោធ ឃើញជាក់ស្បាន់ នូវអំពើអបលក្ខណ៍ របស់ប្រភេទសត្វរុយ និងសត្វមូស ដែលវានាំមកនូវរោគាពាធយ៉ាងកាចសាហាវ ដល់មនុស្សលោក ស្ទើរតែគ្រប់មជ្ឈដ្ឋាន ។

● រុយជាសត្វ មានជើងប្រឡាក់ប្រឡូស ដោយវត្ថុស្មោកគ្រោកជាអតិបរមា ។ វាចូលចិត្តជាបឋម ចំពោះការហើរទំលើវត្ថុមិនស្អាតមានលាមក សម្បោរ និងស្លេស្មជាដើម ។ បន្ទាប់ពីទំលើវត្ថុស្មោកគ្រោកនោះ វាហើរលឿនស្ទើរ ននៈនរនាទមកទំលើភាជន៍ដែលពោរពេញដោយភោជន ពេលនេះហើយដែលវាអាចនាំមកជាមួយ នូវមេរោគសាមាន្យ ផ្ដល់ឲ្យមនុស្សអ្នកបរិភោគភោជ្យភស្តុ ។

● បើយើងពិនិត្យដោយអត្ដនោម័ត ទៅមើលសត្វមូស ក្នុងរាត្រីកាល ; យើងអាចសន្និដ្ឋានច្បាស់លាស់ ចំពោះមូលហេតុសត្វមូសវាចម្លងមេរោគ ពីអ្នកជំងឺម្នាក់ ដែលមានសុខភាពមិនបរិបូណ៌ មានសរីរាង្គកាយទុរន់ទុរា បញ្ចូលដោយចំពុះមួលស្រួចផ្ដល់ទៅឲ្យជនម្នាក់ទៀត តាមសរសៃឈាម ក្រោយពីពេលដែលវាបានជញ្ជក់ឈាមអ្នកជំងឺរួច ។

● យើងត្រូវតែបំបាត់ឲ្យផុតពូជផង សត្វរុយនិងមូស ដោយវិធានការបោសសម្អាតដីធ្លីជានិច្ច ថែមទាំងកុំឲ្យមានថ្លុកជ្រាំស្អុយក្រខ្វក់ និងសម្រាមសម្រោចស្អិត



www.budinst.gov.kh www.elibraryofcambodia.org

នៅជុំវិញគ្រឹះស្ថានទៀតផង ព្រោះវត្ថុទាំងនេះ ជាមេក្រុមធំបំផុតក្នុងការបង្កើនជំនួញមេរោគ ។

## សំណួរ

១– ចូរពន្យល់ន័យនៃពាក្យ : វិទ្យាសាស្ត្រ អនាម័យ ពិនិត្យពិច័យ រោគាពាធ អតិបរមា ភោជ្យភស្តុ ននៈនរនាទ ។

២– វណ្ណយុត្តិធម្មតា មានអត្ថន័យដូចម្តេច ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

៣– ចូរអធិប្បាយអំពីសកម្មភាពរបស់សត្វរុយ ។

---

## ទិដ្ឋារពទ្យ

● បុរាណសម័យ កម្ពោជិកជន ប៉ុនប្រសប់ជាអតិបរមាចំពោះមធ្យោបាយរិះរក ឫសកែវធម្មជាតិមកវិភាគធ្វើជាឱសថ សម្រាប់ការពារ កម្ចាត់រោគាពាធ ដែលវាដេតសំកុកត្រាំរុំរៃ ក្នុងសរីរាវយវៈ ។ ពេលនោះប្រជាជនមួយក្រុមធំ បានធូរធារចាកមរណភ័យ ដោយសារកំណាវល្វាវៃ នៃវេជ្ជបណ្ឌិតពិនិត្យឫសឈើធ្វើជាថ្នាំកែរោគ ។ ចំណេរចីរកាលមក មនុស្សកាន់តែមានចំនួនច្រើន ប្រាជ្ញាវៃឆ្លាតក៏ឆ្លៀតឱកាសពង្រីកសកម្មភាព តាមសម័យនិយម , អ្នកប្រាជ្ញផ្នែកវិទ្យាពេទ្យបានផុះផុសឡើងដូចផ្សិត កលល្បិចផ្សំឱសថដ៏ពិសិដ្ឋ ។ ក៏បានឧប្បត្តិកដើម្បីផ្តាញ់ផ្តាលពពួកមេរោគកាចៗដូចជារោគរបេងរីងរៃ, រោគឫសដូង , រោគមហារីក , រោគគ្រុនចាញ់, រោគអុតកញ្ជ្រិល និងអាសន្នរោគជាដើម ។ អាការរោគ ត្រូវទទួលបរាជ័យយ៉ាងពេញមុខ ជាមួយសម្មាដៃទំនើប នៃអ្នកវិទ្យាពេទ្យនិយម សម័យបច្ចុប្បន្ន ។



www.budinst.gov.kh www.elibraryofcambodia.org

● លក្ខណៈនៃវិជ្ជាពេទ្យ មានគុណសម្បត្តិពិចិត្រ ចំពោះវិធានការសម្លាប់រោគទាំងពួង ក្នុងអតីតសម័យ តែបើប្រៀបមកបច្ចុប្បន្ននេះ ឃើញថាពុំបានសក្តិសិទ្ធិទាន់សម័យនិយមទេ ព្រោះគេអាចពិនិត្យផ្ទុះមើលប្រភពអាការរោគ ដោយពន្លឺអគ្គិសនី និងពិសោធមូលដ្ឋានរោគ ឲ្យស្គាល់ច្បាស់សិន ទើបប្រើថ្នាំជាខាងក្រោយពិសេសទៅទៀត គេអាចរះកាត់និងតភ្ជាប់បានដោយងាយ ។

## សំណួរ

១- ចូរពន្យល់ន័យនៃពាក្យ : ឱសថ មរណភ័យ សកម្មភាព ពិសិដ្ឋ អាសន្នរោគ ។

២- ចូរតែងឃ្លាជាមួយនឹងពាក្យ: សត្វល្អិត វិភាគ ឈ្មោសវៃ ផ្ដាច់ផ្ដាល ។

៣- ចូររកសទិសន័យសព្ទនឹងពាក្យ: អាត្មន ។

៤- ចូររាប់អំពីឈ្មោះនៃរោគទាំងឡាយ ដែលលោកបានដឹង ? តើលោកត្រូវធ្វើដូចម្ដេច ដើម្បីការពាររោគទាំងនោះ ។

---

## កសិកម្ម

● កសិកម្ម ជារបរមួយសំខាន់បំផុតនៅក្នុងប្រទេសខ្មែរ ។ ក្នុងមួយឆ្នាំ ៗ កសិករខ្មែរ ខ្លះប្រកបការងារខាងដាំដំណាំផ្សេង ១ មានសណ្ដែក ពោត ល្ង ស្ពៃ ស្ពៃមើម ថ្នាំ ត្រឡាច ននោង ដំឡូង ល្ពៅ អំពៅ ។ ខ្លះខាងដំណាំ ដូង



www.budinst.gov.kh www.elibraryofcambodia.org

ល្ហា ចេក ល្មុត មង្ឃុត សេដា ព្រលព្រិល ព្នៅព្នាល សាវម៉ាវ ត្លលេន ទុរេន មៀន មាក់ប្រាង ចាន់ ត្របែកព្រៃ ស្វាយ ។ ខ្ទះប្រកបរបរខាងដំណាំស្រូវប្រាំង ស្រូវវស្សា ដែលជារបរចាំបាច់បំផុត សម្រាប់លៀងជីវិតជន ។

● រៀងរាល់ឆ្នាំ ផលិតផលស្រូវ អាចផ្តល់លទ្ធភាពជាអតិបរមា សម្រាប់ចិញ្ចឹមខេមររដ្ឋ រហូតដល់នាំចេញយកទៅលក់ឯបរទេស ជាច្រើនទៀតផង ។ រីផលដំណាំផ្សេង ៗ ក្រៅពីស្រូវនេះ មានរបរនេសាទមួយទៀត ដែលសំខាន់ណាស់ដែរ ដោយទឹកដីកម្ពុជា ប្រកបដោយស្ទឹង ត្រពាំង បឹងបួ ជាពិសេសគឺទន្លេសាប ដែលសម្បូណ៌ដោយមច្ឆជាតិ សម្រាប់ផ្តល់ដល់សេចក្តីត្រូវការនៃពលរដ្ឋ ទាំងជាសេដ្ឋកិច្ចមួយដ៏ពិសិដ្ឋ សម្រាប់នាំចេញទៅលក់ឯប្រទេសនានា ។

● ប្រទេសកម្ពុជា បរិបូណ៌ផលកសិកម្មយ៉ាងនេះហើយ ទើបរដ្ឋាភិបាលសង្គម បានចាត់ចែងឲ្យមានក្រសួងមួយ ហៅថា ក្រសួងកសិកម្ម ដើម្បីពិនិត្យនិងពង្រីក ចំពោះផែនការសេដ្ឋកិច្ច ឲ្យរឹងរឹតតែមានដំណើរទៅរកសេចក្តីចម្រុងចម្រើនជានិច្ចនិរន្តរ៍ ។

## សំណួរ

១– **ចូរពន្យល់ន័យនៃពាក្យ** : កសិកម្ម កសិករ ផលិតផល លទ្ធភាព មច្ឆជាតិ ផែនការ ។

២– នៅខេត្តណាខ្លះ ដែលពលរដ្ឋយើងប្រកបរបរកសិកម្មខាងដំណាំពោតច្រើនជាងគេ ? តើខេត្តណា ដែលមានដំណាំស្រូវ ច្រើនជាងគេ ? ចូរឆ្លើយ ។

៣– ចូររាប់ឈ្មោះដំណាំទាំងឡាយ ដែលកើតពីរបរដំណាំ ខាងដីចម្ការ ។

៤– ចូររៀបរាប់ អំពីរបរកសិកម្ម នៅក្នុងស្រុករបស់លោក ។



www.budinst.gov.kh www.elibraryofcambodia.org

## វិធីសាបស្រូវ

● ផ្គរលាន់ក្តុងក្តាំងផ្គែកបន្ទោរផ្គែក ៗ ភ្លៀងធ្លាក់ល្វឹងល្វើយ មេឃមីរស្រទំ ពពករសាត់ទ្រុយ ៗ អណ្តែតត្រសែតលើនភាល័យអាកាសវេហាស៍ កំពូលភ្នំគិរី បព្វតាខ្ពស់ស្កឹមស្កៃ លិចបាត់ក្នុងពពកស្រកានាគ ព្រះពិរុណបង្អុរភ្លៀងជោកជាំ ប្រឹថពី ក្រុមកសិករនាំគ្នាយកស្រូវដែលជ្រើសទុកសម្រាប់ធ្វើពូជ ទៅត្រាំក្នុងទឹក ចំនួនបីថ្ងៃ រួចគេស្រង់យកមកផ្ទុំទុកលើគោក ទាលតែមានដុះលេចពន្លកសិនទើប យកទៅសាបព្រោះលើថ្នាល ។ មុននឹងព្រោះស្រូវពូជ គេត្រូវភ្ជួរដីថ្នាល ដែល គេភ្ជួររួចម្តងហើយនោះសាជាថ្មីទៀត ហើយគេបង្ហូរទឹកចេញឲ្យអស់ ទើបគេយក រនាស់ទៅរាស់អាចម៍បំណះនង្គ័លឲ្យរាបស្មើ ។ បន្តពីនោះ គេយកនង្គ័លទៅភ្ជួរ ឆ្វតជាចង្អូរ ឲ្យមានសណ្ឋានដូចជាភ្លូរងារ ដើម្បីឲ្យទឹកហូរធ្លាក់ទៅក្នុងចង្អូរនោះ នៅពេលភ្លៀងធ្លាក់ម្តង ៗ ។ នៅពេលព្រោចស្រូវពូជនៅលើថ្នាល គេឃើញគ្រាប់ ស្រូវហើរចេញពីកណ្តាប់ដៃអ្នកសាបច្រៀវច្រេ ហាក់បីដូចជាហ្វូងបក្សីហើរបីរដេរ ដាសលើវសុន្ធរា ហើយដេកតម្រៀបត្រៀបត្រា តាមលំដាប់លំដោយគ្នានៅលើភក់ ល្បាប់នៃថ្នាលនោះ ។ ក្រុមកសិករ តែងតែរក្សាថ្នាលនោះមិនឲ្យមានទឹកទេ ក្នុង រវាងបួន ឬប្រាំថ្ងៃ ដើម្បីឲ្យពូជស្រូវដែលសាបនោះចាក់ឫសក្នុងដីសិន ។

### សំណួរ

១– ចូរពន្យល់ពាក្យ : នភាល័យ គិរីបព្វតា ព្រះពិរុណ សណ្ឋាន ។

២– ចូរតែងឃ្លាជាមួយនឹងពាក្យ : ផ្គែកបន្ទោរ បន្ទោបង់



www.budinst.gov.kh www.elibraryofcambodia.org

វេហាស៍ វិហារ គ្រឹហា គ្រះស្ថាន ភ្ជួរ ។

៣— កិរិយាសព្ទ មានន័យដូចម្ដេច ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ? ចូរស្រង់យកឧទាហរណ៍ ពីក្នុងអត្ថបទនេះ ។

៤ — ចូររៀបរាប់អំពីវិធីសាបស្រូវ ដោយមតិផ្ទាល់ខ្លួន ។

---

## រដូវស្ទូង

● ព្រះពិរុណ បង្អុរភ្លៀងជោកជាំព្រះធរណី វាលស្រែពោរពេញដោយទឹកសព្រាត ។ មាន់រងាវកុះករបញ្ចេញសម្រែកត្រូវឡៅទឹកស្រងេះស្រងោច អាណោចអាធ័ម ។ រៀងរាល់ព្រឹក កសិករខ្មែរបាននាំគ្នាភ្ជួររាស់ដីគ្មានពេលបង្អង់ ផុតពីនោះរវាងមួយខែកន្លះ ឬពីរខែ គេនាំគ្នាដកសំណាប យកទៅស្ទូងលើដីដែលរាស់ពង្រាបរួចហើយ ។ នៅលើស្រែដែលមានភាពជាដីកណ្ដោង គេគ្រាន់តែរាស់ឲ្យអស់ស្មៅហើយស្ទូងតែម្ដង ។ ឯស្រែដែលមានភាពជាដីខ្សាច់ គេគប្បីភ្ជួរសាជាថ្មីហើយស្ទូងតាមក្រោយប្រកិត បើមិនធ្វើដូច្នេះទេ ដីនឹងកកក្រទាំងជាំសន្ទូងពុំចុះ ។ រដូវស្ទូងនេះ បងប្អូនកសិករទាំងស្រីទាំងប្រុសទាំងក្រមុំ-កំលោះ បាននាំគ្នាក្រោកចេញពីគេហដ្ឋានឆ្ពោះទៅកាន់កសិដ្ឋាន តាំងពីមាន់រងាវរហូតទល់គ្នានឹងព្រលប់មើលគ្នាមិនចង់យល់ ទើបត្រឡប់មកវិញ ។ គេបញ្ចេញកម្លាំងពលំតតាំងនឹងមុខងារ ទោះបីចុកចង្កេះ ឬនឿយហត់យ៉ាងណាក៏ដោយ គេក៏ពុំធុញទ្រាន់ដល់មួយនាទីឡើយ ។ កិច្ចការមុខក្រសួងនេះ រស់នៅក្រោមមេឃត្រូវភ្លៀងផ្គររលឹមសស្រោក់ និងកម្ដៅថែសពាល់ត្រូវរឿយ ៗ សពាង្គកាយប្រឡាក់ដោយភក់ស្រមក តែគេពុំធុញទ្រាន់ដល់តិចតួចឡើយ



www.budinst.gov.kh www.elibraryofcambodia.org

ចំពោះមុខងារនេះ ។ យូរៗ គេឮសូរមាត់ស្រែកច្រៀងឆ្លើយឆ្លង រវាងក្រុមស្រីៗនិងស្រីៗ ហើយឮសូរមាត់ហៅកញ្ជៀវម្ដងៗ ក្រោយពេលដែលក្រុមខាងណាមួយច្រៀងអន់ជាងគេ។ សង្វាក់ទំនុកច្រៀងកាន់តែពិរោះ ដែចាប់ដើមស្រូវដាំលើព្រះធរណីកាន់តែញាប់ឡើង បណ្ដាលឲ្យសន្ធឹងតម្រៀបគ្នាពេញស្រែគ្មានចន្លោះ ។

## សំណួរ

១– ចូរពន្យល់ន័យនៃពាក្យ : ព្រះធរណី អាណោចអាធ័ម កសិដ្ឋាន ។

២– ចូរប្រាប់មុខងារកិរិយាវិសេសន៍ និងគុណនាម ប្លែកគ្នាយ៉ាងណា?

៣– ចូរបង្ហាញ សកម្មភាពអ្នកស្រុកនៅរដូវស្ទូង ។

---

## វិធីបញ្ចូលទឹកក្នុងស្រែ

● សន្ទូងលូតលាស់បែកមែកសាខា ប្រែសភាពជាស្រូវមានផ្ទៃ តែមិនទាន់ដាក់គ្រាប់ពេញបរិបូណ៌ ។ ជួនជាមេឃមិនបង្អុរភ្លៀង ដីប្រែសភាពពីសើមទៅស្ងួត កសិករនៅតំបន់នោះ បែកគំនិតរិះគិត ចាត់វិធានការរកវិធីបាចទឹកបញ្ចូលស្រែ ។ ខ្លះប្រើវិធីទប់ទឹកស្ទឹង ដើម្បីឲ្យទឹកចាល់ឡើងទៅលើស្រែ ខ្លះប្រើរហាត់ជាន់ទាញទឹកពីត្រពាំង ព្រែក បឹងបួ បញ្ចូលស្រែ, ខ្លះប្រើស្នាចខ្នុកប្រ័ក្សណ៍ បាចបញ្ចូលស្រែ, ខ្លះទៀតយកឈ្នីឈរបាច ដើម្បីផ្ដល់ទឹកដល់ស្រែ ។

● វិធានការបាចទឹកបញ្ចូលស្រែនោះ ភាគច្រើនមានតែក្រុមកសិករដែលធ្វើស្រែប្រាំង គេច្រើនប្រើរហាត់ជាន់ ដែលមានកង្ហារលទៅក្នុងទឹក ទាញទឹករត់



www.budinst.gov.kh www.elibraryofcambodia.org

តាមបំពង់ដោយស្វ័យប្រវត្តិ លុះកង្វិលមកដល់ធ្មេញស្តីផុតបំពង់ ក៏ចាក់ទឹកនោះទៅក្នុងជ្រលង ដែលបង្ហូរទឹកទៅក្នុងស្រែ រួចក៏ត្រឡប់វិលបន្តបន្ទាប់គ្នាមកវិញ ក្រៅពីរហាត់នេះ គេប្រើស្នាចដែលត្បាញពីឫស្សីខ្នុកម្រ័ក្សណ៍ភ្ជាប់ដោយផងសម្រាប់កាន់ប្រហែលមួយម៉ែត្រ ខាងមុខមានមាត់សម្រាប់ដួសយកទឹក, ខាងក្រោយគឺគូទភ្ជាប់ជិតដោយផង ។ គេប្រើស្នាចនេះ ដោយចងនឹងបង្គោលបួន ដែលបោះម្ខាងពីរ នៅសងខាងផ្លូវទឹក ។ គេប្រើស្នាចបែបនេះ បានតែទឹកដែលត្រូវបាចនោះមិនទាបជាងស្រែពេកទេ ។ ប្រសិនបើស្រែខ្ពស់ជាងទឹកពេក គេត្រូវប្រើស្នាចកញ្ជើថ្នាន់ដែលធ្វើដោយឫស្សី មានខ្សែពីរចងមាត់ស្នាច ហើយខ្សែពីរទៀតចងបាតឬគូទស្នាចប្រើដោយមនុស្សពីរអ្នក ម្នាក់ទាញខ្សែមុខមួយខ្សែក្រោយមួយ យោងពីក្នុងថ្លុកជ្រៅហើយចាក់ទៅក្នុងស្រែ ដោយទាញខ្សែមុខយ៉ាងតឹង លុះដល់កន្លែងចាក់គេបន្ធូរខ្សែមុខ ត្រឡប់បន្តឹងខ្សែក្រោយវិញ ។

## សំណួរ

១- ចូរពន្យល់ន័យនៃពាក្យ : វិធានការ វិធី ពិធី ស្វ័យប្រវត្តិ ស្នាច ។

២- ចូរតែងឃ្លាជាមួយនឹងពាក្យ : បញ្ចូល ស្រែ មេឃ ម្រ័ក្សណ៍ធូរ ។

៣- ចូររកសទិសសូរសព្ទនឹងពាក្យ : បួ, ម្រ័ក្សណ៍, ថ្លុក ។

---

## វត្តបច្ចុប្បន្ន

● វេលាបច្ចូសកាល នាកាលព្រះអាទិត្យមិនទាន់បញ្ចេញការស្មីនៅឡើយ



www.budinst.gov.kh www.elibraryofcambodia.org

កាលសត្វរាត្រីចរមិនទាន់ចរចូលសម្បុកនៅឡើយ  សូរសព្ទមាន់រងាវម្តង។ សន្សើមធ្លាក់ស្រាក់ ៗ សំឡេងអ្នកច្រូតស្រូវឮសូរអឺងកងអ៊ូអររំពងទីវាល តាមផ្លូវធំតូច ។ ពួកកសិករមានកណ្តៀវនៅដៃក៏មានថ្តក់លើកក៏មាន ខ្លះបណ្តើរគ្នាខ្សៀវខ្សាដើរត្រសងទៅច្រូតស្រូវទុំ , ខ្លះបររទេះចេញពីភូមិទាំងគ្រួៗសំដៅទៅស្រែដែលនៅដាច់ស្រយាល។

● ព្រះសុរិយង្គ  ចោលរស្មីមីត ក្តៅមហិមា  ញើសហូរសស្រាក់ធ្លាក់លើព្រះធរណី  កម្តៅឧណ្ហ។ ហុយចេញពីសរីរៈកាយយូរ ។ ឃើញគេយកដៃអាវជូតញើសដែលហូរចាកថ្ងាសម្តង ។ ថ្ងៃបណ្តើរក្លនព្រាក ៗ  ចំហាយផ្ទុះមកលើអ្នកច្រូតកាន់តែខ្លាំងឡើងៗ កដៃកាន់តែញាប់ស្មេរ  កណ្តៀវត្រកងស្រូវកាន់តែញឹកដូចផ្លេកបន្ទោរ សូរចម្រៀងផុសឡើង លាយជាមួយនឹងសម្រក់ញើសយ៉ាងពីរោះ ។បង្ហាញឲ្យឃើញថា  គេពុំបានគិតដល់កម្តៅកំណាច  របស់មហាមេឃទាល់តែសោះ ។ មួយស្របក់ស្រូវដែលឈរជង្គ្រឹង  ក្លាយទៅជាកណ្តាប់ដេកត្រៀបត្រាដូចគេតម្រៀប ។

● ព្រះសុរិយ៍ទន់ទេរជ្រេទាបហៀបអស្តង្គត  វាយោបក់រំភើយ ៗ ពពករសាត់គ្រៀន ៗ បក្សាបក្សីទុងទោចខ្លែងស្រាកនិងចាបស្រុកហើរច្រៀវច្រៃ ហ៊ីចហើររកទ្រធំ សំឡេងត្រដោកក្របី និងកណ្តឹងគោរណ្តំដូចគេវាយរនាត អ្នកច្រូតគ្រប់ក្រុមនាំគ្នាដើរត្រសង  ដង្ហែគ្នាជាក្បួន  តម្រង់ទៅកាន់គេហដ្ឋាន ។ ចង្កៀងប្រេងកាតផ្ទុង ៗ គេបានជួបជុំគ្នា  បរិភោគអាហារ  ក្នុងគ្រួសារដោយទឹកមុខញញឹមប្រិមប្រិយគួរ ឲ្យកើតប្រីតាប្រាមោទ្យក្រៃពេក  រដូវច្រូតជារដូវដែលធ្វើឲ្យកសិករសប្បាយរីករាយជាងរដូវស្ទូង  ព្រោះសទ្ធផលដែលប្រឹងតាំងពីដើមឆ្នាំទើបតែផ្តល់ផល ស្រូវមកឲ្យហើយជារដូវឥតភ្លៀងទៀតផង ។



www.budinst.gov.kh    www.elibraryofcambodia.org

## សំណួរ

១- ចូរពន្យល់ន័យនៃពាក្យ ៖ បច្ចុសកាល រាត្រីចរ រស្មីធ៌ត សរីរៈកាយ ។

២- ចូររកសទិសន័យសព្ទនឹងពាក្យ ៖ ព្រះអាទិត្យ, ដេក ។

៣- សមាសនាមនិងសមូហនាម ប្លែកគ្នាយ៉ាងណា ? ចូរពន្យល់ជាឧទាហរណ៍ ។

---

## ចម្រូតស្រូវ

● អ្នកច្រូតយកចំពាស់កណ្ដៀវ ទៅត្រកងគុម្ពស្រូវ ម្ដងមួយគុម្ពឬពីរគុម្ព តាមខ្នងស្ទាត់ ឬ មិនស្ទាត់ លុះដល់ត្រកងបានហើយ គេក៏ត្រឡប់កណ្ដៀវកាត់ពាក់កណ្ដាលឬជាងពាក់កណ្ដាលដើមស្រូវ តាមស្រូវវែងឬខ្លី ។ គេច្រូតបានពីរឬបីដៃហើយ គេទើបចងធ្វើជាកណ្ដាប់ម្ដង នៅស្រុកខ្លះ គេចងដល់ទៅប្អូន ឬប្រាំដៃ ។ កណ្ដាប់តូច ៗ គេយកទៅបោកជម្រុះគ្រាប់ស្រូវ រីឯកណ្ដាប់ធំ ៗ វិញគេយកទៅរៀបបញ្ចាន់នឹងគោ - ក្របី ។

● បើស្រែនោះគោកគេច្រូតហើយ ; គេត្រសាប់ជញ្ជាំងទ្រាប់ពីក្រោមហើយដាក់កណ្ដាប់ពីលើ ។ បើស្រែនោះនៅមានទឹក គេត្រូវធ្វើជើងកុក គឺយកជញ្ជាំងមួយគុម្ព កាច់បត់ជាពីរដោតចំកណ្ដាល ហើយបង្អោនជញ្ជាំងជុំវិញនោះមកគងពីលើ ទើបដាក់កណ្ដាប់សង្កត់ជញ្ជាំងនោះទៅ ។ ធ្វើជើងកុកនេះ គឺបង្ការកុំឲ្យទទឹកស្រូវ ។ លុះដល់គេច្រូតហើយសព្វគ្រប់, គេប្រមូលកណ្ដាប់ធ្វើជាពំនូក ។

រ៉ាយ ប៊ុក កម្ពុជសុរិយា លេខ ៣ ឆ្នាំទី ២១



www.budinst.gov.kh www.elibraryofcambodia.org

## សំណួរ

១- ចូរពន្យល់ន័យនៃពាក្យ ៖ ចម្រូត ស្ងាត់ ច្រូត ពោក បង្គារ ពំនូក ។

២ – ចូររកសទិសសូរសព្ទនឹកពាក្យ ៖ គុម្ព, សព្វ, បត់ ។

៣– ពាក្យថា នាម គុណនាម និងសព្វនាម ប្លែកគ្នាយ៉ាងណា? ចូរពន្យល់ និងបង្ហាញឧទាហរណ៍ ។

៤– សិក្សាអត្ថបទនេះ តើអាចផ្តល់គំនិតដល់លោកដូចម្តេចខ្លះ? ចូរពន្យល់ឲ្យច្បាស់លាស់ ។

---

## ពាណិជ្ជកម្ម

● ពាណិជ្ជកម្ម ជារបររបស់ពលរដ្ឋដែលមានភេទជាគ្រហស្ថ ហើយពុំមែនជាអ្នកធ្វើការរដ្ឋ ។ របរបែបនេះ មានទាទីដែលគេលក់ចេញ ទិញចូលប្រមូលប្រាក់កាស ដីងខាតដីងចំណេញសម្រាប់ទុកធ្វើជាមូលធនលៀងជីពជន្ម ។

ពីមុនមិញ នៅប្រទេសកម្ពុជា ពលរដ្ឋពុំសូវប្រកបមុខរបរនេះទេ ព្រោះពិបាកនឹងដឹងនាំផលិតផលចេញពីជនបទដាច់ស្រយាលមកកាន់ទីរួមខេត្ត ដោយផ្លូវគមនាគមន៍មិនមានបរិបូរណ៍ ហើយអ្នកដែលបង្កបង្កើតផលដំណាំនិងសិប្បកម្មការទៀតសោត ក៏ពុំសូវមានប្រសិទ្ធិភាព។ សតវត្សថ្មីសម័យសង្គមនិយមព្រះពុទ្ធសាសនាបោះជំហានលើទឹកដីសុវណ្ណភូមិ ឯករាជ្យថ្មីផុសធ្លោឡើង រំសេវស្លាបនាជាតិលេចមុខចេញច្បាស់ក្រឡែត កម្លាំងខ្មែរពេញពោរហូរហៀរលើប្រមាត់មាតុភូមិ ផ្លូវចរាចរ



www.budinst.gov.kh www.elibraryofcambodia.org

ពង្រីកខ្លួនដូចការវិធី ដេកសន្ទឹងខ្វាត់ខ្វែងសព្វទិសទីនាព្រៃព្រឹក្សា។ សញ្ញាកម្មនេះ ហើយ ដែលជាសមិទ្ធិប្រណីតសម្រាប់ជម្រុញប្រជាពលរដ្ឋប្រព្រឹត្តិរបរពាណិជ្ជកម្ម បានស្រួលគ្រប់ពេលវេលា ។ បច្ចុប្បន្ននេះ សន្ទុះពាណិជ្ជកម្មបានសូន្យរូប លុក លុយចូលក្នុងសន្តានចិត្តខេមរជនស្ទើរគ្រប់គ្នា សូម្បីតែយុវជនតូចៗ ,ដែលជ្រក ក្រោមបារមីនៃព្រះសង្ឃ ស្នាក់នៅក្នុងអាវាសវត្ត ក៏គេឆ្លៀតពេលលក់ដូររបស់បន្តិច បន្តួចដែរ តាមតែពេលវេលាហុចឲ្យ ។ ពាណិជ្ជកម្ម ជាករណិយកិច្ចមានតម្លៃជាទី បំផុត ក្នុងមុខងារចិញ្ចឹមជីវិត សូម្បីតែនាងវិសាខាឬអនាថបិណ្ឌិកសេដ្ឋី ក្នុងសម័យ ពុទ្ធកាល គេក៏មានមុខរបររកទឹកដោះគោលក់ដែរ ។

## សំណួរ

១— ចូរពន្យល់ន័យនៃពាក្យៈ ពាណិជ្ជកម្ម នាយពាណិជ មូលធន គមនាគមន៍ ។

២— ចូរតែងឃ្លាជាមួយនឹងពាក្យៈ ប្រមូល បង្កបង្កើត ប្រសិទ្ធិភាព ខ្វាត់ខ្វែង ។

៣— ចូររកសទិសសូរសព្ទនឹងពាក្យៈ ចរ, លិច, សង្ឃ ។

---

## អាខិលនិងអាខ្វិច

● ថ្ងៃងពីបុរសពីរនាក់ នៅស្រុកទីទៃពីគ្នា ម្នាក់ឈ្មោះអាខ្វិច ម្នាក់ទៀត ឈ្មោះអាខិល ។ បុរសទាំងពីរនេះ សុទ្ធតែមានមធ្យោបាយប្លែកៗ ពីគ្នា ថ្ងៃមួយ អាខ្វិចបន្ទោបង់ឧច្ចារៈដាក់ក្នុងពាងមួយ រួចបិទអាចម៍លើក្តួចឯស្រោកយ៉ាងស្អាត គួរ ឲ្យពិតពិលរមិលមើល ហើយដើរស្រែកពពាយនាយពាក់ ។ អាខិលបែកប្រាជ្ញាធ្វើ



www.budinst.gov.kh www.elibraryofcambodia.org

កាំបិតមួយ ផ្លែខ្ទីកំប៉ិតប៉ុនចុងចង្កេះនៃអកកំបោរ ។ ឯដងប៉ុនកដៃប្រវែងមួយល្វក ។ អ្នកទាំងទ្វេហារចរយាត្រាជួបគ្នាតាមវិថី ក៏ស្រុះស្រួលបបួលគ្នាផ្ញើរផ្អកនឹងកាំបិតរួចស្រេចហើយ ក៏ធ្វើដំណើរទៅផ្ទះរៀង ៗ ខ្លួន ។ ក្នុងពេលទៅដល់ផ្ទះ, អាខិលប្រើប្រពន្ធដាំបាយឆ្អិន ហើយទាញពាងផ្អកមកជិត រួចល្វកយកផ្អកដាក់ក្នុងចានបាយសល់ជាប់នឹងដៃប៉ុន្មាន ក៏ពមផ្លប់ ១ អស់រលីង ។ ប្រពន្ធយល់ច្បាស់ថាមិនមែនផ្អកទេ ក៏ក្អួតឆ ៗ ចំនួនម្ដៃបាយកម្អួត ។ អាខិលច្រឡោតក្ដៅលាន់មាត់ថាយ៉ះ ! អានេះខ្ចមែន ហ៊ានបន្ទំភ្នែកអញទាំងស្រស់ទេតើ ។

ចំណែកខាងអាខ្ចៈ ទៅដល់គេហដ្ឋាន ខឹងនឹងផ្ដេព្រួសពេក ទាញកាំបិតក្រោក ហក់មកបម្រុងសម្លាប់ផ្ដេ ឃើញផ្លែកាំបិតខ្ទីកំប៉ិត កើតក្ដីអៀនខ្មាស់ ឡើងទៅលើផ្ទះធ្វើមុខខ្មាប៉ៃ ។ ដៃអ្នកបាទយល់ការណ៍ ក៏ដើរកាត់ទៅរកជួបអាខិលរ៉ាយរ៉ាប់ប្រាប់សភាពការណ៍សព្វគ្រប់ ។ បុរសទាំងពីរនាក់ បានសូមគ្នាចងជាមិត្រមានចិត្តមូលតែមួយ មិនបែកខ្វែកគ្នាឡើយ ។

● លុះបានគ្នាជាក្លើហើយ, គូកនទាំងពីរនាក់ បានដឹងថាសេដ្ឋីស្លាប់ក៏បបួលគ្នាទៅប្រវ័ញ្ចយកទ្រព្យពីកូនសេដ្ឋី ។ ក្នុងពេលដែលចាស់ទុំកំពុងសូត្រធម៌ព្រះធម្ម អាខិលឡើងប្រូចចូលដេកក្នុងមឈូសពីលើសពសេដ្ឋី ។ អាខ្ចអានសំបុត្របន្ទំប្រាប់ឲ្យកូនសេដ្ឋីចែកទ្រព្យសម្បត្តិ ព្រោះខ្លួនត្រូវជាកូនធម៌មហាសេដ្ឋី ។

នឹកឆ្ងល់ពេក កូនសេដ្ឋីក៏ស្រែកសួរសពឪពុក ។ អាខិលដែលនៅក្នុងមឈូស ឆ្លើយជំនួសភ្លាម ហើយបញ្ជាឲ្យកូនសេដ្ឋីយកមាសប្រាក់ កែវកងពិទូរ្យស្វារ្យកាន្តមកផ្ទុកក្នុងរទេះ រួចអាខ្ចក៏បរចេញទៅ មិនយូរប៉ុន្មាន អាខិលលប



www.budinst.gov.kh www.elibraryofcambodia.org

ចេញពីមឈូសរត់តាមទៅទាន់អាខ្ទច ហើយនាំគ្នាបរទៅទៀត លុះធ្វើដំណើរទៅឆ្ងាយបន្តិច ឃ្លានបាយពេក ទាំងពីរនាក់ក៏ចែកមុខគ្នា គឺឲ្យម្នាក់នៅចាំរទេះ, ម្នាក់ទៀតទៅរកបាយមកស៊ី ។

បុរសទាំងទ្វេ សុទ្ធតែប្រកបដោយលោភចិត្ត ។ បុរសនៅចាំរទេះ ធ្វើខ្នាវដាក់តាមផ្លូវ ។ ឯបុរសអ្នករកបាយ យកថ្នាំពិសមកលាយនឹងបាយនោះ ។ បុរសអ្នករកបាយ គ្រាន់តែដើរមកដល់ជិត ក៏ត្រូវនឹងខ្នាវស្លាប់ភ្លាម ចំណែកឯបុរសអ្នកនៅចាំរទេះយកបាយមកស៊ី ក៏ពុលស្លាប់មួយរំពេចដែរ ។

## សំណួរ

១– **ចូរពន្យល់ន័យនៃពាក្យ** : បុរស ឧច្ចារៈ ប្រវិញ្ញ តែវពិទូរ្យ - ស្ងួរ្យកាន្ត លោភ ចិត្ត ។

២– **ចូរតែងឃ្លាជាមួយនឹងពាក្យ** : គីរ គី រទេះ ពតិមាន ពុល ។

៣– សិក្សារឿងអាទិលនិងអាខ្ទច ផ្ដល់ឲ្យនូវគំនិតដល់លោកដូចម្ដេចខ្លះ ? ចូរអធិប្បាយ ។

៤– ចូរនិទានរឿងអាទិលនិងអាខ្ទច តាំងដើមដល់ចប់ ដោយវោហារផ្ទាល់របស់លោក ។

---

## ក្អែក ១ ជាក្អែក ១០

● កាលនោះមានបុរសម្នាក់ ធ្វើដំណើរតាមផ្លូវចូលទៅក្នុងព្រៃ ហើយ



www.budinst.gov.kh www.elibraryofcambodia.org

បានប្រទះនឹងរទេះមួយ ដំពោរពេញដោយមាសនិងប្រាក់ដែលគ្មានម្ចាស់ គឺរទេះរបស់អាខិលអាខូចដែលស្លាប់ទាំងពីរនាក់នោះឯង ។ បុរសយល់ច្បាស់ថារទេះនោះឥតមានម្ចាស់បែបនេះ ក៏បម្រុងទឹមរទេះនោះយកទៅផ្ទះ តែដោយគិតឃើញថាក្រែងភរិយាខ្លួនមិនចេះលាក់អាថ៌កំបាំងក្នុងគ្រួសារ លុះគិតដូចនេះហើយ ទើបដឹកគ្របីជាមួយនិងរទេះនោះចូលទៅក្នុងព្រៃ ចងទុកក្រោមដើមឈើមួយរួចដើរទៅផ្ទះហើយនិយាយពិសោធនឹងប្រពន្ធថា « ខ្ញុំទៅព្រៃ បន្ទោបង់លាមក ស្រាប់តែមានក្អែកមួយ ហើរចេញពីវច្ចមគ្គ » ។

● កាលបើភរិយាឮប្តីប្រាក់ដូច្នោះហើយ ក៏នាំពត៌មានទៅប្រាប់អ្នកជិតខាងថា « ស្វាមីនាងបានបន្ទោបង់លាមក ហើយមានក្អែក ២ ហើរចេញពីវច្ចមគ្គ » ។ ដំណឹងនេះចេះតែឮខ្ចរខ្ចាយត ៗ គ្នាពីមាត់មួយទៅមាត់មួយ រហូតដល់ល្បីថា មានក្អែក ១០ ហើរចេញពីវច្ចមគ្គ ។ ពេលនោះប្រមុខនគរបានជ្រាបរឿងនុះហើយ ទើបប្រើអាមាត្យ ឲ្យទៅហៅបុរសនោះមកគាល់ ដើម្បីបានជ្រាបពត៌មានច្បាស់ ។ បុរសនោះបានចូលមកក្រាបបង្គំទូលរឿងពិតចំពោះប្រមុខនគរ អំពីការពិសោធន៍នឹងភរិយា ។ ស្តេចទ្រង់ប្រើឲ្យបុរសទៅយករទេះព្រមទាំងភណ្ឌៈមកថ្វាយព្រះអង្គ ។ នាកាលបុរសនោះនាំយករទេះ ព្រមទាំងមាសប្រាក់មកថ្វាយហើយ, ប្រមុខនគរបានដកយកមាសប្រាក់ពាក់កណ្តាលរទេះ ដើម្បីដាក់ជាទ្រព្យឃ្លាំង នៅសល់ពាក់កណ្តាលទៀត ក៏ប្រគល់ឲ្យបុរសនោះ ដើម្បីទុកជាទ្រព្យផ្ទាល់ខ្លួន ។



www.budinst.gov.kh www.elibraryofcambodia.org

## សំណួរ

១— ចូរពន្យល់ន័យនៃពាក្យ : វត្ថុមគ្គ លាមក អាមាត្យ ។

២– ចូរតែងឃ្លាជាមួយនឹងពាក្យ : ពោរពេញ ភរិយា ប្រគល់ ។

៣ — ចូរនិទានរឿងក្អែក ១ ជាក្អែក ១០ ព្រមទាំងបញ្ជាក់ដើមហេតុរបស់រឿងផង

---

## ផ្សារនៅជនបទ

● ផ្សារជាទីប្រជុំទំនិញ, តាមធម្មតា នៅគ្រប់ជនបទសុទ្ធតែមានផ្សារជានិច្ច ។ ទីផ្សារនេះ កើតឡើងពីចំនួនមនុស្ស ព្រោះមនុស្សមានច្រើន គេនាំគ្នាលក់ដូរទំនិញក៏ច្រើនដែរ គឺគេលក់នេះខ្លះ នោះខ្លះ យូរ ៗ ទៅពោរពេញទាំងទីប្រជុំៗ

● ផ្សារជាគ្រឹះស្ថាន មានដំបូលប្រក់ក្បឿង ឬស័ង្កសី តែគ្មានជញ្ជាំងទេ មានតែសសរឈើឬឥដ្ឋធំ ៗ ។ នៅក្នុងទីផ្សារនោះ មានលក់សម្ភារៈ ស្ទើរគ្រប់មុខ ណាល្វែង ជារបស់កម្មសិទ្ធិម្នាក់ ១ ក្នុងល្វែងនីមួយ ៗ មានមនុស្សប្រុសស្រីអង្គុយលក់ដូរលើតាំងតូច ៗ មានកញ្ជ្រែងត្រៀបត្រានៅពីមុខ ។ នៅល្វែងទាំងនោះគេឃើញមានត្រសក់ ត្រកួន ត្រឡាច ក្រឡុក សណ្តែកទ្រើងសណ្តែកបណ្តុះស្ពៃស ស្ពៃខ្មៅ សាឡាត់ ខាត់ណា សារាយ សត្តបង្គ័ជ សេតុប្បល រត្តុប្បល ល្ពៅ ទំពាំងឫស្សី ដូង ស្វាយ - ទុំ ម្ទេស ថ្នាំ ជំឡូង ត្រាវ ។ ល ។ រាងលក់ខ្លះ មានលក់បច្ចា គ្រប់បែប ដូចជាត្រីរស់ ឆ្តោ ការហោ ចង្វា សណ្តាយ ក្រុសក្រាយ ឆ្ពិនផ្ទក់ ក្រាញ់ អណ្តែង ក្រពត ផ្សោត ប្រឡែល ឆ្លូញ ស្វាត ច្រកែង កែស គ្រុំ គជ្រាំ

កំពិសជាដើម ។ ក្រៅពីនោះមានរានលក់សាច់ជ្រូក សាច់គោ ទាំងភ្លៅ ។ ឈាម ហូរស្រោក់ ព្យួរណែងណោង ចម្រុះនិងសាច់ត្រក ប្លែកៗតែសត្វស្វាប មានមាន់ ទា ប្រវីក គេចងជើងដេករង៉ោកនៅលើដី។ មនុស្សស្រីប្រុសប្រជ្រៀតគ្នាឮអឺះអ៊ះ បែកញើសថ្វាស់ប៉ះគ្នាមុខក្រោយ តថ្លៃទំនិញជាមួយនឹងអ្នកលក់។ នៅតាមបរិវេណ ជិតទីផ្សារ មានពួកអ្នកលក់ចំណីអាហារ គឺគុយទាវ នំបញ្ចុក ចេកចៀន បបរ បាយម្ហូប នំលត នំក្រូវ អាកោខ្ទិះ អាកោស្លោត ។ ឯគៀមលក់នីមួយៗដែលនៅជុំវិញនោះ សឹងមានប្រដាប់ប្រដាគ្រប់មុខ សម្រាប់សេចក្តីត្រូវការនៃមនុស្សទូទៅ ។

## សំណួរ

១– ចូរពន្យល់ន័យនៃពាក្យ : កម្មសិទ្ធិ សេតុប្បល រត្តុប្បល បរិវេណ ។

២– ចូររកសទិសព្ទសូរសព្ទនឹងពាក្យ : ផ្សារ , សារ ។

៣ ចូរពន្យល់របៀបប្រើពួកវណ្ណយុត្តផ្នែកខណ្ឌសញ្ញា ។

---

## ម៉ាស៊ីនកិនស្រូវ

● នៅគ្រប់មជ្ឈដ្ឋាន នៃរោងចក្រ ដែលដុះដាលក្នុងកម្ពុជប្រទេស មាន ម៉ាស៊ីនច្រើនប្រការ ដែលមានជាបឋម គឺម៉ាស៊ីនកិនស្រូវ។ ម៉ាស៊ីននេះ ប្រើ ដោយកម្លាំងយន្តទាញដោយខ្សែពានច្រវាត់ឆ្វាត់ឆ្វែងប្រទើសប្រទាក់ សានវ៉ុណ្ឌលើ គ្នាសព្វទិសទស ។ ដំបូង គេចាក់ស្រូវទៅក្នុងគ្របត្បាល់ រួចស្រូវធ្លាក់ម្តងបន្តិចៗ



www.budinst.gov.kh www.elibraryofcambodia.org

ចូលទៅក្នុងត្បាល់កិនកម្ទេចស្រេចហើយ អង្កាមក៏ហើរចេញតាមប្រហោងបំពង់ទៅក្រៅ ។ រីឯអង្ករក៏រត់ចុះមកក្នុងកញ្ច្រែង បញ្ចូលទៅត្បាល់មួយទៀត ដើម្បីលម្អិលពីអង្ករសម្រូបទៅជាអង្ករស ។ អង្ករដែលទើបនឹងស្រីតរួចនេះ ធ្លាក់ទៅលើសំណាញ់ដែក ដែលសម្រាប់រែងយកចុងអង្ករនិងកន្ទក់ បន្ទាប់មក កន្ទក់ចេញទៅមួយកន្លែង ចុងអង្ករទៅមួយកន្លែង រីឯអង្ករដើម ចេញមកមួយកន្លែង ។

● ម៉ាស៊ីនកិនស្រូវ មានប្រយោជន៍សំខាន់ណាស់ ដល់ប្រជាកសិករ ដើម្បីរួញពេលវេលាឲ្យបានឆាប់ ចៀសវាងប្រើកម្លាំងមនុស្ស ។ ទោះបីមានម៉ាស៊ីនកិនស្រូវ កិនឆាប់ទាន់ចិត្តបែបនេះក៏ដោយ ប្រជាជនខ្មែរភាគខ្លះ ក៏នៅតែរក្សាត្បាល់កិនស្រូវជានិច្ច ព្រោះយល់ថាអង្ករកិនត្បាល់ មានរសជាតិជាងអង្ករម៉ាស៊ីន ។

## សំណួរ

១– ចូរពន្យល់ន័យនៃពាក្យ : រោងចក្រ បឋម សាន់វ៉ុណ្ណ ទិសទស ប្រយោជន៍ ។

២– ចូរតែងឃ្លាជាមួយនឹងពាក្យ : មជ្ឈដ្ឋាន យន្ត ទាញ កិន រសជាតិ រស់នៅ ។

៣– ចូរបង្ហាញនូវឈ្មោះទិសទាំង១០មកមើល ?

៤– ចូរពន្យល់អំពីម៉ាស៊ីនកិនស្រូវមួយ ដែលលោកបានស្គាល់ ។



www.budinst.gov.kh www.elibraryofcambodia.org

# វិធីកិនស្រូវ

● ក្នុងអតីតសម័យ ប្រជាជនខេមរបុត្រ បានរិះរកដោយមធ្យោបាយផ្ទាល់គ្រួសារ ប្រើវិធីកិនស្រូវ និងត្បាល់ម៉្យាងហៅថា ត្បាល់កិនស្រូវ ។

ត្បាល់កិន គេធ្វើអំពីបន្ទោះឫស្សី ត្បាញយ៉ាងញឹក ចែកជាពីរផ្នែក ផ្នែកខាងលើហៅថាគ្រប , ផ្នែកខាងក្រោមហៅថាមេ, ទាំងពីរផ្នែកនេះមានធ្មេញជាវិការៈនៃឈើរឹងប៉ឹង បង្កប់ទៅក្នុងដីដំបូក បុកយ៉ាងតឹងមាំ ដែលគេដាក់ក្នុងរង្វង់គ្របនិងមេ។ គ្របខាងលើមានប្រហោង សម្រាប់ចាក់ស្រូវ ហើយខាងក្រោមមានធ្មេញសង្កត់លើមេ ។ មេមានដីពេញទាំងអស់ហើយមានស្នូលឈើមួយបង្កប់ពីក្រោមចំកណ្តាលមានចុងត្រង់ទៅលើចូលទៅក្នុង ចំកណ្តាលដៃឆ្កាងរបស់គ្រប ។ នៅសងខាងគ្របមានដៃឆ្កាងម្ខាងមួយព្រមទាំងមានប្រហោងសម្រាប់សិកដៃត្បាល់ក្នុងពេលកិនម្តងៗ។ ខណៈដែលកិនស្រូវ គេត្រូវចាក់ស្រូវទៅក្នុងរង្វង់គ្រប ហើយគេថ្កក់ដៃត្បាល់បង្វិលគ្របវិលពីឆ្វេងទៅខាងស្តាំ ។ ឯដៃត្បាល់នោះ គេចងខ្សែទៅតល់ទាំងសងខាង ។ ពេលត្បាល់វិល គេឃើញគ្រាប់ស្រូវ ស្រុតចុះទៅក្រោមប៉ះនឹងធ្មេញសង្កៀតគ្នាបែកសំបកបានទៅជាគ្រាប់អង្ករ ។ ជាមួយគ្នានោះ អង្ករកើតជាគំនរលាយឡំជាមួយសំបកស្រូវ ដែលហៅថាអង្កាម ស្ថិតនៅជុំវិញត្បាល់លើកន្ទេលតទៅ គេយកអង្ករសម្រូបនោះទៅអុំនឹងចង្អេរ ឬក៏យកទៅរោយ ដើម្បីយកអង្ករចេញពីអង្កាម ហើយអង្ករសម្រាប់ស្រិតគេដាំធ្វើជាអាហារ ។ រីឯអង្កាមគេយកទៅធ្វើឧសដាំបាយ ដោយដើងក្រានអង្កាម ឬក៏យកទៅបំពក់ធ្វើជាភ្នក់គោ ចំណែកឯផេះមានប្រយោជន៍ដ៏ពិសិដ្ឋ ក្នុងការយកទៅធ្វើជាជីដាំដំណាំផ្សេង ៗ ។



www.budinst.gov.kh www.elibraryofcambodia.org

## សំណួរ

១– ចូរពន្យល់ន័យនៃពាក្យ : អតីតសម័យ បច្ចុប្បន្នសម័យ អនាគត - សម័យ ពិសិដ្ឋ ។

២ – បណ្ដាវណ្ណយុត្តិទាំងអស់ តើវណ្ណយុត្តិណាខ្លះដែលគេត្រូវការប្រើច្រើនជាងគេ? ចូរស្រង់ ឲ្យបានប្រាំ ហើយប្រាប់ឈ្មោះផង ។

៣— ចូរអធិប្បាយ អំពីវិធីកិនស្រូវ តាមគំនិតរបស់លោក ។

---

## មាតុភូមិខ្មែរ

● មាតុភូមិខ្មែរ មានស្ថានភាពទឹកដីធំទូលាយ ប្រាសាទនានា ស្ថិតនៅក្នុងព្រៃពាសពេញមណ្ឌលប្រទេស ជាហេតុនាំឲ្យដួងព្រលឹងនៃខេមរបុត្រស្រងេះស្រងោចខ្លោចផ្សា ដោយក្ដីអាល័យស្ដាយដល់កេរមតិក ជាស្នាដៃទិព្វរបស់បុព្វបុរសខ្មែរ ។

● អស់មួយរយៈកាលដ៏វែង ជិតមួយសតវត្ស មាតុភូមិយើងបានធ្លាក់ចុះក្នុងក្រញាំអាណានិគម ហើយពេលនោះឧបទ្ទវន្តរាយគ្រប់ប្រភេទ ក្លាយជាអាសន្នរោគ រុករានញាំញីដីធ្លីនិងវឌ្ឍនភាព ឲ្យមានឧនភាពជានិច្ច ។ ពូជពង្សខ្មែរធ្លាប់តែមានជ័យជម្នះតំណតតរៀងពីសម័យបុព្វកាល មិនយូរប៉ុន្មានក៏បានរើបម្រះផុតពីនឹមដែកអាណានិគមនិយម ប្រតិស្ឋជាវរជ្ឈពេញវ័យ បរិបូណ៌គ្រប់វិស័យគ្មានសល់



www.budinst.gov.kh www.elibraryofcambodia.org

ចន្ទោះដោយសារសេចក្ដីតស៊ូដ៏អង់អាច នៃរដ្ឋាភិបាល និងទឹកចិត្តស្នេហាជាតិ នៃប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន មួយអន្លើដោយពុទ្ធសាសនិក ដែលព្រះសង្ឃខេមរៈជាតិរួបរួមជាមហាសាមគ្គី ជាមួយពលរដ្ឋ ។

## សំណួរ

១– ចូរពន្យល់ន័យនៃពាក្យ: កេរមត៌ក ឧបទ្ទវន្តរាយ ឧឧកាត វិស័យ ស្នេហាជាតិ ពុទ្ធសាសនិក ។

២_ចូរតែងឃ្លាជាមួយនឹងពាក្យ : ខ្មាំងសត្រូវ អាល័យ វិស័យ ប្រតិស្ឋ ។

៣– ចូរពន្យល់អំពីរបៀបប្រើវណ្ណយុត្តិសំយោគសញ្ញា (៖) ព្រមទាំងប្រាប់នាទីដែលមិនត្រូវប្រើផង ។

៤– ចូរពន្យល់អត្ថន័យ នៃអត្ថបទ ខាងលើនេះ ។

---

## សន្តានចិត្តខ្មែរ

● ខ្មែរជាជនជាតិ ដែលមានសន្តានចិត្តស្លូតបូត ប្រកបដោយមេត្តាព្រហ្មវិហារឥតខ្ចោះ ចេះសន្ដោសត្រីត្នា មិនប្រកាន់ថាសញ្ជាតិខ្លួន ឬសញ្ជាតិដទៃឡើយ ។ ខ្មែរចេះសាមគ្គីរួបរស់ក្នុងសភាពសមរមប្រណីតព្រមទាំងគោរពពាក្យសត្យឥតមន្ទិល,

ក្នុងអតីតកាល ខេមរជាតិ បានស្គាល់ទុក្ខវេទនាជាទីបំផុត ដោយបច្ចាមិត្តគេប្រើកម្លាំងឃោរឃៅ ប្រកបដោយហឹង្សា ក្នុងគោលបំណងកម្ទេចជាតិសាសន៍



www.budinst.gov.kh www.elibraryofcambodia.org

ឲ្យឃ្លាតស្ងាត់បំផុត ពីទំព័រប្រវត្តិសាស្ត្រ តែជាភព្វសំណាង ដោយសារបានដឹងក់នូវគុណធម៌ ពីព្រះរតនត្រ័យ ចេះខន្តីតស៊ូប្រយុទ្ធដ៏អង់អាច បង្ក្រាបនូវបច្ចាមិត្តដែលមានចិត្តប្រកាន់ជាតិសាសន៍ ឈ្លានពានទឹកដី ។

ខេមរជន បានចាំច្បាស់នូវសាមគ្គីភេទ ដែលកើតពីបុព្វហេតុ ដណ្តើមអំណាច នៃវរជនខ្លះ ក្នុងអតីតសម័យ បណ្តាលឲ្យផែនដីកម្ពុជារួញខើចស្ទើរផុតពីទំព័រភូមិសាស្ត្រសាកលលោក ។

បច្ចុប្បន្នកាលនេះ ជាតិខ្មែរបានជ្រើសយកព្រះធម៌ ព្រះសព្វញ្ញុពុទ្ធ ទុកជាមូលដ្ឋាននៃកិច្ចស្ថាបនាអនាគតរបស់ខ្លួន ផ្តួនទៅលើសន្តិភាព មេត្តាធម៌ យុត្តិធម៌ អព្យាក្រឹតភាព និងសម្បូរណភាពទឹកដី ដើម្បីជាសក្តិភាព នៃសេចក្តីសុខ សន្តានចិត្តខ្មែរបានដឹតជាប់នៅក្នុងពុទ្ធវាចថា នត្ថិ សន្តិ បរំ សុខំ សេចក្តីសុខក្រៅពីសេចក្តីស្ងប់មិនមាន ។

## សំណួរ

១– **ចូរពន្យល់ន័យនៃពាក្យ** ៖ សន្តានចិត្ត មេត្តាព្រហ្មវិហារ សន្តោស ពាក្យសត្យ បច្ចាមិត្រ គុណធម៌ សន្តិភាព ។

២— ចូររកឲ្យបាន៥ពាក្យ៖ នូវស្វរសព្ទ ត្ត ដែលមានសំឡេងជាជើង ដ រឺ ៣ ។

៣– **ចូររកបដិពាក្យ** ៖ ចិត្តសុខ មិត្ត គុណធម៌ សន្តិភាព ខន្តី យុត្តិធម៌ ។

៤– តើផ្ទៃនៃអត្ថបទនេះ មានអត្ថបទ ដូចម្តេចខ្លះ? ចូរពន្យល់ឲ្យល្អមស្តាប់បានមកមើល ។



www.budinst.gov.kh www.elibraryofcambodia.org

# ព្រះពុទ្ធសាសនា

● តាមមាត្រា ៨ នៃរដ្ឋធម្មនុញ្ញ បានចែងថា ព្រះពុទ្ធសាសនា ជាសាសនាសម្រាប់រដ្ឋកម្ពុជា ។ ពត៌មាននេះ បណ្ដាលឲ្យពុទ្ធសាសនិកជន មានបីតិសោមនស្សប្រកបដោយយោនិសោមនសិការៈគ្រប់ ៗ គ្នា ។

● ព្រះពុទ្ធសាសនា ជាពាក្យប្រៀនប្រដៅប្រកបដោយមធុរស ប្រសូតចេញពីព្រះពុទ្ធោវាទជ្រួតជ្រាបចូលក្នុងសន្ដានចិត្តប្រជាជន តាំងពីយូរយារណាស់ហើយ ។ ពុទ្ធសាសន៍នេះ មានឧត្តមគតិ ញាំងអ្នកដែលជឿស៊ប់ ហើយប្រតិបត្តិតាម ឲ្យឡើងពីហីនភាពទៅកាន់ឧត្តមភាព, ពីពាលភាព , ទៅកាន់បណ្ឌិតភាព, ពីមូឡ្ហភាពទៅកាន់កុដិស្សភាព រៀងរាបដរាបដល់ចាកទុកភយន្ដរាយគ្រប់យ៉ាង ។ ផ្ទុយពីនេះព្រះបរមពុទ្ធោវាទ ពុំអាចផ្ដល់នូវសច្ចធម៌ ដល់ជនដែលគ្មានធម្មប្បដិបត្តិនិងសាសនប្បដិបត្តិឡើយ ។

សំណួរ

១– ចូរពន្យល់ន័យនៃពាក្យ : រដ្ឋធម្មនុញ្ញ ពត៌មាន បីតិសោមនស្ស យោនិសោមនសិការៈ សច្ចធម៌ ធម្មប្បដិបត្តិ ។

២ – ចូរតែងឃ្លាជាមួយនឹងពាក្យ : ប្រតិបត្តិ ហីនភាព ឧត្តមភាព ពាលភាព បណ្ឌិតភាព កុដិស្សភាព ។

៣– សាសនា ប្រែថាដូចម្ដេច ? មានប៉ុន្មានយ៉ាង? អ្វីខ្លះ ? ដែលហៅថាពុទ្ធសាសនា បានដល់អ្វី ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ? ចូររាប់និងពន្យល់ផង ។

៤– ចូរពន្យល់អត្ថន័យ នៃអត្ថបទខាងលើនេះ ។



www.budinst.gov.kh www.elibraryofcambodia.org

# ពុទ្ធចក្រ និង អាណាចក្រ

បោរាណបណ្ឌិតទាំងឡាយ លោកសន្មតប្រទេសនីមួយ ៗ ទុកដូចជាតួរទេះ ឬតួរថ រទេះឬរថនោះ ត្រូវមានចក្រ គឺកង់ទាំងពីរខាង កង់ម្ខាងហៅថាសាសនចក្រ កង់ម្ខាងទៀតហៅថាអាណាចក្រ ។ សាសនចក្រ ជាកង់ខាងសីលធម៌ ដែលមានសីលប្រាំនិងសុចរិតផប់ និងចរិយាសម្បត្តិជាមូលដ្ឋាន ។ ប្រទេសខ្មែរ តាំងពីបានទទួលគោរពជឿកាន់ព្រះពុទ្ធសាសនាមក បានផ្លាស់ពាក្យសាសនចក្រ ឲ្យហៅថា ពុទ្ធចក្រវិញ ព្រោះយកព្រះពុទ្ធសាសនាដែលសម្បូណ៌ដោយសន្តិវិធី ជាកង់ម្ខាងរបស់ប្រទេស ។ ឯអាណាចក្រនោះបានខាងកង់ គឺអំណាចដោយយកច្បាប់សម្រាប់ប្រទេស ដែលមានទសពិធធម៌ផប់ប្រការជាគោល សន្មតថាជាកង់ម្ខាងរបស់រទេះឬរថ គឺប្រទេសដែរ ។ ចក្រគឺកង់ទាំងពីរខាងនេះ ជាគូនឹងគ្នា ត្រូវឲ្យវិលស្មើរគ្នាជាផរាប ។ ប្រទេសណាបើឲ្យសាសនចក្រ វិលខ្លាំងជាងអាណាចក្រ គឺបើប្រជាជនពលរដ្ឋខំប្រឹងប្រតិបត្តិតាមផ្លូវសាសនាជ្រុលហួសពេក ជាងផ្លូវអាណាចក្រ ប្រទេសនោះនឹងខ្វាយទៅរោទន់ខ្សោយ ពុំបរិបូណ៌ដោយទ្រព្យធននិងតេជានុភាព , បើឲ្យអាណាចក្រវិលខ្លាំងពេកជាងសាសនចក្រ គឺបើប្រជាពលរដ្ឋពុំសូវអើពើចំពោះសាសនចក្រ សីលធម៌និងចរិយាសម្បត្តិក្នុងប្រទេសនោះ នឹងមិនសម្បូណ៌ ហើយប្រទេសនោះនឹងខ្វាយទៅជារដ្ឋមានច្រើនតែប្រជាជនឃោរឃៅឈ្លានពានពាយងាយហួសហេតុ ស្ងប់ត្រឹមតែកតញ្ញូតាធម៌ កតវេទិតាធម៌និងវុឌ្ឍា-



www.budinst.gov.kh www.elibraryofcambodia.org

បចាយនធម៌ ដែលសត្វលោកគួរកាន់ គួរគោរពជានិច្ច ក៏ក្លាយទៅជាទន់ថយ ខ្សោយអស់ ស្ទើរតែនឹងឲ្យឈ្មោះថាគ្មានសោះក៏សឹងតែបាន ។

សម្តេចព្រះសង្ឃរាជ

ជួន-ណាត

---

## រដ្ឋាភិបាលនិងព្រះពុទ្ធសាសនា

● រដ្ឋាភិបាល ជាអគ្គពុទ្ធសាសនូបត្ថម្ភក៍ បានយកចិត្តទុកដាក់ចំពោះព្រះពុទ្ធសាសនា ឥតមានរដ្ឋណាមួយប្រដូចបាន បានកសាងវត្តអារាម សម្រាប់ព្រះសង្ឃគង់នៅអប់រំបន្ទំបារមី សាងសេចក្តីបរិសុទ្ធិដើម្បីចេញចាកឥធលោក ទៅកាន់សេចក្តីសុខក្នុងបរលោក ។ ផ្នែកសាសនសិក្សាធិការ រដ្ឋាភិបាលជាមួយសម្តេច ហួត តាត បានស្ថាបនាឲ្យមានសាលាពុទ្ធិកបឋមសិក្សាពេញអាណាចក្រ, ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត និងពុទ្ធិកសាកលវិទ្យាល័យ ដែលស្ថិតនៅទិសខាងកើតឆៀងអាគ្នេយ៍ នៃនិវេសន៍វាំង ជិតសាលសន្និសីទ និងទន្លេចតុមុខ ។ ក្រៅពីនេះបានស្ថាបនាវិទ្យាល័យ ស៊ីវ - ហ្វួង បាត់ដំបង និងសាលាធម្មវិន័យនានាក្នុងកម្ពុជរដ្ឋ ដែលសម្រាប់ឲ្យព្រះសង្ឃសិក្សាសព្វសាស្ត្រវិជ្ជា ទាំងផ្លូវធម៌និងផ្លូវលោក ។ មិនតែប៉ុណ្ណោះបានបញ្ចូលទៅក្នុងមាត្រារដ្ឋធម្មនុញ្ញថា «ពុទ្ធសាសនាជាសាសនារបស់រដ្ឋកម្ពុជា» ហើយបានអនុញ្ញាតឲ្យមន្ត្រីភ្នាក់ងារ គ្រប់តំណែងសម្រាកធ្វើការថ្ងៃឧបោសថ ដើម្បីបំពេញឧបោសថសីលស្តាប់លោកទេសន៍ សង្ឃ



www.budinst.gov.kh www.elibraryofcambodia.org

ទាន និងធ្វើសមាធិកម្មដ្ឋានទៀតផង ។

## សំណួរ

១- ចូរពន្យល់ន័យនៃពាក្យ ៖ បរិសុទ្ធ សាលសន្និសីទ ឧបោសថ សមាធិ ។

២- តើអត្ថបទនេះ និយាយអំពីអ្វីខ្លះ ? ចូរពន្យល់ឲ្យច្បាស់លាស់ ។

---

## ពុទ្ធសាសនប្បត្តិ

● សេចក្ដីតំណាលក្នុងគម្ពីរសាមន្តប្បាសាទិការអដ្ឋកថាវិន័យបិដកថា ក្រោយពុតិយសង្គាយនារួចហើយ ។ នៅប្រទេសឥណ្ឌាក្នុងពុទ្ធសតវត្សរ៍ទី ៣ មានព្រះមហាថេរមួយអង្គ ព្រះនាមមហាមោគ្គលីបុត្តតិស្សៈ បានចាត់ឲ្យព្រះថេរៈពីរអង្គ គឺព្រះសោណត្ថេរនិងឧត្តរត្ថេរ ចេញមកផ្សាយព្រះពុទ្ធសាសនាក្នុងសុវណ្ណភូមិ ក្រោមព្រះបរមរាជូបត្ថម្ភនៃព្រះមហាក្សត្រ ទ្រង់ព្រះនាមធម្មាសោករាជ ។

● តាមការពិនិត្យអក្ខរសញ្ញាលើផ្ទាំងសិលាចារឹកបុរាណ ដែលស្ដីពីការទាក់ទងនៃរឿងព្រះពុទ្ធសាសនា ឃើញថា ព្រះពុទ្ធសាសនា បានឧប្បត្តិប្រតិស្ឋនៅលើទឹកដីកម្ពុជា តាំងពីក្នុងពុទ្ធសតវត្សទី ៣ ម្ល៉េះ ។ នេះសឲ្យច្បាស់ថា សុវណ្ណភូមិ គឺអាស៊ីភាគអាគ្នេយ៍ ។ ក្នុងកំលុងពេលដ៏យូរលង់នោះ រដ្ឋាភិបាលក្ដី ឥស្សរជនក្ដី ប្រជាពលរដ្ឋក្ដី មានទិន្នាការមិនទៀងទាត់ គឺខ្លះកាលជាពុទ្ធសាសនិកថេរវាទ , ខ្លះកាលជាពុទ្ធសាសនិកមហាយាន , ខ្លះកាលជាព្រាហ្ម-



www.budinst.gov.kh www.elibraryofcambodia.org

ណិក, ម្ល៉ោះហើយបានជាមានភស្តុតាង បែបព្រហ្មញ្ញសាសនា លាយឡំជាមួយពុទ្ធសាសនាទល់សព្វថ្ងៃ ។ ប៉ុន្តែគួរឲ្យអស្ចារ្យដែរ ព្រះពុទ្ធសាសនាតែងមានឥទ្ធិពលដ៏មហិមា លើសាសនាដទៃគ្រប់កាលៈទេសៈ រហូតទល់បច្ចុប្បន្ននេះ ក៏ដោយសារប្រជាករបរិស័ទ ក្នុងអតីតសម័យបានជួយគាំទ្រពេញសមត្ថភាព ។

● កម្ពុជិកជន គេបានដឹងច្បាស់ថា កំណាកំណើតនៃពុទ្ធសាសនា គឺពុទ្ធបរិស័ទជាម្ចាស់សាសនាពុទ្ធសាសនា ព្រោះពេលព្រះពុទ្ធបរិនិព្វាន បានផ្ញើសាសនានឹងបរិស័ទទាំង ៤ ។

## សំណួរ

១- **ចូរពន្យល់ន័យនៃពាក្យ** : ពុទ្ធសាសនុប្បត្តិ អក្ខរសញ្ញា ឥស្សរជន ឥទ្ធិពល ។

២- ចូរពន្យល់អំពីការកើតឡើង នៃពុទ្ធសាសនា ។

---

## ពិធីសម្ពោធព្រះត្រៃបិដក

● សម្ដេចព្រះ សង្ឃរាជ ជួន-ណាត និងសម្ដេចព្រះ ពោធិវង្សហួត-តាត ទ្រង់សព្វព្រះរាជហឫទ័យ ស្នើសូមឲ្យរដ្ឋាភិបាល ចាត់ចែងធ្វើពិធីសម្ពោធព្រះត្រៃបិដក ដោយរួបរួមនឹងព្រះសង្ឃ មន្ត្រីគ្រប់តំណែង ទាហាន ស៊ីវិល ព្រមទាំងជាមួយនឹងប្រជាពលរដ្ឋទូទៅ ក្នុងប្រទេសកម្ពុជាទាំងមូលផង នៅថ្ងៃ ១៤ កើត ខែចេត្រ



www.budinst.gov.kh www.elibraryofcambodia.org

ឆ្នាំរកា សម្រឹទ្ធិស័ក ពុទ្ធសករាជ ២៥១២ ត្រូវនឹងថ្ងៃទី ១ ខែមេសា គ្រិស្តសករាជ ១៩៦៩ ។

● រដ្ឋាភិបាលដែលមានក្រសួងធម្មការជាតំណាង បានទទួលភារៈខាងកិច្ចការព្រះពុទ្ធសាសនា ក្រោយដែលបានទទួលបញ្ជាដ៏ខ្ពង់ខ្ពស់នៃនាយករដ្ឋាភិបាល ហើយ ក៏បានរួបរួមជាមួយនឹងសម្តេចព្រះសង្ឃរាជ គណៈមហានិកាយ និងសម្តេចព្រះសង្ឃនាយកគណៈធម្មយុត្តិកនិកាយ រៀបចំពិធីសម្ពោធព្រះត្រៃបិដក ក្នុងក្រុងភ្នំពេញ ក្នុងខេត្តនិងស្រុក គ្រប់វត្តអារាមក្នុងអាណាចក្រទាំងមូល ដើម្បីឱ្យសមដល់ឋានៈ នៃប្រទេសកម្ពុជាឯករាជ្យអព្យាក្រឹត ជាប្រទេសដែលបានទទួលយកព្រះពុទ្ធសាសនា ទុកជាសាសនារបស់រដ្ឋផង ឱ្យសមដល់ព្រះកិត្តិយសដ៏ខ្ពង់ខ្ពស់នៃព្រះសក្យមុនីគោតមបរមគ្រូ ដែលព្រះអង្គជាអ្នកប្រោសប្រាណត្រៃភព ។

## សំណួរ

១- ចូរពន្យល់ន័យពាក្យ ; ព្រះត្រៃបិដក សម្ពោធ រដ្ឋធានី ។

២- តើផ្នែកអត្ថបទនេះ ចែកជាប៉ុន្មានសង្កាត់? ចូរពន្យល់ គំនិតក្នុងសង្កាត់នីមួយៗ។

៣- ចូរពិពណ៌នា អំពីបុណ្យសម្ពោធព្រះត្រៃបិដក ដែលបានធ្វើនៅស្រុកលោក។

---

## បុព្វហេតុនៃបុណ្យ សម្ពោធព្រះត្រៃបិដក

● ព្រះត្រៃបិដក ធ្លាប់មានក្នុងប្រទេសកម្ពុជាយើងនេះ ជាយូរអង្វែងមក ហើយក៏ពិតមែន ប៉ុន្តែមានពុំចប់សព្វគ្រប់ទេ ហើយព្រះត្រៃបិដកដែលមានខ្លះនោះ



www.budinst.gov.kh www.elibraryofcambodia.org

សុទ្ធតែជាភាសាបាលី ពុំទាន់មានសេចក្ដីប្រែជាភាសាខ្មែរយើងនៅឡើយ មានសេចក្ដីប្រែខ្លះដែរតែបន្តិចបន្តួចប៉ុណ្ណោះ ។ ក្នុងប្រទេសខ្មែរយើងនេះ បានចាប់ផ្ដើមកសាងព្រះត្រៃបិដកទាំងបាលីទាំងសេចក្ដីប្រែជាភាសាខ្មែរ តាំងពីក្នុង គ.ស. ១៩២៩ រហូតដល់ គ.ស. ១៩៦៩ គឺក្នុងឆ្នាំរកា សប្ដស័ក ព.ស. ២៥១២ នេះ ទើបការកសាងព្រះត្រៃបិដក និងការបោះពុម្ពភ្ជាប់បាលីនិងសម្រាយ រួមជាមួយគ្នាធ្វើជាសៀវភៅចំនួន ១១០ ភាគបានចប់បរិបូណ៌ ។

• ដោយហេតុនេះ បានជារដ្ឋាភិបាលខ្មែរ ដែលជាពុទ្ធសាសនូបត្ថម្ភក៍ បានយកចិត្តទុកដាក់ និងបញ្ជាឲ្យចាត់ការធ្វើបុណ្យសម្ពោធព្រះត្រៃបិដក នៅឆ្នាំរកា សប្ដស័ក ព.ស. ២៥១២ នេះ ប្រកបដោយបីតិសោមនស្សរីករាយយ៉ាងខ្លាំងក្លា ចំពោះការកសាងព្រះត្រៃបិដកបានចប់បរិបូណ៌នេះ ។

សម្ដេចព្រះពោធិវង្ស ហួត - តាត
សម្ពោធព្រះត្រៃបិដក
ថ្ងៃ ១ - ៤ - ៦៩

## សំណួរ

១- ចូរពន្យល់ន័យនៃពាក្យ : បុព្វហេតុ បុណ្យ ត្រៃបិដក បីតិ សោមនស្ស ។

២- ចូរតែងឃ្លាជាមួយនឹងពាក្យ : ចប់ ចាប់ផ្ដើម និង រីករាយ បរិបូណ៌ ។

៣- ចូររាប់និងពន្យល់អំពីសករាជ : ដែលខ្មែរយើងធ្លាប់ប្រើរួចមកហើយ ។

៤- តើអត្ថបទនេះ និយាយពីអ្វីខ្លះ ? ចូរពន្យល់ឲ្យសព្វគ្រប់ ។



www.budinst.gov.kh www.elibraryofcambodia.org

# ក្រុមជំនុំព្រះត្រៃបិដក

● ប្រទេសខ្មែរយើង ជារដ្ឋកាន់ព្រះពុទ្ធសាសនា ត្រូវមានភារៈស្វែងរកព្រះត្រៃបិដកឲ្យបានចប់បរិបូណ៌ ។ តាំងពីច្រើនសតវត្សមកហើយ ប្រទេសកម្ពុជាយើង ពុំទាន់មានព្រះត្រៃបិដកចប់បរិបូណ៌នៅឡើយ ទើបតែក្នុងពុទ្ធសតវត្សទី ២៦ នេះ ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់បានព្រមព្រៀងមួយអន្លើដោយរដ្ឋាភិបាល និងរដ្ឋការអាណាព្យាបាលបារាំងសែស បានផ្ដើមកសាងព្រះត្រៃ-បិដក គឺបានបង្កើតឲ្យមានក្រុមជំនុំព្រះត្រៃបិដកមួយក្រុម សម្រាប់ឲ្យប្រែពីបាលីមកជាភាសាខ្មែរ ហើយបោះពុម្ពទាំងបាលី ទាំងសម្រាយរួមគ្នាតែម្ដង ធ្វើជាសៀវ-ភៅរួមទាំងអស់ ១១០ ភាគតាំងពីឆ្នាំ ១៩២៩ ដរាបដល់ឆ្នាំ ១៩៦៩ នេះ ទើបចប់បរិបូណ៌ ។ បើគិតរយៈកាលនៃការកសាងព្រះត្រៃបិដកនេះ ឃើញថា ៤០ ឆ្នាំទើបចប់សព្វគ្រប់ ។

● ប្រទេសខ្មែរយើង អាចចាត់ទុកជាប្រទេសកាន់ព្រះពុទ្ធសាសនា មានភព្វសំណាងឧត្តុង្គឧត្តមប្រសើរជាងប្រទេសនានា ដែលកាន់ព្រះពុទ្ធសាសនាដូចគ្នា ដោយហេតុដែលបានកសាងព្រះត្រៃបិដកចប់បរិបូណ៌ ទាំងបាលីទាំងសម្រាយ ។

● ដូច្នេះ យើងជាពុទ្ធបរិស័ទ ត្រូវកត់សម្គាល់នូវព្រះត្រៃបិដកដែលបានចប់បរិបូណ៌ហើយនេះ ថាដូចជាព្រះពុទ្ធជាបរមគ្រូរបស់យើង បានស្ដេចមកគង់នៅក្នុងប្រទេសយើង ឬដូចជាព្រះអង្គទើបយាងមកដល់ គួរយើងជាពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថ រួបរួមគ្នាធ្វើបដិសណ្ឋារៈ គោរពរាប់អានបូជាចំពោះព្រះត្រៃបិដក



www.budinst.gov.kh www.elibraryofcambodia.org

នោះ ដោយសោធនស្សវ៉ីករាយទាំងអស់គ្នា ។

សម្តេចព្រះពោធិវ័ង្ស **ហួត. តាត**

សុន្ទរកថាពិធីសម្ពោធព្រះត្រៃបិដក

ថ្ងៃ ១-៤-៦៩

---

## ផលប្រយោជន៍ព្រះត្រៃបិដក

● ព្រះត្រៃបិដក អាចផ្តល់ផលប្រយោជន៍ ច្រើនជាអនេកប្បការ ពុំអាចនឹងរៀបរាប់ឲ្យអស់បានឡើយ ដូចជាព្រះសព្វញ្ញុពុទ្ធ ដែលព្រះអង្គបានត្រាស់ឡើងក្នុងលោក អាចផ្តល់ផលប្រយោជន៍ឲ្យកើតមានដល់សត្តនិករ រាប់ពុំអស់ដូច្នោះដែរ គឺថាព្រះពុទ្ធទ្រង់ត្រាស់ឡើងក្នុងលោក ប្រៀបដូចជាប្រទីបមួយដ៏ធំ មានពន្លឺភ្លឺអស្ចារ្យ សម្រាប់បំភ្លឺសត្វលោកដែលមានបញ្ញាចក្ខុ ឲ្យឃើញនូវគុណ, ទោស, ខុស, ត្រូវ, អាក្រក់, ល្អ និងផ្លូវវៀចត្រង់ គឺផ្លូវទៅកាន់ទុគ្គតិ និងសុគតិ រហូតដល់ផ្លូវដែលត្រូវដើរទៅកាន់អមតស្ថាន គឺព្រះនិព្វាន ។ ប៉ុន្តែបើសត្វលោករូបណាមួយខ្វះបញ្ញាចក្ខុ គឺជាមនុស្សពាលងងឹតជ្រប់នៅក្នុងមោហន្ធការ សត្វលោករូបនោះ ក៏ពុំអាចទទួលនូវពន្លឺអំពីព្រះពុទ្ធបានឡើយ ដូចជាមនុស្សខ្វាក់ ពុំអាចទទួលនូវពន្លឺថ្ងៃ ឬពន្លឺភ្លើងបានដូច្នោះដែរ ។

● ព្រះពុទ្ធត្រាស់ឡើងក្នុងលោក អាចផ្តល់ផលប្រយោជន៍ច្រើនដល់សត្វលោកយ៉ាងណាមិញ, ព្រះត្រៃបិដកដែលជាធម៌វិន័យ ជាច្បាប់ព្រះពុទ្ធសាសនា



www.budinst.gov.kh www.elibraryofcambodia.org

ក៏អាចផ្តល់ផលប្រយោជន៍ដល់សត្វលោកផងច្មោះដែរ ប៉ុន្តែចំពោះតែសត្វលោកដែលមានសទ្ធា មានគំនិតចេះគិត មានប្រាជ្ញាចេះពិចារណា ព្រមទាំងព្យាយាមខំប្រឹងសិក្សា ខំប្រឹងអាន ខំប្រឹងគិតពិចារណា ។ បើសត្វលោកណាមួយ ឥតសទ្ធាខ្វះគំនិត ឥតប្រាជ្ញា ហើយខ្ជិលច្រអូស មិនខំប្រឹងសិក្សា មិនខំប្រឹងអានឬស្តាប់ មិនខំប្រឹងគិតពិចារណាទេ សត្វលោកនោះ ក៏មិនអាចទទួលផលប្រយោជន៍អំពីព្រះត្រៃបិដកបានដែរ ។

សម្តេចព្រះពោធិវង្ស ហួត - តាត

សុន្ទរកថាពិធីសម្ពោធព្រះត្រៃបិដក

ថ្ងៃ ១-៤-៦៩

---

## ន័យនៃព្រះត្រៃបិដក

- ព្រះត្រៃបិដកនេះ ប្រែថាបិដកបី គឺវិន័យបិដក ១ សុត្តន្តបិដក ១ អភិធម្មបិដក ១ ។
- វិន័យបិដក បើចែកជាគម្ពីរមាន ៥ គឺ ៖ អាទិកម្ម ១ បាចិត្តិយ ៖ ១ មហាវគ្គ ១ ចុល្លវគ្គ ១ បរិវារៈ ១ ។
- សុត្តន្តបិដក បើចែកជាគម្ពីរ ឬនិកាយមាន ៥ គឺ ៖ ទីឃនិកាយ ១ មជ្ឈិមនិកាយ ១ សំយុត្តនិកាយ ១ អង្គុត្តរនិកាយ ១ ខុទ្ទកនិកាយ ១
- អភិធម្មបិដក បើចែកជាគម្ពីរមាន ៧ គឺ ៖ សង្គណី វិភង្គ ១ ធាតុកថា ១



www.budinst.gov.kh www.elibraryofcambodia.org

បុគ្គលបញ្ញត្តិ ១ កថាវត្ថុ ១ យមកៈ ១ បដ្ឋានៈ ១ ។

● បិដកទាំងបីនេះហើយ ដែលជាគោលចារឹកនៃព្រះពុទ្ធសាសនា គឺពាក្យឱវាទ ពាក្យប្រៀនប្រដៅ ពាក្យរំលឹកដាស់តឿន ពាក្យណែនាំនិងពាក្យផ្តែផ្តាំនៃព្រះពុទ្ធជាបរមគ្រូរបស់យើងដល់ពុទ្ធបរិស័ទ ។ កាលបើបិដកទាំងបីនេះនៅមានអស់កាលត្រឹមណា ព្រះពុទ្ធសាសនា ក៏ឈ្មោះថានៅមានអស់កាលត្រឹមណោះ បើបិដកទាំងបីរលាយរលត់អស់ក្នុងពេលណា ព្រះពុទ្ធសាសនា ក៏ឈ្មោះថាសាបសូន្យរលត់អស់ទៅក្នុងពេលនោះដែរ ។

● ដូច្នេះ សូមពុទ្ធបរិស័ទទាំងឡាយ ទាំងបព្វជិត ទាំងគ្រហស្ថ ដែលជាអ្នកស្រឡាញ់គោរព រាប់អាន ពេញចិត្តចំពោះព្រះពុទ្ធសាសនា គប្បីយកចិត្តទុកដាក់គោរពចំពោះព្រះត្រៃបិដក ដែលជាគោលចារឹកនៃព្រះពុទ្ធសាសនា ។

សម្តេចព្រះពោធិវង្ស **ហួត តាត**

ពិធីសម្ពោធព្រះត្រៃបិដក

ថ្ងៃ ១-៤-៦៩

---

## មជ្ឈិមពុទ្ធវចន

● កាលមុនពេលបរិនិព្វាន ព្រះពុទ្ធជាបរមគ្រូសាស្តា គង់ចាំវស្សានៅក្នុងអារាមមួយនាវេឡុវនគ្រាម ទ្រង់មានរោគាពាធដ៏ខ្លាំងក្លាណាស់ លុះរោគាពាធនេះបានធូរស្រាលគ្រាន់បើ ព្រះអង្គបានរំលឹកព្រះភិក្ខុសង្ឃថា :



www.budinst.gov.kh www.elibraryofcambodia.org

អត្តទីបា វិហរថ អត្តសរណា អនញ្ញសរណា
ធម្មទីបា ធម្មសរណា អនញ្ញសរណា

អ្នកទាំងឡាយ ចូរយកខ្លួនជាទីពឹង ចូរយកខ្លួនជាទីរលឹក កុំយកអ្វីដទៃទីរលឹកឡើយ ។ តមកទៀត ក្រោយពេលដែលព្រះអង្គដាក់ចុះនូវព្រះជន្មាយុសង្ខារ ហើយទ្រង់ស្តេចយាងទៅកាន់កុដាគារសាលា ដោយមានព្រះអានន្ទត្ថេរហែព្រះអង្គផង ព្រះអង្គមានព្រះពុទ្ធបញ្ជា ឱ្យព្រះអានន្ទប្រមូលព្រះភិក្ខុសង្ឃទាំងអស់ក្នុងក្រុងវេសាលី ឱ្យមកប្រជុំក្នុងឧបដ្ឋានសាលាហើយព្រះអង្គបានយាងទៅកាន់សង្ឃសន្និបាតនោះទ្រង់បានប្រកាសអំពីបរិនិព្វានកាលរបស់ព្រះអង្គ រួចមានព្រះពុទ្ធតម្រាស់ថា:

ទហរាបិ ច យេ វុឌ្ឍា យេ ពាលា យេ ច បណ្ឌិតា
អឌ្ឍា ចេវ ទលិទ្ទា ច សព្វេ មច្ចុបរាយនា

● ជនទាំងឡាយណា ទោះបីក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តី ស្តុកស្តម្ភក្តី ទាលក្រក្តី ជនទាំងឡាយនោះ សុទ្ធតែមានសេចក្តីស្លាប់នៅពីខាងមុខទាំងអស់ ៗ

យថាបិ កុម្ភការស្ស កតំ មត្តិកភាជនំ
ខុទ្ទកញ្ច មហន្តញ្ច យញ្ច បក្កំ យំ អាមកំ
សព្វំ ភេទបរិយន្តំ ឯវំ មច្ចាន ជីវិតំ

ភាជន៍ដីដែលស្មូនឆ្នាំងធ្វើហើយ ទោះតូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី ទាំងអស់សុទ្ធតែមានការបែកជាទីបំផុតយ៉ាងណាមិញ, ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ៗ

សម្តេចព្រះពោធិវង្ស ហួត-តាត

ស្រង់ចេញពីពិធីសម្ពោធព្រះត្រៃបិដក ថ្ងៃ ១ - ៤ - ៦៩



www.budinst.gov.kh www.elibraryofcambodia.org

## បច្ឆិមពុទ្ធវចនៈ (ត)

បរិបក្កោ វយោ មយ្ហំ បរិត្តំ មម ជីវិតំ
បហាយ វោ គមិស្សាមិ កតំ មេ សរណមត្តនោ

វ័យអញតថាគតចាស់ណាស់ហើយ ជីវិតអញតថាគតនៅតិចណាស់ អញតថាគតនឹងលះបង់នូវអ្នកទាំងអស់គ្នាទៅ រីឯទីពឹងរបស់ខ្លួនអញតថាគតបានធ្វើរួចហើយ ។

អប្បមត្តា សតីមន្តោ សុសីលា ហោថ ភិក្ខវោ
សុសមាហិតសង្កប្បា សុចិត្តមនុរក្ខថ

ម្នាលភិក្ខុទាំងឡាយ, អ្នកទាំងឡាយ ចូរកុំប្រហែសធ្វេស ចូរមានស្មារតី មានសីលល្អបរិសុទ្ធ មានតម្រិះខ្ជាប់ខ្ជួនល្អ ចូររក្សាចិត្តរបស់ខ្លួនឲ្យល្អ ។

យោ ឥមស្មឹ ធម្មវិនយេ អប្បមត្តោ វិហរិស្សតិ
បហាយ ជាតិសំសារំ ទុក្ខស្សន្តំ ករិស្សតិ

ភិក្ខុណាមិនប្រហែសធ្វេសក្នុងធម៌វិន័យនេះ ភិក្ខុនោះនឹងលះបង់នូវជាតិសំ-សារ ហើយនឹងធ្វើនូវទីបញ្ចប់នៃទុក្ខបាន ។ មានពុទ្ធភាសិតមួយបទទៀត ដែលព្រះសម្ពុទ្ធទ្រង់ត្រាស់ជាពាក្យផ្តាំផ្ញើក្នុងពេលចុងក្រោយបំផុត គឺពេលហៀបនឹងបរិនិព្វាន ជាពុទ្ធភាសិតដែលពុទ្ធបរិស័ទទាំងឡាយ ត្រូវចងចាំគ្រប់គ្នាថា:

ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា
អប្បមាទេន សម្បាទេថ ។

ហ៏ ឥឡូវនេះ, ភិក្ខុទាំងឡាយ អញតថាគត ហៅអ្នករាល់គ្នាមកប្រាប់ សង្ខារទាំងឡាយ សុទ្ធតែមានការអស់ទៅ សោះសូន្យទៅជាធម្មតា អ្នកទាំងឡាយ



www.budinst.gov.kh www.elibraryofcambodia.org

ចូរញ៉ាំងកិច្ចការដែលត្រូវធ្វើឲ្យសម្រេច ដោយសេចក្ដីមិនប្រមាទចុះ ។

សម្ដេចព្រះពោធិវង្ស **ហួត-តាត**

ស្រង់ចេញពីពិធីសម្ពោធព្រះត្រៃបិដក

ថ្ងៃ ១-៤-៦៩

---

## យុវជននិងព្រះត្រៃបិដក

● យុវជនយើង បើពុំបានទទួលព្រះពុទ្ធោវាទនិងទស្សនវិជ្ជាតាមផ្លូវព្រះពុទ្ធសាសនាទេ នឹងគ្មានអាវុធអ្វីសម្រាប់ការពារខ្លួន ទល់នឹងមនោគមវិជ្ជាបរទេសដែលមានតម្លៃតាមរបៀបគេដែរ , នៅប្រទេសកម្ពុជា មនោគមវិជ្ជាបរទេសទាំងនោះគ្មានបានហុចផលអ្វី ក្រៅពីការច្របូកច្របល់គ្នានិងការភ្លាំងភ្លាត់ស្មារតីដ៏ខ្លោចផ្សាដែលនាំឲ្យដើរខុសផ្លូវ ផ្ទុយនឹងឧត្ដមប្រយោជន៍ជាតិ ហើយដែលយើងធ្លាប់ទទួលផលអាក្រក់ខ្លះ ៗ ទៅហើយនោះទេ ។ អាស្រ័យហេតុនេះ ព្រះត្រៃបិដកប្រែ « បាលី - ខ្មែរ » ដែលយើងមានចាប់តាំងពីពេលនេះទៅ មានសារៈសំខាន់ណាស់ក្នុងការពង្រីកផ្សព្វផ្សាយព្រះពុទ្ធោវាទ នៃព្រះបរមគ្រូ នៅក្នុងសង្គមជាតិយើង ។ ព្រះត្រៃបិដកនេះមិនផ្ដល់ឧត្ដមប្រយោជន៍ ចំពោះតែព្រះសង្ឃទេ , យុវជនយើងដែលជាអានាគតរបស់ជាតិ ហើយដែលទទួលចំណេះវិជ្ជាយ៉ាងជ្រៅជ្រះខាងច្បាប់ ឬខាងអក្សរសាស្ត្រ , ខាងវិទ្យាសាស្ត្រ ឬខាងវិទ្យាសាស្ត្របច្ចេកទេសសម័យថ្មី ក៏មានលទ្ធភាពអាចគ្រេបជញ្ជក់នូវរសជាតិ នៃអាហារ ខាងផ្លូវចិត្តគំនិតប្រាជ្ញា ពី



www.budinst.gov.kh www.elibraryofcambodia.org

ព្រះត្រៃបិដកនេះបានដូចព្រះសង្ឃយើងដែរ ។

● សមាជិកគ្រប់ជាន់ថ្នាក់នៃអង្គការរដ្ឋ និងពលរដ្ឋយើង ក៏ត្រូវតែចាប់អារម្មណ៍ចំពោះព្រះត្រៃបិដកនេះ ពីព្រោះសមាជិកគ្រប់រូបនោះ ប្រសិនបើខ្លួនហើយមានចំណង់ចង់ល្អតលាស់ខាងផ្លូវចិត្ត ហើយមានឆន្ទៈចង់ជួយកម្ពុជរដ្ឋឲ្យនៅជាខ្មែរ ហើយជួយអង្គការរដ្ឋ ឲ្យមានសភាពស្អាតស្អំនិងប្រសិទ្ធិភាព ក្នុងវិស័យកសាងជាតិ ត្រូវតែមានព្រះត្រៃបិដក មួយចប់នៅកំដរជំណោកខ្លួន ។

សម្រួលចាក ទស្សនាវដ្តីពុទ្ធិកសិក្សា

# គ្រូបាអាចារ្យ និងសិស្ស

● ជនពីរប្រភេទ គឺគ្រូនិងសិស្ស ត្រូវមានទំនាក់ទំនង រវាងគ្នានិងគ្នាយ៉ាងជិតស្និទ្ធ ។ ករណីទាំងពីរនេះ ពុំអាចស្ថិតនៅដាច់ស្រឡះពីគ្នាបានឡើយ ។

● ករណីយកិច្ចរបស់គ្រូបាអាចារ្យ ចំពោះសិស្សត្រូវណែនាំសិស្សឲ្យប្រព្រឹត្តល្អគ្រប់ពេលវេលា , ត្រូវបញ្ជាឲ្យរៀនដោយត្រឹមត្រូវនឹងច្បាប់ , ត្រូវប្រាប់សិល្បវិជ្ជាដល់សិស្សឲ្យអស់ ដោយគ្មានលាក់លៀម , ត្រូវលើកតម្កើងសិស្សក្នុងទីចំពោះមុខមិត្តអាមាត្យ , ត្រូវធ្វើសេចក្តីការពារ ក្នុងទិសទាំងឡាយ គឺនឹងទៅក្នុងទីណាមិនឲ្យលំបាក ។

● ករណីយកិច្ចរបស់សិស្ស ចំពោះគ្រូបាអាចារ្យ: ត្រូវក្រោកឈរទទួល ក្នុងខណៈដែលគ្រូបាអាចារ្យដើរមកដល់ , ត្រូវចូលទៅចាំបម្រើលោក ត្រូវជឿស្តាប់នូវវាទលោកនិងត្រូវឧបដ្ឋាកបម្រើលោក ។



www.budinst.gov.kh www.elibraryofcambodia.org

## សំណួរ

១- ចូរពន្យល់ពាក្យ : ប្រភេទ គ្រូ សិស្ស ករណី ករណីយ អាមាត្យ ឧបដ្ឋាក ។

២- ចូររៀបរាប់អំពីមុខការលោកជាសិស្សដែលត្រូវប្រព្រឹត្ត ចំពោះគ្រូ ។

៣- គ្រូមានធម៌ប៉ុន្មានយ៉ាង សម្រាប់សង្គ្រោះសិស្ស ? ចូរពន្យល់ ។

---

# សង្គហធម៌

សង្គហធម៌ គឺការជួយគ្នាទៅវិញទៅមក ក្នុងករណីដែលនរណាមួយទទួលទុគ្គតភាព, សូម្បីតែជនដែលពុំមានទំនៀមទម្លាប់ ជាប់ទាក់ទិនគ្នា ក៏គេត្រូវតែជួយសង្គ្រោះដែរ កាលបើអាចប្រព្រឹត្តទៅបាន ។

កម្មផល បែងចែកឲ្យសត្វលោក ទទួលដោយពេញមុខ នូវគុណសម្បត្តិនិងលក្ខណៈសម្បត្តិប្លែកៗគ្នា គឺខ្លះមានទ្រព្យសម្បត្តិ សម្បូរទ្រព្យគស្តុកស្តម្ភ ខ្លះប្រកបដោយទុគ្គតភាពអត់ឃ្លានទុរ្ភិក្សធ្លាក់ក្នុងហីនភាព ខ្លះមានរូបពាចរិយាខ្ពង់ខ្ពស់ឧត្តុង្គឧត្តមសមរម្យជុំជិត គួរឲ្យពិតពិលរមិលមើល, ខ្លះប្រកបដោយរូបពាសោគម្រក់ព្រហើនកោងកាចអន្យតិរ័យ ខ្មាំងមិលស៊ីមឹង អបលក្ខណ៍ជួជាតិឃ្លាតពីច្បាប់មនុស្សធម៌, ខ្លះមានប្រាជ្ញាបាធីជាសជាតិកបញ្ញា ខ្លះអប្បប្រាជ្ញាល្ងង់ខ្លៅ ប្រៀបបាននឹងសត្វតិរច្ឆាន ។ គូបដិបក្សទាំងនេះ បើរស់នៅជាច់ស្រយាល



www.budinst.gov.kh www.elibraryofcambodia.org

ពីគ្នានោះ សុភមង្គលសង្គមមនុស្ស ប្រាកដជាពុំមានបរិយាកាសបរិសុទ្ធឡើយ យ៉ាងនេះហើយ បានជាម្នាក់ ៗ ត្រូវមានសង្គហធម៌ ដើម្បីធ្វើឲ្យកុដុម្ពិកជួយទាសាទាសី អ្នកមានសុជីវធម៌ជួយតម្រង់អ្នកគ្មានសុជីវធម៌ បណ្ឌិតជនជួយពាលជន ដោយវិធីសង្គ្រោះតាមផ្លូវទ្រព្យសម្បត្តិ អាហារភោជនទិនផ្លូវចំណេះវិជ្ជា ។ កាលបើសង្គមមនុស្សមានសង្គហធម៌ ជាខ្សែឬជានសថទិព្វ សម្រាប់ចងរុំពន្ធពន្ធហើយ សេចក្ដីសុខសាន្តត្រាណនឹងមានជានិច្ចនិរន្តរ៍ ។

## សំណួរ

១- ចូរពន្យល់ន័យនៃពាក្យ : សង្គហធម៌ ទុគ្គតភាព សម្បកខ្ទេយុគ ទុរ្ភិក្ស អន្យតិរិយ សជាតិបញ្ញា ។

២- ចូរតែងឃ្លាជាមួយនឹងពាក្យ : ករណី សង្គ្រោះ ឧត្តុង្គឧត្តម នសថទិព្វ ។

៣- ចូរអធិប្បាយអំពីសង្គហធម៌ ។

---

## ស្វស្តិ និងអពមង្គល

● សម័យថ្ងៃមួយ អពមង្គលចោទសួរសិរីសួស្ដីថា ‹‹ ម្នាល ! សិរីសួស្ដី ! ឯងមានអំណាចដូចម្ដេចខ្លះ ? ចូរថ្លែងលមើល៍ ? សិរីសួស្ដីហក់ប្រែចចូលក្នុងសពាំង្គកាយ អាតុល កូនមហាសេដ្ឋី ។ ចាប់តាំងពីពេលនោះមក លោកសេដ្ឋី



www.budinst.gov.kh www.elibraryofcambodia.org

លើកតម្កើងអាតុល ទុកដូចជាកូនបង្កើត ហើយក៏ដណ្តឹងធីតាព្រះមហាក្សត្រឲ្យជាភរិយា ។ ព្រះនរបតីសព្វព្រះរាជហឫទ័យ លើកកូនប្រសាឲ្យឡើងសោយរាជ្យមាននាមច្បាស់ថាស្តេចតុល ។

● ថ្លែងពីអពមង្គល កាលបើឃើញហេតុភេទអស្ចារ្យ របស់សិរីសួស្តីខ្លាំងពូកែសក្តិសិទ្ធិ ក៏កោតសរសើរបារមីក្រៃលែង ហើយបញ្ជាឲ្យសិរីសួស្តីថយចេញពីស្តេចតុល ខ្លួនចូលទៅម្តងវិញ ។ តាំងពីអពមង្គលចូលលុកក្នុងខ្លួនស្តេចតុលពេលណា សេចក្តីអផ្សុកអប្បសាទ្ធ កើតឡើងពោរពេញព្រះសព៌ាង្គកាយ នៅមិនស្រណុកបក់មិនល្ហើយ ក៏នាំពលរេហ៍មួយអន្លើដោយមហេសី ទៅប្រពាតព្រៃ លុះស្តេចតុលយាងចរចូលទៅដល់ព្រៃរហោឋាន កើតវិប្បដិសារីស្តាយក្រោយ នឹកស្រងេះស្រងោច រសាប់រសល់ខ្វល់ខ្វាយ ពោលពាក្យសត្យាប្រាប់រាជធីតាថា « ខ្លួនខ្ញុំជាអតីតទាសារបស់សេដ្ឋី » រាជធីតាខ្មាស់ណាស់ ក៏នាំវត្តមាននោះទូលដល់ព្រះវរបិតា ព្រះនរនាថមានព្រះកម្ញាល់ ក៏បណ្តេញស្តេចតុលឲ្យចុះចាកតំណែងរាជ្យក្លាយទៅជាខ្ញុំបម្រើសេដ្ឋីដដែល ។

## សំណួរ

១– ចូរពន្យល់ន័យនៃពាក្យ : សួស្តី អពមង្គល អស្ចារ្យ ពលរេហ៍ ។

២– ចូររកសទិសសូរសព្ទនឹងពាក្យ : សក្តិ នាថ ។

៣– ចូរនិទានរឿងស្តេចតុល ដោយគំនិតយល់ឃើញ ។



www.budinst.gov.kh www.elibraryofcambodia.org

## អរច្ឆរិយាភិនិក្ខមណ៍

● មហាបុរសរតន៍ ទ្រង់នាមាភិធេយ្យថា ព្រះសិទ្ធត្ថៈ ឬ ព្រះសិទ្ធាថ ទ្រង់ស្ដេចចេញពីព្រះរាជនិវេសន៍វាំង យាងទៅក្រសាលឧទ្យាន មួយអន្លើដោយអាជានេយ្យ សេះសន្ធព មានពពួកសេវកាមាត្យជារាជបរិវារ ។ ព្រះបរមពោធិសត្វទ្រង់ទតព្រៃព្រឹក្សា ដែលល្អតលាស់ដុះត្រៀបត្រា ទ្រង់ឮសូរសព្ទបក្សីបក្សាដែលយំស្រែកគ្នាឲ្យលន្លង់លន្លោច ទ្រង់ឃើញសុទ្ធាវាសទេវតាដែលកាឡាភេទជាព្រឹទ្ធាចារ្យចាស់ជរាទុព្វលភាពទុរន់ទុរា ទ្រង់ក៏មានព្រះទ័យសង្វេគឥតឧបមានាកាលសប្ដាហ៍កន្លងទៅ មិនទាន់រលត់ផុតពីស្រមុតចិត្តផង ទ្រង់បានយល់មនុស្សមានព្យាធិសម្ដម ដេកបម្រះនន្ទៀលស្រែកយំឈឺផ្សា ក្សត្រាក៏រឹតតែកើតក្ដីពុះពោរដោយសេចក្ដីសង្វេគទ្វេឡើង ។ វារៈជាគម្រប់បី ពោធិសត្វពិតមារក្រឡេកឈ្វេងយល់ សាកសពបុគ្គលត្រូវរមណ៍ប្រល័យស្លាប់តាយស្ទឹងកណ្ដាលមាគ៌ា ព្រះអង្គទ្រង់យល់សព្វប្រការ តាមវាចាដែលនាយសារថីក្រាបបង្គំទូល, ទ្រង់មានសេចក្ដីសោកសង្រេងក្នុងព្រះទ័យរកឧបមានុបមេយ្យប្រៀបពុំបានៗ ជាអវសាននៃព្រះរាជទស្សនកិច្ច ទ្រង់បានពើបពះប្រទះនឹងភេទបព្វជិត មានព្រះចិន្ដាសោមនស្សឥតឧបមា ។

● ព្រះរាជដំណើរនិវត្តដល់ព្រះរាជនិវេសន៍ យប់យន់អាធ្រាត្រស្ងាត់មជ្ឈិមយាម នាថ្ងៃពេញបូណ៌មីនៃថ្ងៃព្រហស្បតិ៍ ខែអាសាឍ ឆ្នាំថោះ, នាងនាដកិត្តិស្រីរបាំ លេងប្រគំដេញដំផ្លូវ្យដន្ត្រីដេកលក់ស្កប់ស្កល់ផ្ដល់វិប្បការហៀរទឹកមាត់អាក្រាតរាងកាយ ហាក់ដូចជាមានសាកសពពាសពេញប្រាសាទ ។ ព្រះអង្គដាច់ព្រះទ័យ



www.budinst.gov.kh www.elibraryofcambodia.org

ចោលបុត្រពន្ធក និងអគ្គមហេសី ដាស់ឆន្នាមាត្យ ឲ្យទាំយកកណ្ឋកអាជានេយ្យមក ហើយទ្រង់គង់លើអស្សពាហន៍ បរសំដៅទៅកាន់អភិនិក្ខមនដ្ឋាន លើផ្លូវខ្សាច់នាត្រើយនាយនៃស្ទឹងអនោមា ។

## ទុក្ករកិរិយា

● ព្រះសិទ្ធត្ថកុមារបរមពោធិសត្វ ទ្រង់កម្ចាត់បង់នូវសេចក្ដីសុខក្នុងរាជសម្បត្តិ សាងបព្វជ្ជា ជាបព្វជិត ទ្រង់កម្ចាត់តណ្ហាដោយអត់អាហារ ៧ ថ្ងៃ ក្នុងអនុអម្ពវ័ន ។ អ្នកនគររាជគ្រឹះផ្អើលអឺអរឈូឆរត្រេកអរសោមនស្ស ជាអតិបរមា ក្នុងពេលដែលព្រះពោធិសត្វយាងទៅបិណ្ឌបាត នៅថ្ងៃជាគម្រប់ ៨ ហើយព្រះអង្គត្រូវបានទទួលការឧបត្ថម្ភពីព្រះបាទពិម្ពិសារ ។

ព្រះអង្គខំស្វះស្វែងរកវិជ្ជា ទៅសិក្សាក្នុងសម្នាក់អាឡារតាបស និងឧទ្ទកតាបសចេះចប់អស់ ទ្រង់សាកសួររកធម៌ពិតទៅតាបសទាំងពីរទញ់គំនិតរកមិនឃើញ ទើបព្រះអង្គយាងទៅកាន់ឧរុវេលនិគម តាំងខ្ជាប់នូវមហាបធានត្រិះរិះដោយផ្ទាល់ព្រះអង្គ ដោយធ្វើទុក្ករកិរិយា បន្ថយក្រយាស្ងោយរហូតដល់លែងសោយសោះ ខំប្រឹងលុះស្គមកំព្រឹងនៅសល់តែស្បែកនិងឆ្អឹង ប្រដាប់ដោយខ្សែសរសៃរុំពទ្ធអង្គប្រាណដូចវល្លិ៍ជ្រៃ ។ មិនយូរប៉ុន្មានព្រះអង្គទ្រង់ដួលស្លកស្ដឹងលើផែនពសុធា ទេវតាគ្រប់បានឆកាមាវចរ មានទេវតាបានត្រៃត្រឹង្សជាដើម ផ្អើលឆោឡោ សក្កទេវរាជបើកទិព្វ–



www.budinst.gov.kh www.elibraryofcambodia.org

ចក្ខុទាញពិណមានខ្សែបីមកដេញថ្វាយ រឹតខ្សែមួយតឹងដាច់ភឹង, រឹតខ្សែពីរធូរស្លុះមិនពីរោះ, រឹតខ្សែមួយយ៉ាងកណ្តាល សម្លេងពីរោះស្រួល ។ ទ្រង់មានស្មារតីឡើងឈ្វេងយល់អំពើប្រព្រឹត្តិតឹងពេក នាំឲ្យខូចប្រយោជន៍ ហើយព្រះអង្គក៏សោយក្រយាស្ងោយវិញជាធម្មតា ពួកភិក្ខុបញ្ចវគ្គិយសម្គាល់ឃើញព្រះអង្គបែរមកឆាន់ចង្ហាន់ដូច្នោះ ក៏នាំគ្នាថយទៅនៅឯព្រៃឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ដោយយល់ថា ព្រះសិទ្ធត្ថធ្វើទុក្ករកិរិយាអស់ ៦ វស្សា ម្តេចគង់មិនបានត្រាស់ដឹង ចុះចំណង់បើព្រះអង្គត្រឡប់បែរសោយក្រយាហារជាធម្មតាវិញ តើកាលណាឡើយនឹងបានជួបនូវមោក្ខធម៌ ។

---

## ពុទ្ធបូជា

● សម័យនោះមានឧបាសិកាម្នាក់ឈ្មោះសុជាតា ជាធីតានៃសេនកុដុម្ពិក បានចំណាយទ្រព្យបួនសែនកហាបណៈ ដើម្បីចាត់ចែងធ្វើពលិកម្ម ចំពោះទេពតាទាំងឡាយ ដែលរក្សាដើមជ្រៃ ក្រោយពីបានកូនប្រុសច្បងម្នាក់តាមបំណង ។

● ព្រឹកព្រាងរាំងស្រឡះ ទក្ខត្តឫក្សប្រកបដោយតិថីពេញបូណ៌មីនៃខែពិសាខ នាងសុជាតាយកភាជន៍ទៅត្រងយកទឹកដោះគោ មកចម្អិនជាមធុបាយាស ខណៈនោះចតុលោកបាល បានចុះមកជួយរក្សាជើងក្រាន មហាព្រហ្មយកស្វេតច្ឆត្រមកបាំង , សម្តេចអមរិន្ទ្រាធិរាជថែភ្លើង, ទេវតាក្នុងសែនចក្រវាឡ នាំទិព្វឱជារសមកដាក់ក្នុងមធុបាយាស ដោយអនុភាពរបស់ខ្លួន ។ លុះចម្អិនរួចស្រេចកាលណា



www.budinst.gov.kh www.elibraryofcambodia.org

នាងសុជាតាមួយអន្លើដោយនាងបណ្ណាទាសី ឆ្ពោះទៅដើមជ្រៃ ថ្វាយមធុបាយាស ព្រមទាំងភាជន៍មាស ហើយក៏ដើរចេញទៅ ។

● ថ្ងៃងពីពេលនោះ មហាបុរសរ័តន៍ ទ្រង់តើនចាកអាសនាយាងប្រទក្សិណដើមជ្រៃបីជុំ រួចហើយ ព្រះហស្តកាន់ភាជន៍យាងទៅកាន់ស្ទឹងនេរញ្ជរា ដល់ហើយក៏តម្កល់ទុកទៀបឆ្នេរស្ទឹង ចុះស្រង់ទឹក រួចស្រេចកាលណា ទ្រង់បែរព្រះភក្ត្រទៅកាន់បុរត្ថិមទិស ពូតមធុបាយាសជា ៤៩ ពំនូត សោយអស់រលីងហើយទ្រង់អធិដ្ឋានបណ្តែតភាជន៍មាសទៅក្នុងស្ទឹង ។ ក្នុងសាយណ្ហសម័យ សោត្ថិយព្រាហ្មណ៍បានថ្វាយស្មៅសម្រាប់ទ្រាប់គង់ ឧប្បត្តិកជារតនបល្ល័ង្ក ហើយព្រះអង្គបានអធិដ្ឋានមាំថា បើអាត្មាអញមិនបានត្រាស់ទេ និងមិនក្រោកចាកបល្ល័ង្កនេះឡើយ ។

---

## ចិត្តភក្តី

● ពុទ្ធមាមកជន ទោះបីក្នុងនិគមជនបទច្រកល្ហកតូចតាចក៏ដោយ គង់នៅដឹងដែរថាក្នុងយប់ព្រះសិទ្ធត្ថ គង់លើរតនបល្លង្ក ពពួកមារមានចិត្តបាប បានផ្តន្ទាផ្តាញ់ព្រះអង្គដោយវិធានការច្រើនយ៉ាង មានការនិម្មិតខ្យល់ព្យុះសង្ឃរា បក់រំលើងលេណដ្ឋានព្រៃភ្នំក្រំថ្មគិរីបពិត និងបង្អុរភ្លៀងធំ, ភ្លៀងដុំថ្ម, ភ្លៀងគ្រឿងប្រហារ, ភ្លៀងរងើកភ្លើង, ភ្លៀងផេះក្តៅ, ភ្លៀងដីខ្សាច់, ភ្លៀងភក់, ផ្សែងងងិតអ័ព្ទពាសពេញទិសទស ដើម្បីផ្តាញ់ឲ្យព្រះអង្គឃ្លាតចាករតនបល្លង្គ ។ តែផ្ទុយទៅវិញ នាំឲ្យព្រះអង្គរឹតតែមានចិត្តភក្តីតរាំងមាំ យកព្រះធរណី ធ្វើជាបន្ទាល់នៃព្រះ



www.budinst.gov.kh www.elibraryofcambodia.org

ទ័យព្រះអង្គ ។ ក្រុងមារក្ដៅណាស់ ចាប់យកចក្រាវុធមុខមុតពិសិដ្ឋ ចោលតម្រង់ទៅរកព្រះបរមពោធិសត្វ ក្លាយទៅជាពិតានស្ថិតនៅពីខាងលើវិញ ។ ចំណែកពួកមារបរិស័ទ ចាប់កាច់កំពូលភ្នំធំ ៗ ចោលសំដៅព្រះពោធិសត្វ ក្លាយទៅជាមាលាសម្រាប់បូជាព្រះអង្គវិញ ។ ពួកទេវតា ដែលរក្សាព្រះសិទ្ធត្ថ ភ័យណាស់រត់ទៅឈរលើភ្នំចក្រវាឡហើយគិតគ្នាថា ព្រះពោធិសត្វប្រត្យក្សជាក្សិណក្ស័យដោយសម្មាដៃមារហើយមើលទៅ ។ ជាអវសាន ជ័យជម្នះត្រូវបានទៅលើព្រះសិទ្ធត្ថសពើជ្ញតាញាណ ពួកមារបាក់បបខ្វបខ្វាចចុះញ៉ម ទទួលស្គាល់ ព្រះពោធិសត្វថាជាមហាបុរសប្រកបដោយចិត្តភក្ដី ដើម្បីឆ្លងកាត់វដ្តសំសារ នាំសត្វទៅកាន់ត្រើយគឺព្រះនិព្វាន ។

## សំណួរ

១– ចូរពន្យល់ន័យពាក្យ : ពុទ្ធមាមកជន រតនបល្ល័ង្ក លេណដ្ឋាន ប្រត្យក្ស សពើជ្ញតាញាណ ។

២– ចូរពន្យល់គំនិតអត្ថខាងលើនេះ ។



www.budinst.gov.kh www.elibraryofcambodia.org

រោងពុម្ព មិត្តភាព

កម្ពុជា-ជប៉ុន

តម្លៃ ៖ ១២០០ ៛

www.budinst.gov.kh www.elibraryofcambodia.org